ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

# ក្របខ័ណ្ឌគោលនយោបាយ និង
# គោលការណ៍ណែនាំសំរាប់ប្រតិបត្តិ

**Version 1**

ភ្នំពេញ ខែ សីហា ឆ្នាំ ២០០៧

# បុព្វកថា

ឯកសារគោលនយោបាយ និងសេចក្តីណែនាំប្រតិបត្តិសំរាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបាន បង្ហាញនូវការបោះជំហានទៅមុខដ៏មានសារៈសំខាន់មួយ របស់ក្រសួងសុខាភិបាលជាពិសេសសំរាប់នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកកំពស់មុខងារ និងតួនាទីរបស់នាយកដ្ឋានអោយដំណើរការកាន់តែមាន ប្រសិទ្ធភាពថែមទៀត តាមរយៈការដឹកនាំ និងសំរបសំរួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានាកិច្ច សំរបសំរួលក្នុង ការគ្រប់គ្រងកម្មវិធីជំនួយនៅក្នុងវិស័យសុខាភិបាល ។

ក្នុងនាមក្រសួងសុខាភិបាល នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការ អន្តរជាតិ និងកិច្ចការអាស៊ាននៅក្នុងវិស័យសុខាភិបាល។ ភារកិច្ចនេះអាចសម្រេចទៅបានអាស្រ័យលើការសំរប សំរួល និងសហប្រតិបត្តិការជាមួយផ្នែកពាក់ព័ន្ធនានា ដោយរួមជាមួយនឹងការរៀបចំចងក្រងគោលនយោបាយ សំរាប់កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសុខាភិបាល ដើម្បីធានាអោយមានសុខដុម្មនីយកម្ម ការតំរង់ទិស ភាពជា ម្ចាស់ និងសារៈប្រយោជន៍ជាតិ ។

ដើម្បីជួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារនិងតួនាទីរបស់ខ្លួន អោយស្របទៅនឹង ប្រកាសរបស់ក្រសួងសុខាភិបាល ឯកសារគោលនយោបាយនិងសេចក្តីណែនាំប្រតិបត្តិ នៃនាយកដ្ឋានសហប្រតិ បត្តិការអន្តរជាតិ ត្រូវបានរៀបចំចងក្រងឡើងដោយមានការពិគ្រោះពិភាក្សាជាមួយគ្រប់ភាគីពាក់ព័ន្ធ ដៃគូរ អភិវឌ្ឍន៍ក្នុងវិស័យសុខាភិបាល ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និង ស្ថាប័នជាតិនានារួមទាំងអង្គភាពចំណុះរបស់ក្រសួងសុខាភិបាលជាដើម។ ឯកសារគោលនយោបាយ និងសេចក្តី ណែនាំប្រតិបត្តិនេះ និងក្លាយជាឧបករណ៍ដ៏សំខាន់មួយចំពោះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្នុងការបំពេញ តួនាទីនិងភារកិច្ចរបស់ខ្លួន ដោយមានប្រសិទ្ធភាពក្នុងកិច្ចសំរបសំរួលគ្រប់គ្រងកម្មវិធីជំនួយនានា នៅក្នុងវិស័យ សុខាភិបាល។

ក្រសួងសុខាភិបាលមានក្តីសោមនស្សរីករាយអនុម័ត និងដាក់អោយប្រើប្រាស់នូវឯកសារគោល នយោបាយដ៏មានសារៈសំខាន់នេះ ហើយយើងមានជំនឿដ៏មុតមាំថា ឯកសារនេះនឹងផ្តល់មូលដ្ឋានដ៏សំខាន់មួយ ដើម្បីធានាអោយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបំពេញមុខងារដោយប្រសិទ្ធភាព។ បន្ថែមលើនេះទៀត ឯកសារនេះ នឹងផ្តល់ជាក្របខ័ណ្ឌដែលអនុញ្ញាតិអោយក្រសួងសុខាភិបាល និងដៃគូរអភិវឌ្ឍន៏វិស័យសុខាភិបាល

អាចធ្វើការរួមគ្នាដើម្បីលើកកំពស់ប្រសិទ្ធភាព និងគុណប្រយោជន៍ជំនួយក្នុងវិស័យសុខាភិបាល ។ ឯកសារនេះអាចត្រូវបានពិនិត្យកែសំរួលឡើងវិញ ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិប្រសិនបើចាំបាច់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៧

សាស្ត្រាចារ្យ អេង ហួត

រដ្ឋលេខាធិការក្រសួងសុខាភិបាល

# មាតិកា


១ សេចក្តីផ្តើម ០១

២ គោលនយោបាយរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ០២

៣ តួនាទី មុខងារ និងការអនុវត្តន៍របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ០៣

៣.១. ការសំរបសំរួលដៃគូអភិវឌ្ឍន៍សុខាភិបាល ០៦

៣.២. ការសំរបសំរួលកិច្ចការសុខាភិបាលអាស៊ាន ១០

៣.៣. ការសំរបសំរួលសហប្រតិបត្តិការអន្តរជាតិនៃវិស័យសុខាភិបាល និងទំនាក់ទំនងសាធារណៈ ១២

៣.៤. សំរបសំរួលក្រុមការងារបច្ចេកទេសសុខាភិបាល និងការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេស សុខាភិបាលថ្នាក់ខេត្ត ១៣

៣.៥. ការគ្រប់គ្រងពតិមានជាយុទ្ធសាស្ត្រ ១៦

៤ គោលនយោបាយនៃការគ្រប់គ្រងចំពោះសហប្រតិបត្តិការលើកិច្ចអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ២១

៥ បរិយាកាសស្ថាប័នដែលទ្រទ្រង់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ២៤

ឧបសម្ព័ន្ធ១: សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានាស្តីពីការពង្រឹងប្រសិទ្ធភាពជំនួយ ២៩

ឧបសម្ព័ន្ធ២: តួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល ៣៧

ឧបសម្ព័ន្ធ៣: តួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត ៣៩

ឧបសម្ព័ន្ធ៤: សេចក្តីថ្លែងពីបំណងផ្តួចផ្តើមសកម្មភាពថ្មីក្នុងវិស័យសុខាភិបាលកម្ពុជា ៤១

ឧបសម្ព័ន្ធ៥: ទិន្នន័យដែលទទួលបានពីការលើកឡើងក្នុងកិច្ចប្រជុំ ៤២

ឧបសម្ព័ន្ធ៦: របាយការណ៍សកម្មភាពប្រចាំឆមាសរបស់ទីភ្នាក់ងារអនុវត្តគំរោង ៤៣

ឧបសម្ព័ន្ធ៧: អនុស្សរណៈនៃការយោគយល់ របស់ទីភ្នាក់ងារអនុវត្តន៍ដោយផ្ទាល់ ៤៩

## ១. សេចក្តីផ្តើម

នាខែតុលា ឆ្នាំ២០០៦ ក្រសួងសុខាភិបាលបានចេញប្រកាសលេខៈ៩១៩ ស.ន.ប ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៦ កំណត់ការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិដោយបញ្ចូលរួមគ្នានូវការិយាល័យទំនាក់ទំនងអន្តរជាតិ និង ការិយាល័យកិច្ចការអាស៊ានដែលមានស្រាប់ ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិស្ថិតនៅក្រោមការដឹកនាំដោយផ្ទាល់នៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ហើយក្នុងនាមក្រសួងសុខាភិបាល នាយកដ្ឋាននេះមានភារកិច្ចទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាននៅក្នុងវិស័យសុខាភិបាល។ ភារកិច្ចនេះនឹងត្រូវធ្វើអោយសម្រេចបាន តាមរយៈកិច្ចសំរបសំរួល និងសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងអស់ ។ ការរៀបចំចងក្រងនៃគោលនយោបាយ និងគោលការណ៍ប្រតិបត្តិសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យសុខាភិបាល ដើម្បីធានាអោយមានសុខដុមនីយកម្ម ការតំរង់ទិស ភាពជាម្ចាស់ និងបំរើផលប្រយោជន៍ជាតិ ។

គោលនយោបាយ និងគោលការណ៍ប្រតិបត្តិរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវបានបែងចែកជាប្រាំផ្នែក។ ផ្នែកទីពីរបញ្ជាក់អំពីគោលនយោបាយរបស់នាយកដ្ឋានដោយផ្អែកទៅលើ **សេចក្តីប្រកាសនៅទីក្រុងប៉ារីសស្តីអំពី ការប្រើប្រាស់ជំនួយឱ្យមានប្រសិទ្ធភាព** ដើម្បីជួយតំរង់ទិសកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិនានារបស់នាយកដ្ឋាន។ ផ្នែកទីបីបង្ហាញអំពីតួនាទីនិងភារកិច្ចរបស់នាយកដ្ឋានរួមទាំងសូចនករ ដើម្បីជួយសំរួលឱ្យនាយកដ្ឋានអាចបំពេញបាននូវតួនាទី និងភារកិច្ចរបស់ខ្លួនបានពេញលេញ។ ផ្នែកទីបួននិងទីប្រាំជាបន្តបន្ទាប់រៀបរាប់យ៉ាងទូលំទូលាយអំពីគោលនយោបាយ និងបរិដ្ឋានដែលនាយកដ្ឋានត្រូវប្រតិបត្តិ ដើម្បីជួយទ្រទ្រង់កិច្ចសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍន៍នៅក្នុងវិស័យសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងសុខាភិបាលកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការធ្វើកំណែទំរង់ ។ គោលនយោបាយ តួនាទី ភារកិច្ច និងសកម្មភាពរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលបានបង្ហាញជូនខាងក្រោមនេះ អាចនឹងមានការវិវត្តន៍ ក្នុងបរិបទនៃកំណែទំរង់ដ៏ទូលំទូលាយនៃស្ថាប័ន ដែលស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ។

## ២. គោលនយោបាយរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ[២]

ភារកិច្ចគន្លឹះរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិគឺសំរបសំរួលការប្រើប្រាស់ជំនួយ ឱ្យមានប្រសិទ្ធភាពនៅក្នុងវិស័យសុខាភិបាល ហើយក៏ជាការចូលរួមចំណែកដើម្បីធ្វើអោយសំរេចបាននូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ និងសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្ស ។ នៅក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិអាចនឹងផ្អែកលើគោលនយោបាយ និងគោលការណ៍ប្រតិបត្តិដែលឈរលើគោលការណ៍ទាំងប្រាំ នៃសេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីការគ្រប់គ្រងជំនួយឱ្យមានប្រសិទ្ធភាព:

**ភាពជាម្ចាស់:** នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងផ្តល់នូវភាពជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាពនៅក្នុងការសំរបសំរួលនៃការគ្រប់គ្រងជំនួយកម្មវិធីនៅក្នុងវិស័យសុខាភិបាល។ ដៃគូអភិវឌ្ឍនៅក្នុងវិស័យសុខាភិបាល (អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយទ្វេភាគី ពហុភាគី និងផ្នែកឯកជន) និងគោរពនូវភាពជាម្ចាស់និង ភាពជាអ្នកដឹក នាំរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៅក្នុងការអភិក្រមគ្រប់គ្រងកិច្ចការងារអភិវឌ្ឍន៍។

**កាតំរង់ទិស:** នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងរៀបចំគ្រប់គ្រងទៅលើកិច្ចព្រមព្រៀងជាមួយនឹងដៃគូរអភិវឌ្ឍន៍ដែលកំណត់អំពីវិសាលភាពនិង ប្រភេទនៃការឧបត្ថម្ភរបស់ដៃគូរអភិវឌ្ឍន៍វិស័យសុខាភិបាល រួមទាំងកិច្ចព្រមព្រៀងដែលសមស្របទៅនិងគោលនយោបាយនិងអាទិភាព។ ដៃគូអភិវឌ្ឍនឹងតំរង់ទីសនូវការឧបត្ថម្ភរបស់គេជាមួយគោលនយោបាយនិងអាទិភាពរបស់វិស័យសុខាភិបាលជាតិដែលកំណត់ដោយផែនការយុទ្ធសាស្ត្រ សុខាភិបាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដៃគូអភិវឌ្ឍន៍នឹងធ្វើឱ្យមានការកើនឡើងនូវការប្រើប្រាស់ស្ថាប័នដែលរឹងមាំប្រព័ន្ធ និងនិតិវិធីនានារបស់ក្រសួងសុខាភិបាល ហើយព្រមទាំងជៀសវាងការបង្កើតឱ្យមានប្រព័ន្ធនិងរចនាសម្ព័ន្ធដែលមានលក្ខណៈត្រួតស៊ីគ្នា ។

**សុខដុមនីយកម្ម:** ដៃគូអភិវឌ្ឍនឹងទទួលយកនូវការរៀបចំ និងនិតិវិធីដែលបានកែសំរួលដោយក្រសួងសុខាភិបាលសំរាប់ប្រើប្រាស់ជាលក្ខណៈរួមចំពោះ ការគ្រប់គ្រង តាមដាន វាយតម្លៃ និងការធ្វើរបាយការណ៍គំរោងកម្មវិធី ហើយធ្វើការពង្រីកវិសាលភាពប្រើប្រាស់ដោយដៃគូរតាមដែលអាចធ្វើបាន។ ។ ជាមួយគ្នានោះដែរដៃគូអភិវឌ្ឍន៍នឹងត្រូវបានស្នើសុំអោយកាត់បន្ថយចំនួនបេសកកម្ម និងការពិនិត្យឡើងវិញដែលដាច់ឡែកៗតែត្រួតស៊ីគ្នា និងជួយបង្កើនការប្រើប្រាស់អោយកាន់តែច្រើននូវកិច្ចសន្យាសហប្រតិបត្តិការដែលបានព្រមព្រៀងគ្នា។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនឹងសំរបសំរួលជួយដៃគូអភិវឌ្ឍក្នុងការបំពេញកាតាព្វកិច្ច ផ្តល់ពតិមាន និងធ្វើបច្ចុប្បន្នភាព

---

[2] គំរោងគោលនយោបាយដែលមានលក្ខណៈទូលំទូលាយថ្នាក់ជាតិដែលនាយកដ្ឋានសហប្រតិបត្តិការអនុវត្ត និងលើកយកមកបកស្រាយនៅក្នុងផ្នែកទី ៤

ពត៌មានជំនួយអភិវឌ្ឍន៍ផ្លូវការទាំងអស់ចំពោះវិស័យសុខាភិបាលមកក្រសួង ហើយពត៌មានដែលប្រមូលបាននឹងត្រូវបានចងក្រង នឹងផ្តល់ជូនសំរាប់ការប្រើប្រាស់ ។

**គ្រប់គ្រងផ្តោតទៅលើលទ្ធផលៈ** ដើម្បីពង្រីកនូវវិសាលភាពជាអតិបរមា ដៃគូអភិវឌ្ឍនឹងរួមចំណែក និងសំរបកម្មវិធីឬគំរោងខ្លួនទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការរំកិលបីឆ្នាំរបស់ក្រសួងសុខាភិបាល ។ ដៃគូរអភិវឌ្ឍនឹងធានាឱ្យបានជាអតិប្បរមាតាមដែលអាចធ្វើបានថា ពួកគេនិងអនុវត្តទៅតាមច្បាប់ បទបញ្ជា និងនិតិវិធី នៅក្នុងការអនុវត្តន៏ តាមដាន និងធ្វើរបាយការណ៍ទៅលើកម្មវិធីឬគំរោងរបស់ពួកគេ ដើម្បីកាត់បន្ថយការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនឹងចូលរួមចំណែកក្នុងសកម្មភាពរៀបចំផែនការនិងការសំរេចចិត្តដោយរក្សានិងធ្វើការរៀបចំនិងធ្វើបច្ចុប្បន្នភាពឯកសារ និងពត៌មាន ស្តីពីជំនួយអភិវឌ្ឍជាផ្លូវការ (ODA) ទាំងអស់សំរាប់វិស័យសុខាភិបាល ។

**គណនេយ្យភាពរួមគ្នាៈ** នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងផ្តល់លទ្ធភាពដល់គ្រប់ផ្នែកពាក់ព័ន្ធ ទាំងអស់ដោយអាចទទួលយកពត៌មានស្តីពីការប្រើប្រាស់ធនធានរបស់ជំនួយអភិវឌ្ឍផ្លូវការទៅក្នុងវិស័យសុខាភិបាល ដើម្បីធ្វើឱ្យមានតម្លាភាពនិងភាពទទួលខុសត្រូវ។ ដៃគូអភិវឌ្ឍនិងផ្តល់នូវពត៌មាន ដែលទាន់ពេលវេលា មានតម្លាភាពនិងទូលំទូលាយ អំពីលំហូរនៃជំនួយអភិវឌ្ឍផ្លូវការ និងសកម្មភាពរបស់កម្មវិធី ឬគំរោងនៅក្នុងវិស័យសុខាភិបាល ។ ដៃគូអភិវឌ្ឍនិងរៀបចំ ធ្វើផែនការនិងផ្តល់ជំនួយចំពោះវិស័យសុខាភិបាលឱ្យកាន់តែមានតម្លាភាព និងការទទួលខុសត្រូវដើម្បីបង្កើនការប្រើប្រាស់ជំនួយឱ្យមានប្រសិទ្ធភាព និងផ្តល់ផលប្រយោជន៏កាន់តែប្រសើរដល់ប្រជាជនកម្ពុជា ជាពិសេសសំរាប់ប្រជាជនក្រីក្រ ។

## ៣. តួនាទី មុខងារ និងការអនុវត្តន៍របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

ប្រកាសអំពីមុខងារ និងការរៀបចំរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ កំណត់នូវ តួនាទី និងភារកិច្ចសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ពង្រឹងកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាប្រទេស និងភ្នាក់ងារផ្តល់ជំនួយនានា និងវិស័យឯកជនដែលជួយវិស័យសុខាភិបាលកម្ពុជា
- ទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំរាប់ការសំរបសំរួលកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យសុខាភិបាល
- ទំនាក់ទំនងសម្របសម្រួលការងារអាស៊ានផ្នែកសុខាភិបាល
- សំរបសំរួលកម្មវិធីជំនួយទាំងជំនួយឥតសំណង ទាំងជំនួយកម្ចីឥណទាន លើសកម្មភាពសុខាភិបាល តាមរយៈការចុះបញ្ជីការ ពិធីសារ កិច្ចសន្យា អនុស្សរណៈយោគយល់គ្នាទៅវិញទៅមក ព្រមទាំង

សហការជាមួយអង្គភាពគ្រប់គ្រង ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងកម្មវិធីទាំងអស់នេះ

- ប្រមូលផ្តុំទិន្នន័យពត៌មានពីសកម្មភាពរបស់ភាគីដៃគូ វិភាគ បូកសរុបធ្វើរបាយការណ៍សកម្មភាពសង្ខេបដាក់ជូនថ្នាក់ដឹកនាំក្រសួង
- ធ្វើរបាយការណ៍សកម្មភាពសង្ខេប អំពីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ សំរាប់ថ្នាក់ដឹកនាំក្រសួង រួមទាំងការចងក្រង និងការផ្សព្វផ្សាយ ។
- រៀបចំដំណើរការ លេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសសុខាភិបាល ដើម្បីធានានូវរាល់កិច្ចប្រជុំជាទៀងទាត់ របស់ក្រុមការងារនេះ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ លើវិស័យសុខាភិបាល ។

ជាមួយគ្នានោះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិត្រូវបានផ្តល់ភារកិច្ចក្នុងការរៀបចំ និងគ្រប់គ្រងលើការអភិវឌ្ឍគេហទំព័ររបស់ក្រសួងសុខាភិបាល និងសំរបសំរួលការ បង្កើតកម្មវិធីគ្រប់គ្រងទិន្នន័យ ក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមនៅក្នុងវិស័យសុខាភិបាល (MTEF) ជាមួយនាយកដ្ឋានផែនការ និងនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល ។

## អង្គការលេខរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

(ផ្អែកទៅលើប្រកាសលេខ ៩១៩ ស.ន.ប ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៦ ដោយក្រសួងសុខាភិបាល)

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានការិយាល័យចំនួនប្រាំ ដែលស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងរបស់ប្រធាននាយកដ្ឋាន ដូចមានបង្ហាញជូនក្នុងអង្គការលេខខាងក្រោមនេះ:




នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានមុខងារស្នូលចំនួន៥ ហើយដែលការិយាល័យចំណុះរបស់នាយកដ្ឋាន មានភារៈទទួលបន្ទុកៈ

1. ធ្វើការសំរបសំរួលជូនដៃគូរអភិវឌ្ឍន៏វិស័យសុខាភិបាលនានា (ដៃគូរសុខាភិបាលសាលក ម្ចាស់ជំនួយ ទ្វេភាគី និង ពហុភាគី ទីភ្នាក់ងារទទួលអនុវត្តន៏គំរោង)
2. បំពេញភារកិច្ចជាស្ថាប័នសំរបសំរួលកិច្ចការអាស៊ានដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល
3. ធ្វើការសំរបសំរួល កិច្ចការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
4. ធានាអោយមានការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពនៃក្រុមបច្ចេកទេសសុខាភិបាល

5. គ្រប់គ្រងពត៌មានជាយុទ្ធសាស្ត្រដែលពាក់ព័ន្ធទៅនឹងកម្មវិធីជំនួយសំរាប់វិស័យសុខាភិបាល ដែលរួមមានៈ ការគ្រប់គ្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ សំរបសំរួលការរៀបចំធ្វើក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម នឹងការគ្រប់គ្រងវេបសាយក្រសួងសុខាភិបាល

មុខងារស្នូលនិមួយៗ នឹងត្រូវបានរៀបរាប់លំអិត ជាសកម្មភាពប្រតិបត្តខាងក្រោម ។

## ៣.១ ការសំរបសំរួលដៃគូរអភិវឌ្ឍន៍សុខាភិបាល

ដើម្បីលើកកំពស់ប្រសិទ្ធិភាពជំនួយលើវិស័យសុខាភិបាល ភារកិច្ចនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរ-ជាតិ គឺអនុវត្តន៍សកម្មភាពទាំងឡាយដែលនឹងសំរួលការ ពិគ្រោះពិភាក្សាលើគោលនយោបាយ ធ្វើការសំរេចចិត្ត ការធ្វើផែនការ ការតាមដាននិងវាយតំលៃលើជំនួយរបស់ដៃគូរអភិវឌ្ឍន៍ក្នុងវិស័យសុខាភិបាលជូនរាជរដ្ឋាភិបាលកម្ពុជា។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងធ្វើសកម្មភាពជាច្រកចេញចូលតែមួយ នឹងជាមជ្ឈមណ្ឌលពត៌មាននៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលពាក់ពន្ធ័និងវិស័យសុខាភិបាល នឹងជាចំនុចភ្ជាប់ទំនាក់ទំនងផ្លូវការដំបូង នឹងជាស្ថាបន័សំរបសំរួលរបស់ក្រសួងសុខាភិបាលជាមួយដៃគូរអភិវឌ្ឍន៍ដែលធ្វើការ ក្នុងវិស័យសុខាភិបាលកម្ពុជា។

<u>សកម្មភាពទាំងឡាយដែលពាក់ពន្ធ័ទៅនិងការសំរបសំរួល ជាមួយដៃគូរអភិវឌ្ឍន៍សុខាភិបាលអាចរួមមាន តែមិនកំរិតដាច់ខាតនោះទេៈ</u>

- ផ្ទៀងផ្ទាត់ និង ពិនិត្យតាមដានការផ្តល់ហិរញ្ញវត្ថុដោយដៃគូរអភិវឌ្ឍន៍ចំពោះវិស័យសុខាភិបាល (ទីភ្នាក់ងាផ្តល់ជំនួយទ្វេភាគី ពហុភាគី និង ស្ថាបន័អនុវត្តន៍គំរោង ឬ អង្គការក្រៅរដ្ឋាភិបាល) ដោយ រួមបញ្ចូលការផ្តល់មូលនិធិដែលមានកិច្ចសន្យា ជាការប៉ាន់ស្មាន និងមូលនិធីពិតប្រាកដដែលបានចំណាយ។ ទិន្នន័យនេះនិងជួយផ្ទៀងផ្ទាត់គំលាតនៃការផ្តល់មូលនិធិសំរាប់វិស័យ និងត្រូវបានយកទៅប្រើប្រាស់សំរាប់ការរៀបចំក្របខណ្ឌ័ចំណាយសំរាប់រយៈពេលមធ្យម ការធ្វើផែនការប្រចាំឆ្នាំ និង ផែនការរំកិលបីឆ្នាំ។
- ផ្តល់ជាជំនួយក្នុងការធ្វើផែនការ និង ពិនិត្យតាមដានសកម្មភាព តំបន់គ្របដណ្តប់ និង សមិទ្ធិផលរបស់ស្ថាបន័ ឬ អង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តន៍គំរោង។ សកម្មភាពនេះនឹងជួយពិនិត្យតាមដានវឌ្ឍនភាពដែលស្ថាប័ន ឬ អង្គការក្រៅរដ្ឋាភិបាលបាន អនុវត្តន៍សកម្មភាព និង លទ្ធផលដែលសំរេចបាន លើកកំពស់ការរួបរួម ផ្ទៀងផ្ទាត់គំលាត នៃការអនុវត្តន៍គំរោង និងដើរតួជាធនធានចូលរួមចំណែកក្នុងដំណើរការធ្វើផែនការប្រចាំឆ្នាំ និង រំកិលបីឆ្នាំ។
- សំរបសំរួលការពិនិត្យសំណើគំរោងសុខាភិបាលរបស់ដៃគូរអភិវឌ្ឍន៍ដើម្បីធានាថាសំណើគំរោងទាំងអស់មានភាពសុខដុមនីយកម្មជាមួយគំនិតផ្តួចផ្តើមទាំងឡាយដែលរាជរដ្ឋាភិបាល និង ដៃគូរ

អភិវឌ្ឍន៍បានរៀបចំឡើងដោយស្របជាមួយគោលនយោបាយ ប្រពន្ធ័ និង អតិភាព នៃវិស័យសុខាភិបាលជាតិ ។

- កំណត់កាលានុវត្តភាពដើម្បីស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងលំហូរជំនួយអភិវឌ្ឍន៍ផ្លូវការចំពោះវិស័យសុខាភិបាល ជួយពង្រឹងការសំរបសំរួលភាគីផ្តល់ជំនួយ ដើម្បីឈានទៅរកការគ្រប់គ្រងទូលំទូលាយនៃវិស័យសុខាភិបាល ។ នេះរួមបញ្ចូលការផ្តល់មូលនិធិដែលបញ្ចូលគ្នា ឬ ការផ្តល់មូលនិធិដោយឡែក១ពីគ្នា ។
- ពិនិត្យតាមដានជំនួយបច្ចេកទេសរបស់ដៃគូរអភិវឌ្ឍន៍ដែលបានផ្តល់ក្នុងវិស័យសុខាភិបាល កិច្ចការនេះ នឹងជួយបង្កើតឡើងនូវកម្មវិធីមួយដែលដឹកនាំដោយរដ្ឋាភិបាល ដើម្បីប្រើប្រាស់ជំនួយបច្ចេកទេសឱ្យមានប្រសិទ្ធិភាពនិងមានការសំរបសំរួលល្អ និងការកំណត់សូចនករណ៏សំរាប់តាមដានវាស់ស្ទង់ដែលអាចប្រាប់ពីវឌ្ឍនភាពនៃ ការអភិវឌ្ឍន៍សមត្ថភាព
- តាមដាន និង ចូលរួមប្រសិនបើអាច ក្នុងបេសកម្មពិនិត្យឡើងវិញ ដែលអាចជួយលើកកំពស់កិច្ចសហការចំរុះ និងលើកំពស់ការសំរបសំរួលក្នុងវិស័យ
- ជាច្រកចូលសំរាប់ទំនាក់ទំនងដំបូងរបស់ក្រសួងសុខាភិបាល និងបំពេញជាមជ្ឈមណ្ឌលផ្តល់ពតិមាន ដល់ដៃគូរអភិវឌ្ឍន៍ដែលធ្វើការក្នុងវិស័យសុខាភិបាល
- បំពេញសកម្មភាពជាចំណុច កណ្តាល និង ចំណុចប្រសព្វ ក្នុងក្របខ័ណ្ឌក្រសួងសុខាភិបាល ក្នុងការពិគ្រោះកំណត់គោលនយោបាយ រវាង ក្រសួងសុខាភិបាល និងដៃគូរអភិវឌ្ឍន៍ ក្នុងការរៀបចំជាគំរោងកម្មវិធី ដៃជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងវិស័យសុខាភិបាល ។
- សំរបសំរួលក្នុងការផ្លាស់ប្តូរពតិមានដែលទាក់ទងទៅនឹងការសំរេចចិត្តដែលបានធ្វើ រវាងក្រសួងសុខាភិបាល និងដៃគូរអភិវឌ្ឍន៍សុខាភិបាល និងផ្តល់ពតិមានបច្ចុប្បន្នភាព នៃវឌ្ឍភាពរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល
- សំរបសំរួលទំនាក់ទំនងរវាង ក្រសួងសុខាភិបាល ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ និង ស្ថាប័នដទៃទៀតដែលពាក់ព័ន្ធជាមួយការសំរបសំរួលជំនួយអភិវឌ្ឍន៍ផ្លូវការសំរាប់វិស័យសុខាភិបាល វិភាគពតិមានហិរញ្ញវត្ថុរបស់ដៃគូរអភិវឌ្ឍន៍ និងចងក្រងឯកសារប៉ាន់ប្រមាណ លើការផ្តល់ហិរញ្ញវត្ថុ និង ការសន្យាផ្តល់ហិរញ្ញវត្ថុ ប្រចាំឆ្នាំ និងសំរាប់រយៈពេល៣ឆ្នាំ ចំពោះក្រសួងសុខាភិបាល ។

ការទទួលខុសត្រូវបឋមចំពោះ ភារកិច្ចសំរបសំរួលកិច្ចអភិវឌ្ឍន៍វិស័យសុខាភិបាល ត្រូវបានបែងចែកប្រគល់អោយការិយាល័យទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល ការិយាល័យសហប្រតិបត្តការ

ទ្វេភាគី ការិយាល័យសហប្រតិបត្តិការពហុភាគី ដោយមានការគាំទ្រពីការិយាល័យ អាស៊ាន ការិយាល័យរដ្ឋបាល និងពត៌មាន និងការិយាល័យទទួលជំនួយមូលនិធិសាកលសំរាប់កម្ពុជា។ ការគ្រប់គ្រងពត៌មានដែលទាក់ទងទៅនឹង ការផ្តល់ហិរញ្ញប្បទានរបស់ដៃគូរអភិវឌ្ឍន៍ និង ការធ្វើផែនទីសកម្មភាពរបស់ អង្គការក្រៅរដ្ឋាភិបាល នឹងបានបរិយាយក្នុងផ្នែក៣.៥ ស្តីពីការគ្រប់គ្រងពត៌មានជាយុទ្ធសាស្ត្រ។ អនុផ្នែកពីរខាងក្រោម នឹងផ្តោតទៅលើចំណុចការសំរបសំរួលដៃគូរអភិវឌ្ឍន៍:

-ខ្លឹមសាររបាយការណ៍ដែលតំរូវអោយទីភ្នាក់ងារអនុវត្តគំរោង និងអង្គការក្រៅរដ្ឋាភិបាលរាយការណ៍ជូនក្រសួងសុខាភិបាល

-ការគ្រប់គ្រងសំណើរគំរោងកម្មវិធីថ្មីៗដែលបានស្នើសុំដោយដៃគូរអភិវឌ្ឍន៍សុខាភិបាល

## ៣.១.១ តំរូវការរបាយការណ៍ចំពោះទីភ្នាក់ងារ ឬអង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តគំរោង

ទីភ្នាក់ងារ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុក ឬអន្តរជាតិដែលធ្វើការនៅក្នុងវិស័យសុខាភិបាល រួមទាំងការងារដែលទាក់ទងជាមួយផ្នែកហ៊ីវ-អេដស៍ ត្រូវរាយការណ៍ស្របតាមរយៈពេលកំណត់ជូនដល់ក្រសួងសុខាភិបាលស្របតាមវដ្តនៃការធ្វើផែនការ។ របាយការណ៍ត្រូវ ទំរង់ដែលប្រើប្រាស់រួម និងជាក់លាក់ ដែលផ្តល់ភាពងាយស្រួលក្នុងការពិនិត្យ រក្សាទុក និងផ្ទៀងផ្ទាត់ទៅតាមពេលវេលា ហើយទីភ្នាក់ងារអនុវត្តគំរោងត្រូវបានលើកទឹកចិត្តអោយផ្ញើរបាយការណ៍ ប្រចាំឆ្នាំ និងពត៌មានបន្ថែមដែលសមស្រប។

ទំរង់របាយការណ៍ប្រចាំឆមាសសំរាប់ទីភ្នាកងារអនុវត្តគំរោងមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៧។

## ៣.១.២ ការគ្រប់គ្រងសំណើគំរោងដៃគូរអភិវឌ្ឍន៍

ប្រព័ន្ធត្រួតពិនិត្យរវាងដៃគូរសំរាប់គំនិតផ្តួចផ្តើមសុខភាពថ្មីមួយ ត្រូវបានចែងក្នុងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការធ្វើសុខដុមរនីយកម្ម ការសំរបទិស និងលទ្ធផល។ ការបង្កើតឡើងនូវប្រព័ន្ធត្រួតពិនិត្យរវាងដៃគូរនឹងត្រូវការយ៉ាងហោចៈ

- កិច្ចព្រមព្រៀងលើដំណើរការត្រួតពិនិត្យ និង លក្ខខ័ណ្ឌក្នុងការត្រួតពិនិត្យ
- សមត្ថភាព និង ការជ្រើសរើសដៃគូរអ្នកត្រួតពិនិត្យ
- អាណាត្ត និងសិទ្ធអំណាចក្នុងការកែប្រែ និងបដិសេដសំណើគំរោង
- សក្តានុពលសំរាប់ជំលោះផលប្រយោជន៍

ប្រព័ន្ធត្រួតពិនិត្យដៃគូរមួយកន្លងមកសំរាប់សំណើគំរោងដែលទាក់ទងទៅនឹងសំណើគំរោងសុខាភិបាលទៅមូលនិធិសាកល ត្រូវបានបង្កើតឡើងដោយយន្តការសំរបសំរួលរបស់ប្រទេសដែលត្រូវបានស្គាល់ថាជា CCM

របស់កម្ពុជា។ សមាសភាគនៃសំណើគំរោងកំពុងត្រូវបានពិនិត្យដោយដៃគូរ និងត្រូវបានពិនិត្យជាថ្មីដោយមន្ត្រីបច្ចេកទេសដែលបានជ្រើរើសពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សហគមន៍អ្នកផ្តល់ជំនួយ និងទីប្រឹក្សាឯករាជ្យ។ មតិ និងអនុសាសន៍របស់អ្នកត្រួតពិនិត្យ ត្រូវបានបញ្ចូល ទៅក្នុងការរៀបចុងក្រោយនៃសំណើគំរោង ដែលត្រូវបានសំរបសំរួលដោយ CCC ដោយនាំដល់ការពិនិត្យឡើងវិញ សមាសភាគ ឬ អនុសមាសភាគ ឬក៏អាចត្រូវបានដកចេញពីសំណើគំរោងចុងក្រោយ។ ដំណើរពិនិត្យដោយដៃគូរដូចគ្នាមួយត្រូវបានបង្កើតឡើងក្រោមការសំរបសំរួលរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិដើម្បីពិនិត្យមើលសំណើគំរោងក្នុងវិស័យសុខាភិបាល។

ជំរើសមួយដើម្បីត្រួតពិនិត្យដោយដៃគូរចំពោះសំណើគំរោងត្រូវឆ្លងកាត់ដំណើរការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងឡាយ។ នេះអាចរួមមានការប្រជុំពិគ្រោះជាតំណាក់ជាមួយមន្ត្រីក្រសួងសុខាភិបាលសំខាន់ៗមួយចំនួនដែលរួមមាន យ៉ាងហោចនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានផែនការ និងពតិមានសុខាភិបាល និងជាមួយនាយកដ្ឋាន និង ឬ កម្មវិធីជាតិណាមួយដែលពាក់ព័ន្ធជាមួយសំណើគំរោង (ឧទាហរណ៏: MCH HIV/AIDS ជាដើម) ។ ការពិគ្រោះយោបល់គួត្រូវបានធ្វើឡើងដោយសមស្របជាមួយជាមួយដៃគូរអភិវឌ្ឍន៍សុខាភិបាលដទៃទៀត។ លទ្ធផលនៃការពិគ្រោះយោបល់ទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងការរៀបចំ និងពិនិត្យឡើងវិញនៃសំណើគំរោង។ ប្រសិនបើចាំបាច់សំណើគំរោងអាចត្រូវបានដាក់ឆ្លងក្រុមការងារបច្ចេកទេសសុខាភិបាល ឬក៏ក្រុមដៃគូរសុខាភិបាលដើម្បីមានមតិ ឬ ការឆ្លើយតបបន្ថែម។

សំណើគំរោងទាំងឡាយដែលត្រូវបានរៀបចំនៅខាងក្រៅមិនត្រូវបានពិនិត្យ ឬ ពិគ្រោះដោយដៃគូរទេ វាត្រូវបានដំណើការតាមនិតិវិធីដូចតទៅ:

ឯកសារបញ្ជាក់ពីគោលបំណងត្រូវបានដាក់ជូននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អង្គប្រជុំដៃគូរសុខាភិបាលដើម្បីទទួលមតិ ឬ ការឆ្លើយតបចំពោះគំនិតផ្តួចផ្តើមគំរោងកំរិតជាតិហើយប្រតិបត្តិនៅក្នុងខេត្ត លើសពីមួយ ឬ ក៏មានថវិការលើសពី ៣០០០០ដុល្លារ។ ឯកសារបញ្ជាក់ពីគោលបំណងត្រូវលើកឡើងលើចំណុចគំនិតសំខាន់ៗជាមួយនិងពតិមាន ភូមិសាស្ត្រ ពេលវេលា និង ថវិកា[៣]។

ចំពោះគំនិតផ្តួចផ្តើមគំរោងដែលគ្រោងអនុវត្តន៏នៅកំរិតមូលដ្ឋានក្នុងខេត្តតែមួយហើយថវិកាតិចជាង ៣០០០០ដុល្លារត្រូវដាក់ជូនមន្ទីរសុខាភិបាលខេត្ត និង ឬក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តដើម្បីពិនិត្យ និងផ្តល់យោបល់។ អនុសាសន៍ចំពោះសំណើគំរោងដែលធ្វើឡើងដោយមន្ទីរសុខាភិបាលខេត្ត និង ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តត្រូវដាក់ជូននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិភ្លាមៗ។ សំណើគំរោងតំរូវឱ្យមានលិខិតគាំទ្រមួយពីមន្ទីរសុខាភិបាលខេត្ត-ក្រុង។

[3] ទំរង់នៃលិខិតគាំទ្រមានភ្ជាប់ជូននៅឧបសម្ព័ន្ធទី ៤

## ៣.២ ការសំរបសំរួលកិច្ចការសុខាភិបាលអាស៊ាន

ភារកិច្ចសំរបសំរួលកិច្ចការសុខាភិបាលអាស៊ានទទួលបន្ទុកដោយការិយាល័យកិច្ចការអាស៊ានដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ ដោយទទួលខុសត្រូវក្នុងនាមក្រសួងសុខាភិបាលចំពោះការសំរបសំរួលកិច្ចការអាស៊ានទាំងអស់ជាមួយអគ្គនាយកដ្ឋានកិច្ចការអាស៊ាននៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

ការិយាល័យកិច្ចការអាស៊ានមានភារកិច្ចចំបងពីរ:

**ក**.សំរបសំរួលកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល និង

**ខ**.ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងវិស័យសុខាភិបាល

សំរបសំរួលកិច្ចសហប្រតិបត្តិការពាក់ព័ន្ធជាមួយការសំរបសំរួលរាល់បញ្ហាសុខាភិបាលក្នុងតំបន់អាស៊ាន ។ យន្តការសំរបសំរួលរួមបញ្ចូលក្រុមឯកទេសនៃជំងឺឆ្លង និង សុវត្ថិភាពម្ហូបអាហារ និង ក្រុមការងារជំងឺ AIDS និងឱសថ ។ នៅកម្ពុជាក្រុមនេះស្ថិតនៅក្រោមការអភិបាលរបស់អគ្គនាយករងបច្ចេកទេសសុខាភិបាល និងជាអ្នកសំរបសំរួលកិច្ចប្រជុំផ្លូវការនៃមន្ត្រីជាន់ខ្ពស់អាស៊ានលើការអភិវឌ្ឍន៍លើវិស័យសុខាភិបាល ។

អាស៊ានមានដៃគូរមួយចំនួនដូចជាម្ចាស់ជំនួយទ្វេភាគី ពហុភាគី រួមបញ្ចូល EU, WHO, UNAIDS, USAID, Canada, Japan, NZ, Republic of Korea, Australia and India ដែលផ្តល់ការគាំទ្រហិរញ្ញវត្ថុ និង បច្ចេកទេសដល់បណ្តាប្រទេសអាស៊ានសំរាប់ជំងឺ AIDS និង ជំងឺលេចធ្លោរដ៏ទៃទៀត ។

ភារកិច្ចគន្លឹះរបស់ការិយាល័យអាស៊ាន គឺការពិនិត្យផែនការសកម្មភាពរបស់ដៃគូរសន្ទនារ ដែលរួមបញ្ចូលការប្រមូល និង ចងក្រងយោបល់ឆ្លើយតប និង ទិន្នន័យពីកម្មវិធីជាតិ ឬ នាយកដ្ឋានហើយផ្ញើរទៅដៃគូរសន្ទនារតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង អគ្គលេខាធិការដ្ឋានអាស៊ាននៅទីក្រុងហ្សាកាតា ។

សមាហរណកម្មសេដ្ឋកិច្ច ការិយាល័យអាស៊ានមានតួនាទីសំខាន់ចាប់ពីឆ្នាំ២០០២មកដោយបំណង នៃសមាហរណកម្មគឺសំរេចឱ្យបានលំហូរសេវា និង ផលិតផលសុខាភិបាលដោយសេរីក្នុងតំបន់អាស៊ានត្រឹមឆ្នាំ២០១០ ។ តួនាទីនេះមានការកើនឡើងគួឱ្យកត់សំគាល់ចាប់ពីឆ្នាំ២០០៤មកនៅពេលដែលការថែទាំសុខភាពក្លាយជាវិស័យអតិភាពសំរាប់សមាហរណកម្មសេដ្ឋកិច្ច ។

សមាហរណកម្មសេដ្ឋកិច្ចគឺជាភារកិច្ចគន្លឹះមួយរបស់ការិយាល័យអាស៊ានដែលរួមមានការបង្កើតយន្តការនិយ័តកម្ម និង សំរបសំរួលដើម្បីឱ្យស្របទៅនឹងតំរូវការ និង ការការពារផលប្រយោជន៍នៃប្រទេសសមាជិកនិមួយៗ ។

ការងារសមាហរណកម្មសេដ្ឋកិច្ចរួមមានពិនិត្យច្បាប់និងនិយ័តកម្មដែលទាក់ទងទៅនឹងដំណើរការ សេរីភាវូបនីយ-កម្ម នៃសេវាថែទាំសុខភាព រួមជាមួយការកាត់បន្ថយអត្រាពន្ធ និង សុខដុនីយកម្មសំរាប់ផលិតផលថែទាំសុខភាព ។

សកម្មភាពកំណត់នៃការិយាល័យអាស៊ានរួមមាន តែមិនកំរិតដាច់ខាត:

- ទំនាក់ទំនងជាមួយស្ថាបន័ នាយកដ្ឋាន និង កម្មវិធីនានាក្រោមឳវាទក្រសួងសុខាភិបាល ដើម្បីប្រមូលពតិមានសំខាន់ៗ និង ផ្តល់អនុសាសន៏កិច្ចការដែលទាក់ទងនឹងអាស៊ាន ។
- ពិនិត្យផែនការសកម្មភាពរបស់ដៃគូសន្ទនាដែលផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដល់ប្រទេសសមាជិកអាស៊ាន ។
- ពិនិត្យច្បាប់ និង បទដ្ឋានរបស់ប្រទេស តំបន់ និង អន្តរជាតិ ដែលទាក់ទងទៅនឹងតំណើការសេរីភាវូបនីយកម្ម ថែទាំសុខភាព រួមជាមួយការកាត់បន្ថយអត្រាពន្ធ និង សុខដុនីយកម្ម សំរាប់ផលិតផលថែទាំសុខភាព ។
- ចងក្រង និងគ្រប់គ្រងទិន្នន័យសហប្រតិបត្តិការសុខាភិបាលអាស៊ាន និងបំពេញភារកិច្ចជាមណ្ឌលរក្សាឯកសារ និង ពតិមានពាក់ពន្ធ័សុខាភិបាលអាស៊ានរបស់ក្រសួងសុខាភិបាល ។
- ផ្សព្វផ្សាយពតិមានអាស៊ានឱ្យបានសមស្របដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹង និង ធ្វើការសំរេចចិត្តលើសកម្មភាពអាស៊ានដោយមន្ត្រី និង ស្ថាបន័សុខាភិបាល ។ រៀបចំសេចក្តីព្រាងច្បាប់ និង គោលនយោបាយសុខាភិបាលសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដោយសហការយ៉ាង ជិតស្និតជាមួយនាយកដ្ឋាន កម្មវិធី និង ស្ថាប័នពាក់ពន្ធ័
- ចូលរួមក្នុងយន្តការសំរបសំរួលស្តីពីបញ្ហាសុខាភិបាលដោយរួមបញ្ចូលក្រុមឯកទេស និង ក្រុមការងារដើម្បីធានាឱ្យមានតំណើការសហប្រតិបត្តិការនៃដៃគូសុខាភិបាលក្នុងតំបន់អាស៊ាន
- ចូលរួមក្នុងកិច្ចប្រជុំសិក្ខាសាលាផ្សេងៗដែលពាក់ពន្ធ័សុខាភិបាលអាស៊ានក្នុងកំរិតជាតិ និង ក្នុងកំរិតតំបន់
- បំពេញភារកិច្ចជាលេខាធិការដ្ឋានក្នុងការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកិច្ចប្រជុំជាន់ខ្ពស់ផ្សេងៗ ដែលពាក់ពន្ធ័និងកិច្ចការសុខាភិបាលអាស៊ានដោយសហការជាមួយអគ្គលេខាធិការដ្ឋានអាស៊ាន នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមដាន វាយតំលៃ និង ផ្តល់របាយការណ៏សរសេរអំពីសហប្រតិបត្តិការអាស៊ានរបស់ស្ថាប័នសុខាភិបាលក្នុងកំរិតជាតិ និង តំបន់
- រៀបចំផែនការយុទ្ធសាស្ត្រ ពីរយៈពេលមួយ ទៅរយៈពេលមួយសំរាប់កិច្ចសហប្រតិបត្តិការសុខាភិបាលអាស៊ាន និង ធានាថាយុទ្ធសាស្ត្រទាំងនោះត្រូវបានបញ្ចូលទៅក្នុងការកសាងផែនការប្រចាំឆ្នាំ និង បីឆ្នាំរំកិលដែលមានលក្ខណៈទូលំទូលាយ

- ទំនាក់ទំនង និង សំរបសំរួលជាមួយនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង នាយកដ្ឋានអាស៊ាន និង អង្គការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ដើម្បីរក្សាទុកឯកសារ និង អនុវត្តន៍កិច្ចព្រមព្រាងដែលទាក់ទង និង ជាមួយសេវា និង ផលិតផលរង្វាងប្រទេសសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ប្រទេសដៃគូអាស៊ាន និងរដ្ឋសមាជិកអាស៊ាន
- ពិនិត្យច្បាប់បទដ្ឋានសំរាប់សេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និង ជួយក្នុងការបង្កើតយន្តការសំរបសំរួល និង និយ័តកម្មសំរាប់សមាហរណកម្មសេដ្ឋកិច្ចនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន

## ៣.៣ ការសំរបសំរួលសហប្រតិបត្តិការអន្តរជាតិនៃវិស័យសុខាភិបាល និងទំនាក់ទំនងសាធារណៈ

ភារកិច្ចនេះជាការងាររដ្ឋបាលភាគច្រើនដែលអាចបែងចែកជា៥ផ្នែកធំៗ : ទំនាក់ទំនងអន្តរជាតិ ការទទួលខុសត្រូវពិធីការ ការសំរបសំរួល និង ទ្រទ្រង់ចំពោះទស្សនកិច្ចរបស់ប្រតិភូបរទេស និង ភ្ញៀវ ទ្រទ្រង់ទស្សនកិច្ច ឬបេសកម្មរបស់មន្ត្រីក្រសួងសុខាភិបាលទៅក្រៅប្រទេស និង ទទួលទំនិញដែលជាអំណោយផ្សេងៗ ការសំរបសំរួលមួយភាគធំស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ការិយាល័យទំនាក់ទំនងសាធារណ ពតិមាន និង រដ្ឋបាល ។

សកម្មភាពរបស់នាយកដ្ឋានលើផ្នែកសំរបសំរួលចំពោះទំនាក់ទំនងសាធារណៈដែលទាក់ទងការងារសុខាភិបាល និង សហប្រតិបត្តិការអន្តរជាតិមានដូចខាងក្រោម តែមិនកំណត់ដាច់ខាតនោះទេ:

- សំរបសំរួលកម្មវិធី និង ការវិភាគទស្សនកិច្ចជូនគណប្រតិភូបរទេស ទទួលគណប្រតិភូ និង អមដំណើរគណប្រតិភូដែលចុះទស្សនកិច្ចមូលដ្ឋានប្រសិនបើចាំបាច់
- សំរបសំរួលការរៀបចំនៃដំណើរទស្សនកិច្ចជាន់ខ្ពស់ទៅកាន់គំរោងដែលគាំទ្រដោយមូលនិធិពីខាងក្រៅ
- ភ្ជាប់ទំនាក់ទំនងជាមួយក្រសួងការបរទេស និង ស្ថានទូត លើកិច្ចសហប្រតិបត្តិការសុខាភិបាល
- តាមដានពតិមានទេសចរណ៍ និង រៀបចំរបាយការណ៍អំពីការវិវឌ្ឍន៍នៃកិច្ចការទេសចរណ៍ជូនការិយាល័យផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំបែបបទឯកសារ និង ជួយសំរបសំរួលទស្សនកិច្ចក្រៅប្រទេស របស់មន្ត្រីក្រសួងសុខាភិបាលដែលអញ្ជើញចូលរួមក្នុងសិក្ខាសាលា សន្និសិត ទស្សនកិច្ចសិក្សា ។ល។ ដោយរួមទាំងរៀបចំឯកសារធ្វើដំណើរ លិខិតឆ្លងដែន ទិដ្ឋការ និង ការអនុញ្ញាត្តិដោយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ទទួល និង បែងចែកលិខិត ឬ ឯកសារអន្តរជាតិ និង ផ្តល់ដំបូលមានជូននាយកដ្ឋាន និងកម្មវិធីផ្សេងទៀតតាមដែលចាំបាច់

- ធានាទំនាក់ទំនងសាធារណជាមួយស្ថាប័ន និង ក្រសួងផ្សេងៗដើម្បីធានាកិច្ចសហប្រតិបត្តិការ អន្តរនាយកដ្ឋាន និង អន្តរក្រសួងឱ្យមានប្រសិទ្ធភាព
- រៀបចំសំរបសំរួលការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយក្រៅប្រទេសរវាងក្រសួង សុខាភិបាល និង ដៃគូអភិវឌ្ឍន៍
- រៀបចំសំរបសំរួលកិច្ចប្រជុំរវាងមន្ត្រីជាន់ខ្ពស់ជាមួយគណប្រតិភូជាន់ខ្ពស់នានា
- ផ្តល់ការគាំទ្រដែលចាំបាច់ជូនទីភ្នាក់ងារអន្តរជាតិក្នុងការនាំចូលមុខទំនិញជាអំណោយ និង សំភារៈគំរោង ។

## ៣.៤ សំរបសំរួលក្រុមការងារបច្ចេកទេសសុខាភិបាល និង ការទទួលខុសត្រូវរបស់ក្រុមការងារ បច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចរៀបចំ និង ធានាឱ្យលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសសុខាភិបាលបំពេញមុខងារប្រកបដោយប្រសិទ្ធភាពដោយរួមបញ្ចូល ការរៀបចំការប្រជុំជាទៀងទាត់របស់ក្រុមការងារបច្ចេកទេសសុខាភិបាលលើផ្នែកកិច្ចសហប្រតិបត្តិការសុខាភិបាលជាមួយអន្តរជាតិ ។ ភារកិច្ចនេះរួមបញ្ចូលការរៀបចំ និង គ្រប់គ្រងរបៀបវារៈ និងកំណត់ហេតុនៃអង្គប្រជុំនៃក្រុមការងារបច្ចេកទេសសុខាភិបាល និង អនុក្រុម និង តាមដានក្នុងក្របខណ្ឌក្រសួងសុខាភិបាល និង ទីភ្នាក់ងារដែលទទួលខុសត្រូវបំពេញសកម្មភាពដែលបានព្រមព្រាង ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចផងដែរក្នុងការធានាឱ្យមានទំនាក់ទំនងប្រតិបត្តិ រវាងក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ក្រសួង និង ខេត្តតាមរយៈការបង្កើតឱ្យមានយន្តការរាយការណ៍ និងផ្តល់ពត៌មានត្រឡប់ ។

### ៣.៤.១ ក្រុមការងារបច្ចេកទេសសុខាភិបាល

មុខងារចំបងរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលគឺធានាឱ្យមានការសំរបសំរួលដែលមានប្រសិទ្ធភាពដែលជាការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដឹកនាំដោយក្រសួងសុខាភិបាលទៅនឹងកិច្ចការប្រឈមនានាក្នុងវិស័យសុខាភិបាលនៅកម្ពុជា ។ ក្រុមការងារបច្ចេកទេសសុខាភិបាលបង្កើតជាយន្តការសំរបសំរួលរួមរវាងក្រសួងសុខាភិបាល និង ដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យកំណត់អតិភាព ធ្វើសុខដុមនីយកម្មសកម្មភាព ពិភាក្សា និងដោះស្រាយបញ្ហាបច្ចេកទេស ធ្វើឱ្យប្រសើរឡើងការប្រើប្រាស់ និងគៀងគរធនធាន និងសំរបសំរួលការពិនិត្យតាមដានចំពោះវឌ្ឍនភាព ។

សកម្មភាពរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលនឹងទ្រទ្រង់កម្ពុជាឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សតាមរយៈការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការអភិវឌ្ឍន៍ជាតិនានាក្នុងពេលបច្ចុប្បន្ន និងផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្ររបស់ជាតិ២០០៦-២០១០ ។ ក្រុមការងារបច្ចេកទេសសុខាភិបាល

ជួយកំណត់គោលដៅនៃគោលនយោបាយឱ្យមានលក្ខណៈប្រាកដនិយមជូនក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល ដើម្បីធ្វើការសំរេចចិត្ត ។

ក្រុមការងារបច្ចេកទេសសុខាភិបាល និងសំរបសំរួលការអនុវត្តន៍ តាមដាន និង វាយតំលៃ និងប្រសិនបើ ចាំបាច់ធ្វើការកែតំរូវផែនការយុទ្ធសាស្ត្រសុខាភិបាលឱ្យមានភាពប្រទាក់ក្រឡាជាមួយយុទ្ធសាស្ត្រ និងក្រុមការងារ បច្ចេកទេសវិស័យផ្សេងទៀតតាមតំរូវការ ។ ក្រុមការងារបច្ចេកទេសសុខាភិបាល និងជួយភាគីពាក់ពន្ធ័ចូលរួម ឱ្យបានពេញលេញក្នុងការពិគ្រោះពិភាក្សាបញ្ហានានាក្នុងរង្វង់ទទួលខុសត្រូវរបស់ខ្លួន[៤] ។

គណកម្មការសំរបសំរួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយមានភារកិច្ចសំរបសំរួលការងាររបស់ក្រុមការងារ បច្ចេកទេសនៃវិស័យទាំងអស់ ហើយរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ពិនិត្យតាមដានវឌ្ឍនភាពរបស់បញ្ហាគន្លឹះនានា ។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានភារៈកិច្ច រៀបចំរបាយការណ៍វឌ្ឍនភាពដើម្បីផ្សព្វផ្សាយ និង ផ្ញើរជូន គណៈកម្មការសំរបសំរួលរវាងរដ្ឋាភិបាលនិងម្ចាស់ជំនួយតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាលេខាធិកា-រដ្ឋាន និងលើកបញ្ហាជូនដើម្បីដោះស្រាយ ។

<u>សកម្មភាពរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្នុងការទទួលខុសត្រូវចំពោះលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសសុខាភិបាលរួមមានដូចខាងក្រោម តែមិនកំណត់ដាច់ខាតៈ</u>

- រៀបចំរបៀបវារអង្គប្រជុំ និង រក្សាទុកដាក់ជាឯកសាររៀបចំកំណត់ហេតុអង្គប្រជុំ និង ផ្សព្វផ្សាយ ឬ បែងចែក ។
- តាមដានការសំរេចចិត្តដែលធ្វើឡើងដោយអង្គប្រជុំ
- សំរបសំរួលការរៀបចំផែនការការងាររបស់ក្រុមការងារបច្ចេកទេសសុខាភិបាលប្រចាំឆ្នាំ
- គាំទ្រការអនុវត្តន៍ផែនការការងារប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល
- ទំនាក់ទំនងជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីធានាឱ្យការរៀបចំរបាយការណ៍វឌ្ឍនភាព ដែលមានប្រសិទ្ធភាពស្តីពីការបំពេញមុខងាររបស់ក្រុមការងារបច្ចេកទេសសុខាភិបាល ដើម្បី បែងចែក និង ផ្ញើរជូនគណកម្មការសំរបសំរួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ ។

### ៣.៤.២ ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត

មុខងារចំបងរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្តទាំង២៤គឺជួយសំរបសំរួលការ អភិវឌ្ឍន៍ ទូទៅនៃសេវាសុខាភិបាលនូវថ្នាក់ខេត្ត និងធានាការប្រើប្រាស់ធនធានរបស់ខេត្តដែលមានទាំងអស់ប្រកបដោយ ប្រសិទ្ធភាពតាមរយៈសកម្មភាពរបស់ដៃគូទាំងឡាយដែលមានការសំរបសំរួលបានល្អដើម្បីគាំទ្រការអនុវត្តន៍ គោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាលជាតិ និងផែនការរបស់ខេត្ត។ យន្តការចំបងនៃមុខងាររបស់ ក្រុម

---

[៤] ខងារ និង តួនាទីនៃក្រុមការងារបច្ចេកទេសសុខាភិបាលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី២

ការងារបច្ចេកទេសថ្នាក់ខេត្ត[5] គឺការប្រជុំប្រចាំខែដែលរៀបចំដោយ មន្ទីរសុខាភិបាលខេត្តដោយមានការចូលរួមរបស់ដៃគូររដ្ឋាភិបាល និង ក្រៅរដ្ឋាភិបាលផ្សេងទៀតដែល បំពេញការងារនៅក្នុងខេត្ត ។

ទំនាក់ទំនងរវាង ក្រុមការងារបច្ចេកទេសសុខាភិបាលក្រសួង និងខេត្ត ធ្វើឡើងតាមរយៈរបាយការណ៍ប្រចាំត្រីមាសដែលលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្តផ្ញើរជូន លេខាធិការដ្ឋានថ្នាក់ក្រសួង និងថ្នាក់ក្រសួងផ្ញើរជូនថ្នាក់ខេត្តពត៌មានត្រលប់មកថ្នាក់ខេត្តវិញ ។ របាយការប្រចាំត្រីមាសត្រូវរួមបញ្ចូលពត៌មានៈ

**ក**-ចំនួននៃកិច្ចប្រជុំប្រចាំត្រីមាសរបស់ ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត

**ខ**-ចំនួន និងភាគរយនៃវត្តមានចូលរួមប្រជុំ របស់ដៃគូរអភិវឌ្ឍន៍សុខាភិបាលរួមទាំងអង្គក្រៅរដ្ឋាភិបាល

**គ**-ចំនួន និងភាគរយនៃដៃគូរសុខាភិបាលដែលសកម្មក្នុងខេត្តហើយបានចូលរួមប្រជុំតាមដាន ការអនុវត្តន៍ផែនការប្រតិបត្តិ និងការចូលរួមក្នុងការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ ។

**ឃ**-បញ្ហាគន្លឹះសំខាន់ៗ ដែលបាន លើកឡើង និងដោះស្រាយក្នុងត្រីមាស រួមទាំងលទ្ធផលសំរេចបាន និងមេរៀនដែលគួររៀនសូត្រ ។

**ង**-ស្ថានភាពអនុវត្តថវិការបស់ខេត្ត

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ពិនិត្យរបាយការណ៍ និងបញ្ហាគន្លឹះរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត និងជួយរៀបចំផ្តល់ពត៌មានត្រលប់ជូនលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តវិញ ។ ដំណើរការប្រព្រឹត្តទៅអាចត្រូវបានបង្ហាញតាមគំនូសដូចតទៅៈ




[5] មុខងារ និងតួនាទីរបស់ ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធទី៣

សកម្មភាពរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្នុងកាទទួលខុសត្រូវលើក្រុមការងារបច្ចេកទេស សុខាភិបាល ខេត្ត រួមមាន ដូចខាងក្រោម តែមិនត្រូវបានកំរិតដាច់ខាតនោះទេះ

- ពិនិត្យរបាយការប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត និង ដាក់ជូនលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តក្រសួង និងតាមដានបញ្ហាដែលបានរាយការណ៍ក្នុងរបាយការណ៍ត្រីមាសមុនៗ ។
- ចងក្រងពត៌មានដែលបានផ្តល់ដោយ នៃត្រីមាសនីមួយៗ និង តាមដានបញ្ហាគន្លឹះនានាជាមួយខេត្ត ។
- ក្នុងនាមក្រុមការងារបច្ចេកទេសសុខាភិបាលក្រសួង ចងក្រង និងផ្តល់ពត៌មានត្រលប់ជូនក្រុមការងារ បច្ចេកទេសសុខាភិបាលខេត្ត ដោយសហការជាមួយនាយកដ្ឋាននានា និង កម្មវិធីជាតិ នានា ។
- ចូលរួមក្នុងកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត ផ្អែកតាមតំរូវការជាក់ស្តែង ក្នុងករណីដែល មានប្រធានបទសំខាន់ ឬ ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តបំពេញមុខងារ មិនទាន់បានពេញលេញ ។ តាមដែលអាចធ្វើបាន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ គួរចូលរួម យ៉ាងហោចអោយបានម្តងក្នុង មួយឆ្នាំក្នុងកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តនីមួយៗ ។

## ៣.៥ ការគ្រប់គ្រងពត៌មានជាយុទ្ធសាស្ត្រ

មុខងារគន្លឹះរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្នុងការគ្រប់គ្រងពត៌មានពាក់ព័ន្ធជាមួយះ

- ការសំរបសំរួលម្ចាស់ជំនួយ រួមទាំងមូលនិធិដែលត្រូវបានសន្យា មូលនិធិដែលបាន់ប្រមាណមូលនិធិដែល ត្រូវបានប្រើប្រាស់រួចហើយដោយម្ចាស់ជំនួយ និងទីភ្នាក់ងារអនុវត្តគំរោង ។ ពត៌មានទាំងនេះនឹងត្រូវបានបញ្ចូល ទៅក្នុងក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម ផែនការប្រចាំឆ្នាំ និង ផែនការវិកិលពាឆ្នាំ ។
- ធ្វើកំណត់ត្រា រាយការណ៍សកម្មភាព តំបន់គ្របដណ្តប់ និងលទ្ធផលសំរេចបានរបស់ទីភ្នាក់ងារអនុវត្ត គំរោង ។ ពត៌មានទាំងនេះនឹងសំរួល ក្នុងការសំរបសំរួល តាមដានទីភ្នាក់ងារអនុវត្តគំរោង ។
- គ្រប់គ្រង និងថែទាំ វេបសាយក្រសួងសុខាភិបាល ។ វេបសាយក្រសួងសុខាភិបាល នឹងមានសារៈសំខាន់ជា ប្រភពពត៌មានគន្លឹះនៃឯកសារចប្ចុប្បន្ន និងឯកសារនានានៃសមិទ្ធិផលវិស័យសុខាភិបាល ដែលសំរេចបាន ។

### ៣.៥.១ ក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវបានផ្តល់ភារកិច្ចជូនក្នុងការសំរបសំរួលក្នុងការរៀបចំឯកសារ ក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមសំរាប់វិស័យសុខាភិបាល ។ ក្របខ័ណ្ឌផែនការចំណាយសំរាប់ រយៈពេលមធ្យមជាផែនការចំណាយសាធារណៈច្រើនឆ្នាំ ដែលផ្អែកលើតំរូវការហិរញ្ញប្បទានសំរាប់វិស័យ សុខាភិបាល និងការប៉ាន់ប្រមាណប្រភពធនធានដែលមាន ក្នុងប្រទេស និង ពីក្រៅប្រទេស ។ វាជាឧបករណ៍ដើម្បី

ផ្តល់ពត៌មានសំរាប់ធ្វើការសំរេចចិត្តក្នុងការបែងចែកធនធានជាអតិភាព ទាំងក្នុងវិស័យសុខាភិបាល និងវិស័យដទៃៗផ្សេងទៀត ។

ក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម ក្នុងវិស័យសុខាភិបាល ផ្សំឡើងដោយសមាសភាគ៣:

1) ការប៉ាន់ប្រមាណនៃ តំរូវការ និងតំលៃ សំរាប់រយះពេល៣ឆ្នាំខាងមុខ( ផែនការប្រតិបត្តិប្រចាំឆ្នាំ និងតំលៃ ដែលត្រូវការ និងផែនការ៣ឆ្នាំរំកិល) ។
2) ការប៉ាន់ប្រមាណមូលនិធិដែលផ្តល់ដោយរាជរដ្ឋាភិបាលសំរាប់រយះពេល៣ឆ្នាំបន្ទាប់ (កញ្ចប់ថវិកា និង ការធ្វើរៀបចំថវិកាជាយុទ្ធសាស្ត្រ) ។
3) សំរាកការប៉ាន់ប្រមាណនៃការផ្តល់ហិរញ្ញវត្ថុពីខាងក្រៅសំរាប់រយះពេល៣ឆ្នាំបន្ទាប់ (ម្ចាស់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល) ។

ចំពោះសមាសភាគទី៣ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នឹងធានាការកត់ត្រា ពត៌មានបច្ចុប្បន្នភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការទាំងអស់សំរាប់វិស័យសុខាភិបាល ។ ដើម្បីការងារធ្វើផែនការនិងរៀបចំក្របខ័ណ្ឌផែនការចំណាយសំរាប់រយះពេលមធ្យម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវផ្តោតការយកចិត្តប្រមូលពត៌មានស្តីពីមូលនិធិប៉ាន់ស្មានដែលនឹងត្រូវផ្តល់ដោយភាគីម្ចាស់អំណោយសំខាន់ៗ និង ទីភ្នាក់ងារ ឬអង្គការដែលអនុវត្តគំរោងធំៗក្នុងវិស័យសុខាភិបាល ។ វាមានសារសំខាន់ណាស់ដែលទីភ្នាក់ងារ ឬអង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តគំរោង បញ្ជាក់បែងចែកប្រភពមូលនិធិ ផ្ទាល់របស់ខ្លួន ពីមូលនិធិ ដែលផ្តល់ដោយម្ចាស់អំណោយ ដើម្បីចៀសវាងការរាប់ធនធានទ្វេដង ។

### ៣.៥.២ ការគ្រប់គ្រងទិន្នន័យ

បច្ចុប្បន្នមានយន្តការបួនដែលអាច ដឹងទិន្នន័យស្តីពី ការផ្តល់មូលនិធិដោយម្ចាស់អំណោយ និងអង្គការក្រៅរដ្ឋាភិបាលសំរាប់វិស័យសុខាភិបាល:

i. កំរងសំនួរសំរាប់ប្រមូលទិន្នន័យដើម្បីរៀបចំក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម ដែលបានផ្ញើរជូនម្ចាស់អំណោយ និង អង្គការក្រៅរដ្ឋាភិបាលផ្នែកសុខាភិបាល
ii. ប្រព័ន្ធទិន្នន័យតាមរយៈបណ្តាញ Internet ដែលរៀបំបង្កើតឡើង និងគ្រប់គ្រងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
iii. ប្រព័ន្ធទិន្នន័យអង្គការក្រៅរដ្ឋាភិបាលដែល ដែលរៀបំបង្កើតឡើង និងគ្រប់គ្រងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
iv. ប្រព័ន្ធទិន្នន័យអង្គការក្រៅរដ្ឋាភិបាលដែលរៀបំបង្កើតឡើង និងគ្រប់គ្រងដោយ អង្គការមេឌីខាំ ។

ប្រភពទិន្នន័យទាំងនេះត្រូវបានបញ្ជាក់ដូចតទៅ:

កំរងសំនួរសំរាប់ប្រមូលទិន្នន័យ ពាកលព័ន្ធនឹងក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមបច្ចុប្បន្ន កំពុងត្រូវបានបែងចែកជូនទៅម្ចាស់ជំនួយ និងទីភ្នាក់ងារ ឬអង្គការក្រៅរដ្ឋាភិបាលដែលកំពុងអនុវត្តគំរោង ក្នុងវិស័យសុខាភិបាល ។ កំរងសំនួរត្រូវការកែលំអរបន្ថែមទៀត ព្រោះថាអត្រាឆ្លើយតបមានកំរិតទាបទោះបីជាម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលធំៗមួយភាគធំបានផ្ញើរត្រលប់មកវិញកំរងសំនួរដែលបពេញរួច ហើយក៏ដោយ ។

បន្ថែមលើកំរងសំនួរខាងលើ ម្ចាស់ជំនួយ ទ្វេភាគី ពហុភាគីទាំងអស់បានផ្តល់ពតិមានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៏ និងស្ថាវនិតិសម្បទាកម្ពុជាដែលជាប្រភព ពតិមានបឋមស្តីពីជំនួយអភិវឌ្ឍន៏ផ្លូវការចំពោះកម្ពុជា។ ប្រព័ន្ធទិន្នន័យនេះជាប្រព័ន្ធទិន្នន័យបើកចំហរដែលអាចដកស្រង់ទិន្នន័យបានតាមរយៈអាស័យដ្ឋាន htpp://cdc.khmer.biz ហើយដៃគូរអភិវឌ្ឍន៏អាចបញ្ចូលទិន្នន័យរបស់ខ្លួនបានគ្រប់ពេលវេលា តាមរយៈលេខសំងាត់ដែលបានផ្តល់អោយ។ មានប្រព័ន្ធទិន្នន័យមួយសំរាប់អង្គការក្រៅរដ្ឋាភិបាលដាច់ដោយឡែកពីប្រព័ន្ធទិន្ននិ័យម្ចាស់ជំនួយ ។ ប្រព័ន្ធទិន្នន័យនេះមិនត្រូវបានអនុញ្ញាតិអោយបញ្ចូលទិន្នន័យ ឬដកស្រង់ទិន្នន័យទេ។ ប្រព័ន្ធទិន្នន័យសំរាប់អង្គការក្រៅរដ្ឋាភិបាល និង សំរាប់ម្ចាស់ជំនួយនឹងត្រូវបានដាក់បញ្ចូលគ្នានៅចុងឆ្នាំ២០០៧ ហើយដែលនឹងបើកចំហរក្នុងការដកស្រង់យកទិន្នន័យ ។

អង្គការមេឌីខាំមានប្រព័ន្ធទិន្នន័យពីអង្គការក្រៅរដ្ឋាភិបាលចំនួនប្រហែលជាង១២០ ដែលធ្វើការក្នុងវិស័យសុខាភិបាល ។ ប្រព័ន្ធទិន្នន័យលំនាំជាផែនទីនេះអាចបង្ហាញពីវត្តមានគំរោងរបស់អង្គកាក្រៅរដ្ឋាភិបាល ដែលបែងចែកជាអនុវិស័យសុខាភិបាល រហូតដល់កំរិតឃុំរដ្ឋបាល។ ថ្វីបើទិន្នន័យរបស់វាគ្របដណ្តប់ស្តីពីអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារសុខាភិបាល និង អង្គការក្រៅរដ្ឋាភិបាលមួយភាគធំៗក៏ដោយ វាមានតែសមាជិកអង្គការមេឌីខាំទេ ដែលមាននៅក្នុងប្រព័ន្ធទិន្នន័យនេះ ។

ប្រព័ន្ធទិន្នន័យទាំងអស់នេះមិនមានប្រព័ន្ធទិន្នន័យណាមួយដែលឆ្លើយតបទៅនឹងតំរូវការរបស់ ក្រសួងសុខាភិបាលក្នុងការគ្រប់គ្រងទិន្នន័យបាន់ប្រមាណទេ ចំរុះគ្នានៃប្រព័ន្ធទិន្នន័យទាំងនេះមានសក្តានុពលអាចឆ្លើយតបទៅនឹងតំរូវការបាន។ ផ្អាកការការរៀបចំប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៏ផ្លូវការរបស់នាយកដ្ឋានសហប្រតិ-បត្តិការអន្តរជាតិមួយអន្លើ ហើយកំណត់ និងសំរួលយន្តការប្រមូលទិន្នន័យក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមឡើងវិញ។ នាយកដ្ឋានគួរដកស្រង់ទិន្នន័យជំនួយអភិវឌ្ឍន៏ផ្លូវការ ពីប្រព័ន្ធទិន្នន័យដែលមានស្រាប់មកប្រើប្រាស់ជាពិសេសប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា។

ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី បានបញ្ចូលទិន្នន័យរបស់ខ្លួនទៅក្នុងប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៏ផ្លូវការ

របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ប្រព័ន្ធទិន្នន័យនេះហាក់នៅតែជាប្រភពពត៌មានបឋមនៃជំនួយអភិវឌ្ឍន៍ផ្លូវការ សំរាប់រាជរដ្ឋាភិបាលកម្ពុជា ថ្វីបើ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង្ហាញថាខ្លួនចង់ ផ្ទេរិមជ្ឈការប្រព័ន្ធទិន្នន័យនេះ ទៅអោយក្រសួងស្ថាប័នជំនាញក៏ដោយ ។

ចំពោះគោលបំណងរបស់ក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម (ក៏ដូចជាតំរូវការពត៌មានផ្សេងទៀត) នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ គួរបង្កើតប្រព័ន្ធទិន្ន័យដែលសំដៅយកទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការប៉ាន់ប្រមាណដែលធំៗចំពោះវិស័យសុខាភិបាល ។

ដើម្បីមានទិន្នន័យបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរង់ចាំការបង្កើតប្រព័ន្ធទិន្នន័យ និងសាកល្បង និងបណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានអោយចេះថែទាំវា នាយកដ្ឋានអាចទទួលយកនិតិវិធីដូចតទៅដើម្បីផ្តល់ ទិន្នន័យពាក់ព័ន្ធទៅអោយក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យម ។

- ជ្រើសរើសពត៌មានដែលទាក់ទង ពីកំរងសំនួរដែលបានបំពេញរួច និងផ្ញើរជូននាយកដ្ឋានរួចហើយ ។
- ពិគ្រោះជាមួយម្ចាស់ជំនួយនិងអង្គក្រៅរដ្ឋាភិបាលដើម្បីការយល់ព្រមចុងក្រោយលើការប្រមាណហិរញ្ញវត្ថុ

ដោយសារការប្រមូលទិន្នន័យ សំរាប់រៀបចំក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមមានការប្រសើរឡើងពីមួយពេលទៅមួយពេល រួមជាមួយការបង្កើតប្រព័ន្ធទិន្នន័យរបស់នាយកដ្ឋាន នាយកដ្ឋានគួរចាប់ផ្តើមដំណើរការទទួលខុសត្រូវបឋមរបស់ខ្លួនប្រមូលទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការចំពោះ វិស័យសុខាភិបាលជាមួយគោលការណ៍ប្រចាំឆ្នាំ។ ម្ចាស់អំណោយ និងទីភ្នាក់ងារអនុវត្តគំរោង ត្រូវផ្ញើរជូន ទិន្នន័យផ្តល់មូលនិធិរបស់ខ្លួនទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្នុងពេលតែមួយដោយមានទំរង់ដូចគ្នាតាមការព្រមព្រៀង។ ធ្វើដូចនេះនឹងជួយអោយមានភាពស៊ីសង្វាក់នៃទិន្នន័យរបស់នាយកដ្ឋាន សហប្រតិ-បត្តិការ អន្តរជាតិ ជាមួយទិន្នន័យរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ហើយនឹងធ្វើអោយប្រសើរឡើងនូវតម្លាភាព និងទូរលេខ ។

### ៣.៥.៣ វេបសាយក្រសួងសុខាភិបាល

នៅឆ្នាំ២០០៤ ក្រសួងសុខាភិបាលបានបង្កើតវេបសាយរបស់ខ្លួន www.moh.gov.kh ។ គោលបំណងនៃវេបសាយគឺ ពង្រីកការផ្តល់ និងការប្រើប្រាស់ពត៌មាន សំរាប់ការធ្វើផែនការកម្មវិធី គ្រប់គ្រង តាមដាន និងវាយតំលៃដោយក្រសួងសុខាភិបាល និងដៃគូររបស់ក្រសួង។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចគ្រប់គ្រង និង ថែទាំវេបសាយក្រសួង។ វេបសាយដែលភ្ជាប់ដោយប្រព័ន្ធទិន្នន័យមានសមត្ថភាពយ៉ាងហោចៈ

- រៀបរាប់អំពីនាយកដ្ឋាន កម្មវិធីជាតិ គោលនយោបាយ អាទិភាព និងសកម្មភាពរបស់ក្រសួង
- ប្រព័ន្ធទិន្នន័យអាចធ្វើបច្ចុប្បន្នភាពបាន ទិន្នន័យអាចត្រូវបានយកមកប្រើប្រាស់ និង ធ្វើការវិភាគបាន

- ភ្ជាប់គេហទំព័រនៃនាយកដ្ឋាន កម្មវិធី ម្ចាស់អំណោយ និងអង្គការក្រៅរដ្ឋាភិបាល បណ្ណាល័យអេឡិចត្រូនិច មូលនិធិសាកល ។ល។ ទៅនឹង គេហទំព័រក្រសួងសុខាភិបាល
- ធ្វើផែនទី រួមទាំងផែនទីដែលប្រើដោយប្រព័ន្ធ GIS ដៅទីតាំងអគារសេវាសុខាភិបាលដែលមាន អ្នកផ្តល់សេវាអង្គការក្រៅរដ្ឋាភិបាល ប្រព័ន្ធផ្លូវថ្នល់ ។ល។
- ប្រតិទិន នៃ ពត៌មាន និង ព្រឹត្តការណ៍ដែលប្រព្រឹត្តឡើង ។ល។

នាយកដ្ឋាន និងកម្មវិធីជាតិមួយចំនួនមានវេបសាយផ្ទាល់ខ្លួន (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ការិយាល័យទទួលជំនួយមូលនិធិសាកល) វេបសាយទាំងនេះនឹងត្រូវភ្ជាប់ទៅនឹងវេបសាយកណ្តាលរបស់ក្រសួងសុខាភិបាល www.moh.gov.kh ។ សមាហរណកម្មវេបសាយទាំងនេះទៅជាវេបសាយតែមួយនឹងពង្រីកវិសាលភាព និងអំណាចរបស់វេបសាយកណ្តាលដែលដើរតួរជាប្រភពពត៌មានបឋមរបស់ក្រសួងសុខាភិបាល ។

សកម្មភាពរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្នុងភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងពត៌មាន មានដូចតទៅ (រួមទាំងសំរបសំរួលការរៀបចំក្របខ័ណ្ឌផែនការចំណាយសំរាប់រយះពេលមធ្យម) តែមិនកំណត់ដាច់ខាតនោះទេ:

- ទំនាក់ទំនងជាមួយ នាយកដ្ឋានផែនការ និងពត៌មានសុខាភិបាល ដើម្បីទទួលបាន ផែនការ៣ឆ្នាំរំកិល ផែនការប្រតិបត្តិប្រចាំឆ្នាំ ចុងក្រោយបំផុត
- ទំនាក់ទំនងជាមួយនាយកដ្ឋាន ថវិកា និង ហិរញ្ញវត្ថុ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលបាន ការផ្តល់មូលថវិកាប៉ាន់ប្រមាណសំរាប់រយៈពេល៣ឆ្នាំសំរាប់ក្រសួងសុខាភិបាល
- វិភាគទិន្នន័យនៃកំរងសំនួរ MTEF របស់ម្ចាស់ជំនួយ និង ដកស្រង់ទិន្នន័យសំខាន់ៗ
- ទំនាក់ទំនងជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជាដើម្បីធានាថាទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ស៊ីសង្វាក់ជាមួយទិន្នន័យដែល ម្ចាស់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាលបានផ្តល់ក្នុងកំរងសំនួរ MTEF ។
- ធានាថាទីភ្នាក់ងារអនុវត្តគម្រោងក្នុងវិស័យសុខាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងគំរោងជាមួយក្រសួងសុខាភិបាល
- ធានាថាទីភ្នាក់ងារអនុវត្តគម្រោងក្នុងវិស័យសុខាភិបាលមានទំរង់របាយការណ៍ ជាច្បាប់បោះពុម្ព និងអេឡិចត្រូនិចដែលបានកែសំរួលចុងក្រោយ ហើយនឹងដឹងអំពីតំរូវការដែលត្រូវធ្វើរបាការណ៏មកក្រសួងរៀងរាល់៦ ខែម្តង ។

- ប្រមូលនិង រក្សាទុកដាក់របាយការណ៍ដែលទទួលបានពី ទីភ្នាក់ងារអនុវត្តគំរោង និងតាមដានរំលឹក ទីភ្នាក់ងារអនុវត្តគំរោងណាដែលមិនបានផ្ញើររបាយការណ៍ទាន់ពេលវេលា (ប្រើប្រាស់យន្តការក្រុមការងារ បច្ចេកទេសសុខាភិបាលខេត្តប្រសិនសមស្រប)
- បញ្ចូលពតិមានសំខាន់ៗរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងប្រពន្ធ័ទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ
- វិភាគទិន្នន័យហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ ហើយនិងរៀបចំជាឯកសារប៉ាន់ប្រមាណនៃការផ្តល់ និង សន្យាផ្តល់មូលនិធិសំរាប់រយៈពេល១ឆ្នាំ និង ៣ឆ្នាំខាងមុខ
- ចងក្រងរបាយការណ៍សរុបដែលម្ចាស់ជំនួយ និងទីភ្នាក់ងារអនុវត្តន៍គ្របដណ្តប់បានចំណាយលើវិស័យ សុខាភិបាល ហើយនិងដាក់របាយការណ៍ជូនក្រុមការងារបច្ចេកទេសសុខាភិបាល
- ប្រមូល ចងក្រង និងរក្សាជាឯកសារនូវពតិមានអេឡិចត្រូនិកពីនាយកដ្ឋាន កម្មវិធីជាតិ រួមទាំងការ រៀបរាប់អំពីនាយកដ្ឋាន កម្មវិធីជាតិ គោលនយោបាយ ផែនការ អតិភាព និងសកម្មភាពរបស់ ក្រសួងសុខាភិបាល ហើយនិងបញ្ចូលពតិមានទាំងអស់នេះទៅក្នុង Website ក្រសួងជាបន្តបន្ទាប់
- បង្កើត និង គ្រប់គ្រង Website ក្រសួងព្រមទាំងមានលទ្ធភាពភ្ជាប់ទៅកាន់ Website នាយកដ្ឋាន កម្មវិធីជាតិ ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និង បណ្ណាល័យអេឡិចត្រូនិកដែលមានស្រាប់
- បញ្ចូលផែនទីរួមទាំងផែនទី GIS នៃទីតាំង សេវាសុខាភិបាល អង្គការក្រៅរដ្ឋាភិបាល ។ល។ ដោយ សហការជាមួយអង្គការ មេឌីខាំ
- ច្រងក្រង និង បញ្ចូលប្រតិទិនពតិមាននៃព្រឹត្តិការណ៍នានា ។ល។ ទៅក្នុង Website ក្រសួង
- ធានាថានឹងទទួលបាននូវ Website ដែលមានអាស័យដ្ឋាន www.moh.gov.kh អាចដំណើរការបាននៅលើ ប្រពន្ធ័។

## ៤. គោលនយោបាយនៃការគ្រប់គ្រងចំពោះសហប្រតិបត្តិការលើកិច្ចអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ដើម្បីឱ្យការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) មាន ប្រសិទ្ធិភាពគឺធ្វើ ឱ្យសំរេចនូវគោលបំណងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រជាតិជាអទិភាពដើម្បីកាត់ បន្ថយភាពក្រីក្រ និងធ្វើឱ្យសំរេចគោលបំណងអភិវឌ្ឍន៍សហសវត្សសកម្ពុជា ។ ការពង្រឹងប្រសិទ្ធិភាពជំនួយ ដើម្បី កាត់បន្ថយភាពក្រីក្រ និងដើម្បីបង្កើនផលប្រយោជន៍ជាអតិបរិមា សំរាប់ប្រជាជនកម្ពុជា នៅតែជាអាទិភាពចំបង សំរាប់រាជរដ្ឋាភិបាលកម្ពុជា ។

គំរោងយុទ្ធសាស្ត្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រង លើកិច្ចសហប្រតិបត្តការនៃការអភិវឌ្ឍន៍ (ខែមករា ឆ្នាំ២០០៦) បានគូសបញ្ជាក់ពីតំរូវការនៃភាពជាដៃគូអភិវឌ្ឍន៍ (អង្គការក្រៅរដ្ឋាភិបាលទ្វេភាគី និង

ពហុភាគី) ដើម្បីឱ្យមានការអនុវត្ត និងមានដំណើរការមួយស្របគ្នាដើម្បីកាត់បន្ថយភាពស្មុគស្មាញក្នុងថ្នាក់ក្រសួង និង ដើម្បីបញ្ជាក់ពីតម្លាភាពខ្ពស់នៅក្នុងការប្រើប្រាស់ធនធានដែលអាចឱ្យប្រទេសកម្ពុជាទទួលបានជំនួយបន្ថែមទៀត ។

រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចប្រជុំថ្នាក់កំពូលលើកដំបូង ដែលរៀបចំឡើងដោយ OECD/DAC ក្នុងខែកុម្ភៈ ឆ្នាំ២០០៣ នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី បានគាំទ្រលើសេចក្តីសន្យានានា ដែលធ្វើឡើងនៅក្នុងសេចក្តីប្រកាសមួយដែលបានបង្ហាញនៅ ចុងបញ្ចប់នៃកិច្ចប្រជុំ ហើយត្រូវបានទទួលស្គាល់ថាជា សេចក្តីប្រកាសទីក្រុងរ៉ូម (Rome Declaration) ។ សេចក្តីប្រកាសនេះបានគូសបញ្ជាក់លើការសន្យាជាក់លាក់ ចំនួយ៥ចំណុច :

- ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ត្រូវតែឈរនៅលើភាពជាដៃគូពិតប្រាកដ និងមានការទទួលខុសត្រូវរួមគ្នារវាង ដៃគូអភិវឌ្ឍន៍ និងប្រទេសទទួលជំនួយទាំងអស់ ដើម្បីទទួលបានលទ្ធផលល្អ ។
- ភាពជាម្ចាស់និងជាអ្នកដឹកនាំនៃប្រទេសទទួលជំនួយក្នុងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអនុវត្តយុទ្ធសាស្ត្រទាំងនេះចូលទៅក្នុងកម្មវិធីអនុវត្ត ដែលផ្អែកលើលទ្ធផលជាចំបង ។
- ប្រទេសទទួលជំនួយត្រូវតែនាំមុខក្នុងការគ្រប់គ្រង និងសំរបសំរួលជំនួយគ្រប់លំដាប់ថ្នាក់ទាំងអស់ ។
- ជំនួយដៃគូអភិវឌ្ឍន៍ទាំងឡាយ ត្រូវតែសំរបតាមយុទ្ធសាស្ត្រ និងអាទិភាពរបស់ប្រទេសទទួលជំនួយ ។
- ដៃគូអភិវឌ្ឍន៍ទាំងឡាយត្រូវតែសំរបការអនុវត្ត និងគោលការណ៍របស់ខ្លួន ឱ្យស្របគ្នាក្នុងចំណោមដៃគូទាំងអស់ និងជាមួយប្រទេសទទួលជំនួយផង ។

ផែនការសកម្មភាព លើសុខដុមរមនីយកម្ម, ការតំរង់ទិស និងលទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជា (H-A-R) ក្នុងការអនុវត្ត សេចក្តីប្រកាសទីក្រុងរ៉ូម ត្រូវបានអនុម័តដោយទីស្តីការគណរដ្ឋមន្ត្រី នៅខែវិច្ឆិកា ឆ្នាំ ២០០៤ ។

កិច្ចប្រជុំថ្នាក់កំពូលលើកទីពីរដែលបានរៀបចំឡើងនៅទីក្រុងប៉ារីស ក្នុងខែមិនា ឆ្នាំ២០០៥ ដើម្បីពិនិត្យមើលការរីក ចំរើននៃការអនុវត្តសេចក្តីប្រកាសទីក្រុងរ៉ូមហើយបានចេញជាសេចក្តីប្រកាសទីក្រុងប៉ារីសនៅចុងបញ្ចប់នៃកិច្ចប្រជុំ ។

**សេចក្តីប្រកាសទីក្រុងប៉ារីសមានគោលការណ៍ចំនួន ៥ :**

- **ភាពជាម្ចាស់:** ប្រទេសទទួលជំនួយត្រូវអនុវត្តនូវភាពជាអ្នកដឹកនាំឱ្យមានប្រសិទ្ធិភាពទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ របស់ខ្លួននិងសំរបសំរួលសកម្មភាពអភិវឌ្ឍន៍នានា ។

- **ការសំរបទិស:** ម្ចាស់ជំនួយទាំងឡាយត្រូវផ្តោតការឧបត្ថម្ភរបស់ខ្លួនទៅលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ស្ថាប័នជាតិ និងដំណើរការនានារបស់ប្រទេសទទួលជំនួយ ។

- **សុខដុមនីយកម្ម:** សកម្មភាពម្ចាស់ជំនួយទាំងអស់ត្រូវមានឥទ្ធិពលខ្ពស់លើការប្រមូលផ្តុំ តម្លាភាព និងភាពសុខដុមរមនីយកម្ម ។

- **ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល:** មានការគ្រប់គ្រងធនធាន និងធ្វើឱ្យប្រសើរឡើងនូវការសំរេចចិត្តទាំងឡាយដើម្បីសំរេចលទ្ធផល ។

- **គណនេយ្យភាពរួម:** ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ត្រូវមានការទទួលខុសត្រូវទៅលើលទ្ធផលរួមគ្នា ។

នៅខែតុលា ឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៏កម្ពុជាទាំងអស់ បានប្រកាសពីសុឆន្ទៈរបស់ខ្លួនដើម្បីបង្កើត ភាពជាដៃគូនៅក្នុងបរិបទកិច្ចសហប្រតិបត្តការណ៍, ការទុកចិត្តគ្នា និងការទទួលខុសត្រូវរួម ដើម្បីពង្រឹងជំនួយអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធិភាពខ្ពស់ និងបង្កើនផលប្រយោជន៏ទាំងអស់ដល់ប្រជាជនកម្ពុជា។ គោលបំណងរួមគ្នា ដែលបានព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍លើការពង្រឹងប្រសិទ្ធិភាព ជំនួយ[៦] គឺដើម្បីកាត់បន្ថយភាពក្រីក្រ ដោយជួយគាំទ្រការអនុវត្តផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP)និង ដើម្បីសំរេចគោលបំណងអភិវឌ្ឍន៏សហវត្សនានារបស់ ប្រទេសកម្ពុជា ។

[៦] សូមមើលឧបសម្ព័ន្ធ ១

## ៥. បរិយាកាសស្ថាប័នដែលគាំទ្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា

ដើម្បីជួយជំរុញគោលនយោបាយនិងកិច្ចព្រមព្រៀងខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារបច្ចេកទេសរួមមួយ (TWGs) នៅតាមវិស័យ (Sector/thematic level)។ រហូតមកដល់ពេលនេះមានក្រុមការងារបច្ចេកទេសចំនួន ១៨ ដែលក្រុមនីមួយៗដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា ដែលមានការចូលរួមពីសមាជិករាជរដ្ឋាភិបាល និងតំណាងដៃគូអភិវឌ្ឍន៍នានា (DPs) រួមជាមួយនឹងអ្នកសំរបសំរួលជំនួយធំៗម្នាក់ ឬច្រើននាក់ ។

នៅក្នុងឆ្នាំ ២០០៤ គណៈកម្មការសំរបសំរួលសុខាភិបាល (CoCom) ត្រូវបានបង្វែមកជា ក្រុមការងារបច្ចេកទេសសុខាភិបាលវិញ (TWG-H) ដើម្បីឱ្យស៊ីគ្នាជាមួយកំណែទំរង់រាជរដ្ឋាភិបាលថ្មីៗនេះ។ នៅឆ្នាំ២០០៥ ក្រុមការងារបច្ចេកទេសសុខាភិបាល បានបង្កើតលេខាធិការដ្ឋានមួយដើម្បីជួយឱ្យដំណើរការរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលមានភាពប្រសើរឡើង។ តួនាទីរបស់លេខាធិការដ្ឋានគឺជួយទ្រទ្រង់ការងាររដ្ឋបាល ដល់ក្រុមការងារបច្ចេកទេសសុខាភិបាល និងទទួលខុសត្រូវខ្ពស់ទៅលើការគាំទ្រការអនុវត្តគំរោងផែនការរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល ។

មានគណៈកម្មការសំរបសំរួលថ្នាក់កំពូលរវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល (GDCC) ដើម្បីផ្តល់គោលការណ៍ណែនាំ, កំណត់អាទិភាព សំរបសំរួលការងាររបស់ ក្រុមការងារបច្ចេកទេសវិស័យនិងដៃគូ អភិវឌ្ឍន៍នានា និងដើម្បីត្រួតពិនិត្យទៅលើការរីកចំរើនសំខាន់ៗ។ គណៈកម្មការសំរបសំរួលថ្នាក់ខ្ពស់រវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលបានកំណត់ឱ្យមានកិច្ចប្រជុំគ្នាពាជងក្នុងមួយឆ្នាំៗ ក្រោមការសំរបសំរួលរបស់លេខាធិការដ្ឋានរបស់គណៈកម្មការនេះ ដែលមានទីតាំងនៅគណៈកម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

តួនាទីចំបងរបស់គណៈកម្មការសំរបសំរួលថ្នាក់ខ្ពស់រវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល គឺដើម្បីព្រមព្រៀង និងតាមដានការរីកចំរើន លើសូចនករណ៍ត្រួតពិនិត្យរួម (JMIs)។ សូចនករណ៍ពិនិត្យរួមគ្នានេះបានបង្កើតឡើងនៅកម្ពុជា ដោយសារមានតំរូវការ ដើម្បីបង្កើតសន្ទស្សន៍ត្រួតពិនិត្យរួមគ្នានៅក្នុងកំណែទំរង់ចំបងនានា និងផ្នែកទាំងឡាយណាដែលពង្រឹងដល់ការអភិវឌ្ឍន៍ជាតិ។ សូចនករណ៍ត្រួតពិនិត្យរួមគ្នានេះត្រូវបានយកចេញមកពីគោលដៅផែនការទាំងឡាយដែលមានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ហើយដែលមានទំរង់ជាសូចនករណ៍លទ្ធផល និង/ឬ សូចនករណ៍នៃអភិក្រម ដែលចំបាច់ក្នុងការសំរេចគោលដៅរបស់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ សូចនករណ៍ត្រួតពិនិត្យរួម ត្រូវតែបានជ្រើសរើសដោយហ្មត់ចត់ មានការវាស់វែង ហើយនិងមានការគាំទ្រដោយប្រភពមូលនិធិដែលបានកំណត់ច្បាស់លាស់ និងមានការទទួលខុសត្រូវប្រតិបត្តិ។ សូចនាករណ៍ត្រួតពិនិត្យរួមត្រូវបានបង្កើតរួមគ្នាហើយត្រូវតែឆ្លុះបញ្ចាំងពីសកម្មភាពរួមគ្នា និងការទទួលខុសត្រូវពីរដ្ឋាភិបាលកម្ពុជារួមជាមួយនឹង ដៃគូអភិវឌ្ឍន៍ទាំងអស់ ។

ដោយសារក្រុមការងារបច្ចេកទេសសុខាភិបាល បានដើរតួនាទីចំបងក្នុងកិច្ចប្រជុំសំរាប់ការពិភាក្សាលំអិតលើបច្ចេកទេសនោះ គណៈកម្មការសំរបសំរួលថ្នាក់ខ្ពស់រវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលមានបំណងផ្តោតទៅលើការរីកចំរើនដែលសំខាន់ៗរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សូចនករណ៍ត្រួតពិនិត្យរួម ផែនការសកម្មភាពផ្តោតលើលទ្ធផល ការតំរង់ទិស និងភាពសុខដុមរមនីយកម្ម (H-A-R) និងធ្វើកំណែទំរង់សេវាសាធារណៈសំខាន់ៗទាំងអស់ ។ តួនាទី និងមុខងាររបស់គណៈកម្មការសំរបសំរួលថ្នាក់ខ្ពស់រវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល គឺដើម្បី ៈ

i. អោយមានការយល់ស្របរួមគ្នាលើ បញ្ហាគោលនយោបាយ និងបញ្ហាវិស័យ (Thematic) ជាពិសេសទាក់ទងទៅនឹងរបៀបវារៈកែទំរង់ទូលំទូលាយ ដែលមានសារៈសំខាន់បំផុត ។

ii. ពិភាក្សាពីវឌ្ឍនភាពដែលបានកំណត់ ដើម្បីពិភាក្សាបន្តទៀត នៅក្នុងកិច្ចប្រជុំស្តីពីសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជា និងដើម្បីយកបញ្ហាដែលបានលើកឡើងដោយក្រុមការងារបច្ចេកទេសមកដោះស្រាយ និង ឬ ផ្តល់ដំបូន្មាន ។

iii. ធ្វើជាកិច្ចប្រជុំតស៊ូមតិ ដែលរួមទាំងតំណាងដៃគូរអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងឡាយដែលបានអញ្ជើញចូលរួម ។

iv. ជួបប្រជុំដើម្បីបញ្ជាក់ និងកំណត់ ពីសូចនាករណ៍ត្រួតពិនិត្យរួម ដែលបានជំរាបជូនថា សូចនករណ៍ពិនិត្យរួមគ្នាទាំងនោះ នឹងត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស រួមជាមួយនឹងការត្រួតពិនិត្យលើការវវឌ្ឍភាពនៃសូចនករណ៍ត្រួតពិនិត្យរួមនេះ មុននឹងស្នើសុំសេចក្តីសំរេចពីកិច្ចប្រជុំសហប្រតិ-បត្តិការអភិវឌ្ឍន៏កម្ពុជាប្រចាំឆ្នាំ ។

កិច្ចប្រជុំសសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជា (CDCF) កាលពីមុនត្រូវបានគេស្គាល់ថាជា ការប្រជុំក្រុមពិគ្រោះយោបល់ដែលត្រូវបានរៀបចំឡើងសំរាប់ជំនួបសំខាន់ៗលើបញ្ហាការអភិវឌ្ឍន៏ជាតិ ។ មុខងាររបស់កិច្ចប្រជុំសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជាគឺ ប្រកាន់យកការវាយតំលៃដោយឥតលំអៀង នៃវឌ្ឍនភាពជារួមនៅក្នុងប្រទេសកម្ពុជា និងបញ្ហាប្រឈមនានា ពិភាក្សាលើគោលនយោបាយ និងកំណែទំរង់, និងដើម្បី ឱ្យឈានទៅដល់ការយល់គ្នាទេវិញទៅមកចំពោះស្ថានភាពទូទៅ, តំរូវការអនាគត និងបញ្ហាប្រឈមទាំងអស់ ។ កិច្ចប្រជុំសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជា ក៏បានផ្តល់ផងដែរនូវទំរង់បែបបទ (Platform) ដល់ដៃគូអភិវឌ្ឍន៏ទាំងអស់ក្នុងការសន្យាផ្តល់ជំនួយនានានៅពេលខាងមុខ ដែលបានកែតំរូវជាមួយការអភិវឌ្ឍន៏ ជាអាទិភាពរបស់រដ្ឋាភិបាលនៅក្នុងបរិបទនៃគំរោងថវិការសំរាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ (NSDP) ។

**ក្រុមប្រឹក្សានិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** (CRDB/CDC) គឺជាស្ថាប័នចំបង នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ដែលមានភារៈគៀងគរ ជំនួយអភិវឌ្ឍន៍អភិវឌ្ឍន៍ផ្លូវការ(ODA)ផង ជាអ្នកសំរប សំរួលជំនួយអភិវឌ្ឍន៍ផ្លូវការជាមួយ ដៃគូអភិវឌ្ឍន៍ទាំងអស់ផង (ដៃគូអភិវឌ្ឍន៍ទ្វាភាគី និងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលនានា) និងជាអ្នកសំរបសំរួលរវាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា និងជាមួយទីភ្នាក់ងារទាំងឡាយ ក្នុងការបែងចែកជំនួយអភិវឌ្ឍន៍ផ្លូវការ និងបញ្ហានៃការប្រើប្រាស់ ។

**ក្រុមប្រឹក្សានិតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានការទទួលខុសត្រូវលើ**

- ការបង្កើតកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសរួម តាមវិស័យដើម្បីធ្វើ បច្ចុប្បន្នភាពពតិមានថ្មីៗ ស្តីពីការរីកចំរើនដែលបានធ្វើឡើងដោយក្រុមការងារបច្ចេកទេស ក្នុងការ អនុវត្តន៍ផែនការសកម្មភាពរបស់ខ្លួន និង ដាក់របាយការណ៍រីកចំរើនប្រចាំត្រីមាសនៃកិច្ចការរបស់ ក្រុមការងារបច្ចេកទេសជូនដល់ គណៈកម្មការ សំរបសំរួលអ្នកផ្តល់ជំនួយរដ្ឋាភិបាល ។

- កិច្ចប្រតិបត្តិការ និងបំពេញតួនាទីជារដ្ឋាខាធិការដ្ឋាន ដើម្បីទ្រទ្រង់ដល់ការងាររបស់ គណៈកម្មការសំរប សំរួលរវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល ។

- ការផ្តល់ការគាំទ្រដល់ប្រធាន ក្រុមការងារបច្ចេកទេស ដើម្បីធានាឱ្យបាននូវការចុះសំរុងគ្នា នៃសកម្មភាព ការងារដែលឧបត្ថម្ភដោយដៃគូអភិវឌ្ឍន៍ ជាមួយនឹងអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ការអនុវត្ត របស់ដៃគូអភិវឌ្ឍន៍ និងកសាងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើនប្រសិទ្ធិភាព នៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានបែងចែកទៅផ្នែក និងវិស័យផ្សេងរបស់ក្រុមការងារបច្ចេកទេស ។

ក្រុមប្រឹក្សានិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើរតួរជាអ្នកសំរបសំរួល និងជា ច្រកចេញចូលតែមួយនៃរាជរដ្ឋាភិបាលកម្ពុជាសំរាប់ប្រទេសអ្នកផ្តល់ជំនួយនានា អង្គការអន្តរជាតិ និងអង្គការក្រៅ រដ្ឋាភិបាលទាំងអស់ នៅក្នុងការសំរបសំរួលការប្រើប្រាស់នឹងការបែងចែកជំនួយពីខាងក្រៅ ។ ក្រុមប្រឹក្សានិតិ សម្បទា និងអភិវឌ្ឍន៍កម្ពុជា ទទួលខុសត្រូវក្នុងការធានាឱ្យផែនការ នៃកម្មវិធីអភិវឌ្ឍន៍ ដែលបានធ្វើឱ្យស៊ីគ្នា ជាមួយអាតិភាពអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាលកម្ពុជា ។

ទោះបីជាយន្តការក្រុមការងារបច្ចេកទេសនៃគណៈកម្មការសំរបសំរួលអ្នកផ្តល់ជំនួយរដ្ឋាភិបាល(GDCC) បាន ធ្វើមុនថ្ងៃនៃសេចក្តីប្រកាសទីក្រុងប៉ារីស និងគោលការណ៍ណែនាំរបស់ OECD/DAC ក៏ដោយ ក៏កម្មវត្ថុចំបង ដ៏សំខាន់នៃយន្តការនេះ គឺមានរួមជាមួយនឹងការផ្តួចផ្តើមជាសកលផងដែរ ។ ជាពិសេសយន្តការរបស់ក្រុមការងារ បច្ចេកទេសនៃគណៈកម្មការសំរបសំរួលរវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលគឺមានបំណងសំរេចនូវគោលដៅដូច ខាងក្រោម :

i. ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះដំណើរការអភិវឌ្ឍន៍ដោយឈរលើគោលការណ៍ ភាពជាដៃ គូ

ii. ជំរុញអោយមានការសំរបទិសនៃគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ទៅនឹងអាទិភាពអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលបានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) រួមជាមួយផ្នែកដទៃទៀតព្រមទាំងដំណើរកំណែទំរង់ ។

iii. ធ្វើសុខដុមនីយកម្មដែន និតិវិធីរបស់ដៃគូអភិវឌ្ឍន៍ កាត់បន្ថយចំណាយប្រតិបត្តិការនានាក្នុងការបែងចែកជំនួយ និងពង្រឹងប្រព័ន្ធរាជរដ្ឋាភិបាល ដែលធ្វើឱ្យធនធានខាងពីក្រៅ អាចសំរួលទៅដល់កម្មវិធីអាទិភាពរបស់រាជរដ្ឋាភិបាលតាមរយៈប្រព័ន្ធរាជរដ្ឋាភិបាលកម្ពុជា ។

iv. រៀបចំកិច្ចប្រជុំដែលតាមរយៈប្រភពធនធានទាំងអស់ (ប្រភពធានក្នុងស្រុក និងក្រៅស្រុក) ដែលអាចពិភាក្សាដោយតម្លាភាព ។ ធ្វើដូចនេះការត្រួតស៊ីគ្នាអាចត្រូវបានកាត់បន្ថយ ហើយសកម្មភាពជា អាទិភាពក្នុងការផ្តល់ថវិកា អាចត្រូវបានគេពិភាក្សាបាននៅក្នុងលក្ខខ័ណ្ឌមួយដែលទូលំទូលាយ និងស្រមស្របដោយការប្រើប្រាស់ ថវិកាជំនួយដ៏ត្រឹមត្រូវ (appropriate aid modalities) ។

v. ជំរុញការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រផ្អែកទៅកម្មវិធី និង/ឬ យុទ្ធសាស្ត្រទូលំទូលាយ(SWAps) ។នៅឱ្យឆ្ងាយពីការដែលជំនួយផ្អែកលើគំរោងកម្មវិធី ដោយផ្តោតទៅជំនួយកម្មវិធី និងការទ្រទ្រង់ថវិកា ។

vi. ជំរុញភាពជាដៃគូ និងការទទួលខុសត្រូវរួមនៅក្នុងការអភិវឌ្ឍន៍ និងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយវិស័យ គោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយរួមបញ្ចូលទាំងការប្រើប្រាស្ទចនករណ៍ពិនិត្យរួម (JMIs) ។ និងផែនការសកម្មភាពរាជរដ្ឋាភិបាលផ្តោតលើលទ្ធផល ការសំរបទិស និងសុខដុមនីយកម្ម (H-A-R) ។

vii. ផ្តល់ឱកាសដើម្បីធ្វើការត្រួតពិនិត្យ និងវាយតំលៃឱ្យមានប្រសិទ្ធិភាព និងមានឥទ្ធិពលលើគ្រប់ប្រភពធនធានទាំងអស់ ដោយរួមបញ្ចូលទាំងសារៈប្រយោជន៍នៃការវាយតំលៃរួម និងពិនិត្យរួម ។ ការធ្វើបែបនេះនឹងនាំឱ្យការប្រើ ប្រាស់ធនធាន និងយុទ្ធសាស្ត្រអនាគតអាចត្រូវបានគេផ្តល់ពតិមានជូនជាបន្តបន្ទាប់ ។

viii. បញ្ជាក់ និងយល់ព្រមលើយុទ្ធវិធីសមរម្យមួយ សំរាប់ការពង្រឹងសមត្ថភាព ដែលអាចជំរុញភាពម្ចាស់ការនៅក្នុងការ ប្រើប្រាស់ជំនួយបច្ចេកទេស និងផ្តល់ជូនគ្របវិធីសាស្ត្រទាំងអស់ សំរាប់ដំណើរការវាយតំលៃការពង្រឹងសមត្ថភាពរាជរដ្ឋាភិបាលកម្ពុជា ។

ix. ដាក់ទីតាំងក្រុមការងារបច្ចេកទេស នៃគណៈកម្មការសំរបសំរួលអ្នកផ្តល់ជំនួយរដ្ឋាភិបាល នៅក្នុងរចនាសម្ព័ន្ធក្រុមការងារបច្ចេកទេស ដើម្បីជួយសំរួលដល់ការត្រួតពិនិត្យឱ្យមានប្រសិទ្ធិភាព លើគ្រប់យន្តការសំរបសំរួលទាំងអស់ដែលមានបំណងជំរុញបទពិសោធន៍ពីការប្រតិបត្តិល្អ និងការអនុវត្តជាទូទៅលើប្រធានបទ ប្រសិទ្ធិភាពជំនួយរាជរដ្ឋាភិបាលកម្ពុជា ។

មួយឆ្នាំបន្ទាប់ពីការបង្កើតប្រព័ន្ធក្រុមការងារបច្ចេកទេសរួចមក ក្រុមការងារនេះបានបញ្ជូនរបាយការណ៍វឌ្ឍនៈភាពរបស់ខ្លួនទៅលេខាធិការដ្ឋាននៃគណៈកម្មការសំរបសំរួលរវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល ដោយផ្អែកលើទំរង់បទដ្ឋានមួយដែលរួមបញ្ចូលទាំងពត៌មានស្តីពីការរីកចំរើន ការអនុវត្តផែនកាសកម្មភាពរបស់ក្រុមការងារបច្ចេកទេស សូចនករណ៍ត្រួតពិនិត្យរួម ការសំរបទិស និងសុខដុមនីយកម្ម (Alignment and Harmonization) និងការផ្តល់ធនធននៃក្រុមការងារបច្ចេកទេសទាំងអស់ ។ របាយការណ៍រីកចំរើនទាំងនោះ បន្ទាប់មកបានច្របាច់បញ្ចូលគ្នាទៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មការសំរបសំរួលរវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល ដើម្បីជាពត៌មាន និងសំរាប់ចែកជូនដល់កិច្ចប្រជុំគណៈ កម្មការសំរបសំរួលអ្នកផ្តល់ជំនួយរដ្ឋាភិបាល លើកក្រោយ ។

# សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានាស្តីពីការពង្រឹង ប្រសិទ្ធភាពជំនួយ

ខែតុលា ឆ្នាំ ២០០៦

ក្រុងភ្នំពេញ

# សេចក្តីប្រកាស
# របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា
# ស្តីពីការពង្រឹងប្រសិទ្ធិភាពជំនួយ

រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា បានប្រកាសពីសុឆន្ទៈរបស់ខ្លួន ដើម្បីបង្កើតភាពជាដៃគូរ នៅក្នុងបរិបទនៃកិច្ចសហប្រតិបត្តិការ ការទុកចិត្តគ្នា និងគណនេយ្យភាពរួមគ្នា ដើម្បីពង្រឹងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីផ្តល់ផលប្រយោជន៍ជាអតិបរមាសំរាប់ប្រជាជនកម្ពុជា។ គោលបំណងរបស់យើងគឺដើម្បី កាត់បន្ថយភាពក្រីក្រ ដោយជួយគាំទ្រការអនុវត្តផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) និងដើម្បីសំរេចគោលបំណងអភិវឌ្ឍន៍សហសវត្សរបស់រាជរដ្ឋាភិបាលកម្ពុជា ។ គោលបំណងនៃសេចក្តីប្រកាសនេះ គឺជាការក្រើនរំលឹកទៅដល់ សេចក្តីប្រកាស របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ស្តីពីសុខដុមនីយកម្ម និងការតំរង់ទិស (Harmonization and Alignment) ដែលបានអនុវត្តនៅខែធ្នូ ឆ្នាំ ២០០៤ ដើម្បីពិចារណាទៅលើគោលការណ៍ជាចំបង ៥ចំណុច នៃសេចក្តីប្រកាសទីក្រុងប៉ារីស ស្តីពីប្រសិទ្ធិភាពជំនួយ ដែលបានអនុម័តកាលពីខែ តុលា ឆ្នាំ ២០០៥ ស្របតាមបរិបទ នៃប្រទេសកម្ពុជា។

**គោលការណ៍ជាចំបង ៥ចំណុច នៃសេចក្តីប្រកាសទីក្រុងប៉ារីសរួមមាន**

- **ភាពជាដៃគូ:** ប្រទេសជាដៃគូទាំងអស់ត្រូវតែអនុវត្តនូវភាពជាអ្នកដឹកនាំ ឱ្យមានប្រសិទ្ធិភាពលើការអភិវឌ្ឍន៍ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួន និងសំរបសំរួលសកម្មភាពអភិវឌ្ឍន៍នានា ។

- **ការតំរង់ទិស:** ម្ចាស់ជំនួយទាំងឡាយ ត្រូវផ្តោតការឧបត្ថម្ភរបស់ខ្លួនជាទូទៅ លើយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ស្ថាប័នជាតិ និងដំណើរការនានា របស់ប្រទេសទទួលជំនួយដែលជាដៃគូ ។

- **សុខដុមនីយកម្ម:** សកម្មភាពរបស់ម្ចាស់ជំនួយទាំងអស់គឺមានប្រសិទ្ធិភាពខ្ពស់លើការប្រមូលផ្តុំ តម្លាភាព និង សុខដុមនីយកម្ម ។

- **ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល:** ត្រូវមានការគ្រប់គ្រងធនធាន និងធ្វើឱ្យប្រសើរឡើងលើការសំរេចចិត្តដើម្បីសំរេចលទ្ធផល។

- **គណនេយ្យភាពរួមគ្នា:** ម្ចាស់ជំនួយ និងប្រទេសទទួលជំនួយជាដៃគទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នាលើលទ្ធផលអភិវឌ្ឍន៍ទាំងអស់ ។

ទោះបីជាសេចក្តីប្រកាសនេះមិនភ្ជាប់ដោយអំណាចផ្លូវច្បាប់ក្តី ក៏វាបានបង្ហាញពីការទទួលស្គាល់រួមរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូផ្តល់ជំនួយទៅលើការពង្រឹងប្រសិទ្ធិភាពជំនួយនៅក្នុងប្រទេសកម្ពុជាដែរ ។

ស្មារតីនៃគោលការណ៍ចំបង ៥ចំណុចនេះ ចេញមកពីដំណោះស្រាយនៃការព្រមព្រៀងគ្នា នៅទីក្រុងម៉ុងតេរី (Monterrey) ប្រទេសម៉ិកស៊ិក(ខែមិនា ឆ្នាំ ២០០២) សេចក្តីប្រកាសទីក្រុងរ៉ូម(ខែកុម្ភៈ ឆ្នាំ ២០០៣) កិច្ចប្រជុំតុមូលទីក្រុង ម៉ារ៉ាកិច ប្រទេសម៉ូរ៉ុក ស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផល(ខែកុម្ភៈ ឆ្នាំ ២០០៤) សេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធិភាពជំនួយ(ខែមិនា ឆ្នាំ ២០០៥) ក្រុមការងាររបស់ OECD/DAC ស្តីពីប្រសិទ្ធិភាពជំនួយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់ការគ្រប់គ្រងសហប្រតិបត្តិការលើកិច្ចអភិវឌ្ឍន៍(ខែមករាឆ្នាំ ២០០៦) ។

## ភាពជាម្ចាស់

## រាជរដ្ឋាភិបាលកម្ពុជាប្រកាន់ខ្ជាប់ភាពជាម្ចាស់ការ និងភាពជាអ្នកដឹកនាំលើការអភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពអភិវឌ្ឍន៍របស់ខ្លួនទាំងអស់

**រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាថា:**

- រៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិមួយឆ្នាំ២០០៦-២០១០ (NSDP) ។ ផែនការយុទ្ធសាស្ត្រនេះនឹងបង្កើតនូវក្របខ័ណ្ឌត្រួតពិនិត្យ និងបន្តពិនិត្យមើលជារៀងរាល់ឆ្នាំលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

- បង្កើត និងអនុម័តផែនការតាមវិស័យ(Sector Plan) នៅក្នុងក្របខ័ណ្ឌការងាររបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការថ្នាក់ខេត្ត ដោយមានការពិភាក្សាជាមួយដៃគូទាំងអស់ ។

- កែតំរូវថវិកាជាតិដើម្បីគាំទ្រដល់ការអនុវត្តការរៀបចំផែនការ អភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ តាមរយៈកម្មវិធីវិនិយោគសាធារណៈ (PIP)

- ពង្រឹងបន្ថែមទៀតពីតួនាទីភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ ក្នុងការសំរបសំរួលផ្នែកជំនួយនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជនទាំងអស់ ។

**ដៃគូអភិវឌ្ឍន៍ប្តេជ្ញាថា:**

- គោរពភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំ របស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងដំណើរការគ្រប់គ្រងការអភិវឌ្ឍន៍របស់ខ្លួន និងផ្តល់នូវការគាំទ្រសហប្រតិបត្តិការ ដើម្បីពង្រឹងសមត្ថភាពបុគ្គលិក និងក្រសួងស្ថាប័ននិងគ្រឹះស្ថាននានា ដើម្បីសំរេចបានគោលដៅផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ថ្នាក់ជាតិឆ្នាំ ២០០៦-២០១០ ។

## ការតំរង់ទិស

## ដៃគូអភិវឌ្ឍន៍ទាំងអស់នឹងផ្តោតការគាំទ្រជានូនៅរបស់ខ្លួនលើយុទ្ធសាស្ត្រ, ស្ថាប័ន និង និតិ-វិធីទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញា ៖**

- បន្តការគ្រប់គ្រងដែលមានស្រាប់ ប្រព័ន្ធច្បាប់ និងយន្តការគ្រឹះស្ថានដែលអាចផ្តល់លទ្ធផល ឱ្យមានតម្លាភាព និងទទួលខុសត្រូវ លើការលើកកំពស់ប្រសិទ្ធិភាពជំនួយ ។

- បន្តការអនុវត្តកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានគត់មត់ ដោយរួមបញ្ចូលទាំងការវាយតំលៃតាមដំណាក់ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្ម ។
- ប្រឹងប្រែងដឹកនាំ ដើម្បីជំរុញការអភិវឌ្ឍន៍សមត្ថភាពរយៈពេលវែង ដោយធ្វើការវាយតំលៃ និងចងក្រងយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពទូលំទូលាយ និងសកម្មភាពទាំងអស់នៅថ្នាក់វិស័យដែលរួម សហការណ៍ពីដៃគូអភិវឌ្ឍន៍នានា ដើម្បីសំរេចលទ្ធផលអភិវឌ្ឍន៍ ឱ្យចំគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ដៃគូអភិវឌ្ឍន៍ប្តេជ្ញានឹង ៖**

- ផ្តោតការគាំទ្រជារួមរបស់ខ្លួនទៅលើអាទិភាពដែលបានគូសបញ្ជាក់ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និង ស្របតាមផែនការវិនិយោគសាធារណៈនូវគំរោងកម្មវិធីអភិវឌ្ឍន៍ដែលខ្លួនផ្តល់ ។
- ផ្តល់ការគាំទ្រ សំរបសំរួលដើម្បីពង្រឹងគ្រឹះស្ថាន, ប្រព័ន្ធ និងនិតិវិធីរបស់រាជរដ្ឋាភិបាលទាំងអស់ ។
- ធ្វើឱ្យការប្រើប្រាស់គ្រឹះស្ថាន, ប្រព័ន្ធ និងនិតិវិធីរបស់រាជរដ្ឋាភិបាលទាំងអស់ ឱ្យរីកចំរើនជាលំដាប់ជាមួយស្តង់ដាដែលបានព្រមព្រៀងគ្នារួចហើយ ។
- ជៀសវាងការបង្កើតរចនាសម្ព័ន្ធថ្មី (PIU/PMUs) សំរាប់ការគ្រប់គ្រងប្រចាំថ្ងៃ និងការអនុវត្តកម្មវិធី និង គំរោងថវិការបស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ។

## សុខដុមនីយកម្ម

## សកម្មភាពដៃគូអភិវឌ្ឍន៍ ត្រូវតែមានតម្លាភាព សមូហភាព និងមានភាពសុខដុម

**រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាថានឹង :**

- បន្តធ្វើការជាមួយការិយាល័យកណ្ដាលនៃដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីស្វែងរកការផ្ដល់សិទ្ធិអំណាចបន្ថែមពីការិយាល័យកណ្ដាលនៃដៃគូអភិវឌ្ឍន៍ ជូនដល់ការិយាល័យមូលដ្ឋាននៃប្រទេសនីមួយៗ ដើម្បីអាចឱ្យពួកគេមាន ការទំនាក់ទំនងប្រសើរជាងមុននូវបញ្ហាសុខដុមរមនីយកម្ម និងស្របទិសគ្នា នៅក្នុងបរិបទកម្ពុជា ។

**ដៃគូអភិវឌ្ឍន៍ប្ដេជ្ញាថានឹង:**

- បង្កើត និងអនុម័តនូវការវិភាគរួមគ្នាដែលអាចធ្វើទៅបានក្នុងកំរិតខ្ពស់បំផុត និងក្របខ័ណ្ឌត្រួតពិនិត្យការសំរបសំរួលជារួម និងគោលការណ៍សាមញ្ញៗទាំងអស់ ដើម្បីគ្រប់គ្រងគំរោង/កម្មវិធី ដោយរួមបញ្ចូលទាំងរបាយការណ៍ និង ការធ្វើសវនៈកម្ម ។
- ពង្រីកសមាមាត្រនៃកម្មវិធីសហប្រតិបត្តការអភិវឌ្ឍន៍ តាមរយៈកម្មវិធីតំបន់ និងយុទ្ធវិធីកម្មវិធីដោយមានការគោរពទៅតាមបែបបទជំនួយបន្ថែមទៀត (complimentarily of aid modalities) ។
- កាត់បន្ថយចំនួយបេសកកម្មដោយឡែកៗ និងត្រួតស៊ីគ្នា នូវការធ្វើវិនិច្ឆ័យ និងធ្វើការសិក្សា ។
- បង្កើនការប្រើប្រាស់ស្ដីពីការរៀបចំសហប្រតិបត្តិការនានា ។

## ការគ្រប់គ្រងដោយផ្ដោតលើលទ្ធផល

## គ្រប់គ្រងធនធាន និងធ្វើអោយប្រសើរឡើងការសំរេចចិត្តដែលផ្ដល់លទ្ធផល

**រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាថានឹង:**

- បង្កើត និងអនុម័តក្របខ័ណ្ឌត្រួតពិនិត្យការអនុវត្តផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) និងរៀបចំការការពិនិត្យឡើងវិញនូវរបាយការណ៍វឌ្ឍនះភាពប្រចាំឆ្នាំនៃរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។
- ធ្វើឱ្យការប្រើប្រាស់ពតិមានពីរបាយការណ៍ប្រចាំឆ្នាំ របស់ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដោយភ្ជាប់អាតិភាពទាំងឡាយជាមួយដំណើរការរៀបចំថវិកា ដើម្បីសំរេចបានលទ្ធផលដែលបានកំណត់ ។

**ដៃគូអភិវឌ្ឍន៍ប្ដេជ្ញាថានឹង:**

- ធ្វើការកែតំរូវឡើងវិញនូវកម្មវិធី និងគំរោងរបស់ពួកគេ ក្នុងក៏រិតខ្ពស់មួយដែលអាចធ្វើទៅបានសំរាប់សកម្មភាពអាទិភាពទាំងឡាយ នៅក្នុងកម្មវិធីវិនិយោគសាធារណ:៣ឆ្នាំ ដោយផ្អែកទៅលើរបាយការណ៍ប្រចាំឆ្នាំ នៃការអនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

**គណនេយ្យភាពរួមគ្នា**

**រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងឡាយត្រូវទទួលខុសត្រូវចំពោះលទ្ធផលអភិវឌ្ឍន៍ទាំងអស់**

**រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាធឹង :**

- ពង្រឹងតួនាទីដៃគូអភិវឌ្ឍន៍ទាំងអស់ក្នុងការរៀបចំផែនការនិងការអនុវត្តកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ ។
- ផ្តល់លទ្ធភាពដល់ ដៃគូអភិវឌ្ឍន៍ទាំងអស់ប្រើប្រាស់ពតិមាន ស្តីពីការប្រើប្រាស់ប្រភពធនធានជំនួយអភិវឌ្ឍន៍ផ្លូវការដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពនៅក្នុងការប្រើប្រាស់ធនធាន សហប្រតិបត្តការអភិវឌ្ឍន៍ទាំងឡាយដែលមាន ។
- ប្រកាន់យកនូវកំណែទំរង់ដែលចាំបាច់ ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព នៅក្នុងការប្រើប្រាស់ធនធានអភិវឌ្ឍន៍សហប្រតិបត្តការទាំងឡាយដែលមាន ។

**ដៃគូអភិវឌ្ឍន៍ប្តេជ្ញាធឹង:**

- ផ្តល់ជូនពតិមានទាន់ពេលវេលា ដោយមានតម្លាភាព អំពីលំហូរជំនួយ ដោយទូលាយដើម្បីពង្រីកលទ្ធភាពជាអតិបរិមានូវការបង្កើនតម្លាភាព និងគណនេយ្យភាព នៅក្នុងការប្រើប្រាស់ប្រភពធនធានជំនួយការអភិវឌ្ឍន៍ផ្លូវការ និង លើកកំពស់ការតំរង់ទិសធនធានជំនួយអភិវឌ្ឍន៍ផ្លូវការឱ្យស្របជាមួយនឹងអាទិភាពអភិវឌ្ឍន៍កម្ពុជា ។
- ធ្វើផែនការ និងការបែងចែកជំនួយរបស់ខ្លួនអោយមានតម្លាភាព និងគណនីយភាពចំពោះភាគីពាក់ព័ន្ធដើម្បីបង្កើនប្រសិទ្ធិភាពជំនួយនិងផ្តល់ផលប្រយោជន៍ជូនដល់ប្រជាជនកម្ពុជាជាពិសេសទៅដល់អ្នកក្រីក្រ ។

**យុទ្ធសាស្ត្រឆ្ពោះទៅមុខ**

យើងទាំងអស់គ្នា រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងអស់ សូមសំដែងនូវសុឆន្ទៈដ៏មោះមុតដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការអនុវត្តន៍ផែនការសកម្មភាពរាជរដ្ឋាភិបាលកម្ពុជា ស្តីពីសុខដុមនីយកម្ម ការតំរង់ទិស និងការគ្រប់គ្រងផ្តោតលើលទ្ធផល(H-A-R) ឆ្នាំ២០០៦-២០១០ ។ យើងទាំងអស់គ្នា

នឹងត្រួតពិនិត្យមើលលើការរីកចំរើន ការអនុវត្តផែនការសកម្មភាព ដែលនឹងត្រូវរាយការណ៍ជូនគណៈកម្មការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយរដ្ឋាភិបាល (GDCC) ។

យើងសូមបញ្ជាក់ពីសុឆន្ទៈរបស់យើងដើម្បីធ្វើការរួមចំណែកពង្រឹកប្រសិទ្ធិភាពជំនួយ និងប្រសិទ្ធិភាពនៅព្រះរាជាណាចក្រកម្ពុជា ។

ចុះហត្ថលេខានៅរាជធានីភ្នំពេញ, កម្ពុជា ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៦

**តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា:**

---------------------

**ទេសរដ្ឋមន្ត្រី គាត ឈន់**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អនុប្រធានទីមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
រាជរដ្ឋាភិបាលកម្ពុជា

**តំណាងដៃគូអភិវឌ្ឍន៍ទាំងអស់**

| | |
|---|---|
| ---------------------- | ---------------------- |
| **Yvon Roé d'Albert** | **Takahashi Fumiaki** |
| ឯកអគ្គរដ្ឋទូតបារាំង | ឯកអគ្គរាជទូតជប៉ុន |
| ---------------------- | ---------------------- |
| **Lisa K. Filipetto** | **Pius Fischer** |
| ឯកអគ្គរាជទូតអូស្ត្រាលី | ឯកអគ្គរាជទូតសាធារណរដ្ឋអាល្លឺម៉ង់ |
| ---------------------- | ---------------------- |

**David G. Reader**
ឯកអគ្គរាជទូតចក្រភពអង់គ្លេស

-----------------------

**Donica Pottie**
ឯកអគ្គរាជកាណាដា

-----------------------

**Mogens L. Christensen**
រដ្ឋមន្ត្រីធារធារី
តំណាងដានីដា

-----------------------

**Eva Gibson Smedberg**
ធារធារី
តំណាងស៊ុីដា

-----------------------

**Lynn de Silva**
អគ្គលេខាធិការទីមួយ និងជាប្រធាន NZAID
ប្រចាំប្រទេសថៃ ឡាវ កម្ពុជា និងភូមា NZAID

-----------------------

**Piper A. W Campbell**
Chargé d'Affaires
ស្ថានទូតសហរដ្ឋអាមេរិក

-----------------------

**Alain Goffeau**
ប្រធានប្រចាំប្រទេសស្តីទី
ធនាគារអភិវឌ្ឍន៏អាស៊ី

-----------------------

**Daniel Costa Llobet**
Chargé d'Affaires
គណកម្មការសហគមអឺរ៉ុប

-----------------------

**Douglas Gardner**
អ្នកសំរបសំរួលអង្គការសហប្រជាជាតិ

-----------------------

**Nisha Agrawai**
ប្រធានប្រចាំប្រទេស
ធនាគាពិភពលោក

We, the undersigned, hereby confirm our willingness to jointly work on enhancing aid effectiveness and efficiency in Cambodia.

Signed this day, the Fifth of October 2006, in Phnom Penh, Cambodia

**For the Royal Government of Cambodia:**

------------------------

Sr. Minister Keat Chhon, MP
Minister of Economy and Finance
First Vice Chairman of the Council for the Development of Cambodia
Royal Government of Cambodia

**For the Development Partners:**

| | |
|---|---|
| ------------------------ | ------------------------ |
| Yvon Roé d'Albert<br>Ambassador of France | Takahashi Fumiaki<br>Ambassador of Japan |
| ------------------------ | ------------------------ |
| Lisa K. Filipetto<br>Ambassador of Australia | Pius Fischer<br>Ambassador of the Federal Republic of Germany |
| ------------------------ | ------------------------ |
| David G. Reader<br>Ambassador of the United Kingdom | Donica Pottie<br>Ambassador of Canada |
| ------------------------ | ------------------------ |
| Mogens L. Christensen<br>Minister Counsellor<br>DANIDA Resident Representative | Eva Gibson Smedberg<br>Counselor<br>SIDA Resident Representative |
| ------------------------ | ------------------------ |
| Lynn de Silva<br>First Secretary and NZAID Manager<br>Thailand, Cambodia, Lao PDR, Myanmar<br>NZAID | Piper A. W. Campbell<br>Chargé d'Affaires<br>Embassy of the United States of America |

Alain Goffeau
Acting Country Director
Asian Development Bank

Daniel Costa Llobet
Chargé d'Affaires a.i
European Commission

Douglas Gardner
UN Resident Coordinator

Nisha Agrawal
Country Manager
World Bank

## ឧបសម្ព័ន្ធ ២: តួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល

ភារៈកិច្ចចំបងរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលរួមមាន :

- ផ្តល់ការប្រជុំ ដើម្បីចែករំលែកពត៌មានរវាងដៃគូអ្នកផ្តល់ជំនួយសំខាន់ៗ (Stakeholders)
- ផ្តល់ប្រឹក្សាដល់ក្រសួងសុខាភិបាលលើបញ្ហាគោលនយោបាយ និងយុទ្ធសាស្ត្រ
- ផ្តល់ការត្រួតពិនិត្យឡើងវិញដល់ការកែទំរង់ថ្នាក់តំបន់
- សំរបសំរួលសុខដុមនីកម្ម និងការដើរស្របគ្នាក្នុង និង អន្តរវិស័យ(intra-sector and inter-sector)

គោលបំណងរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលរួមមាន :

១. ពិនិត្យឡើងវិញលើការរីកចំរើន ពិភាក្សាបញ្ហា និងផ្តល់ទស្សនៈទៅលើការរៀបចំ ការអនុវត្ត និងការគ្រប់គ្រង ផែនការយុទ្ធសាស្ត្រសុខាភិបាល ។

២. ជំរុញឱ្យមានការរីកចំរើន នៃការគ្រប់គ្រងវិស័យទូលំទូលាយ (SWiM) ដើម្បីរីកចំរើនឆ្ពោះទៅ អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងវិស័យទូលំទូលាយ (SWAp) នៅក្នុងវិស័យសុខាភិបាល ។

៣. ជំរុញឱ្យមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនូវធនធានដែលមានកំណត់នៅក្នុងវិស័យសុខាភិបាល តាមរយៈ ការកំណត់ជាអាទិភាព, ការសំរបសំរួល និងការធ្វើការងាររួមគ្នា និងដោយតាមរយៈការប្រើប្រាស់ក្របខ័ណ្ឌផែនការចំណាយមធ្យម (Midium-term expenditure framework) ។

៤. ពិនិត្យឡើងវិញពីការរីកចំរើន និងផ្តល់យោបល់លើការអភិវឌ្ឍន៍ និងការអនុវត្តផែនការអនុវិស័យទាំងអស់ (Sub-sector plans)

៥. ពិភាក្សា និងផ្តល់ប្រឹក្សាពីផែនការទាំងឡាយសំរាប់ការពិនិត្យប្រចាំឆ្នាំ និងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្ត និងធ្វើការវាយតំលៃចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រ សុខាភិបាល និងដើម្បីធានាថាការរកឃើញពីការពិនិត្យឡើង វិញទាំងនេះ គឺត្រូវទុកពិចារណាក្នុងការរៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំ និងផែនការផ្លាស់ប្តូរ ៣ឆ្នាំបន្តទៀត (3 year rolling plan)

៦. ពិភាក្សាពីការទំនាក់ទំនងវិស័យសុខាភិបាលដើម្បីពង្រីកការផ្តើមគំនិតរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រ និងធានាឱ្យបាននូវធនធានគ្រប់គ្រាន់សំរាប់វិស័យសុខាភិបាល ដើម្បីដាក់បញ្ចូលទៅក្នុងដំណើរការប្រជុំកិច្ចសហការអភិវឌ្ឍន៍កម្ពុជា (CDCF) ។

៧. ពិភាក្សាបញ្ហាដែលមានទំនាក់ទំនងគ្នា និងផ្តល់ជាទស្សនៈទាំងឡាយដើម្បីការកែទំរង់បើកចំហរបស់រដ្ឋាភិបាល ដូចជារដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុ វិមជ្ឈការ និងការអភិបាលកិច្ច ដោយរួមសហការជាមួយ គណកម្មការសំរបសំរួលជំនួយរដ្ឋាភិបាល (GDCC) ។

៨. ធានាក្នុងការចែករំលែកពត៌មានឱ្យបានទៀងទាត់ពីដៃគូវិស័យសុខាភិបាលស្តីពីការរីកចំរើនក្នុងការអនុវត្ត គំរោង និងពិនិត្យផែនការទាំងអស់ឡើងវិញ សំរាប់កម្មវិធី/គំរោងថ្មីៗ ធានានូវអោយមាន ពាក់ព័ន្ធគ្នា ចៀសវៀងការត្រួតស៊ីគ្នា ។

៩. បង្កើនការត្រួតពិនិត្យ និងវាយតំលៃការរីកចំរើន តាមរយៈការប្រើប្រាស់សូចនករណ៍ ដែលព្រមព្រៀងគ្នាទាំងអស់ ដោយរួមបញ្ចូលទាំង សូចនករណ៍ CMDG និងសូចនករណ៍ត្រួតពិនិត្យរួម (JMIs) ហើយត្រូវវាយការណ៍ឱ្យបានទៀងទាត់ពីទិសដៅនិងគំរូ (targets and benchmarks)ទាំងអស់ ។

១០. ពិនិត្យមើលលទ្ធផល និងផ្តល់យោបល់ស្តីពីការសារៈសំខាន់នៃការផ្តួចផ្តើមការសាកល្បង ការផ្តល់សេវាកម្ម ហិរញ្ញប្បទានសុខាភិបាល ការគ្រប់គ្រង និងការរីកចំរើនផ្នែកគុណភាព និងធានាថា បទពិសោធន៍ ដែលបានទទួល ត្រូវបានប្រើប្រាស់សំរាប់ការអនុវត្តគោលនយោបាយ ។

១១. ពង្រឹងទំនាក់ទំនង និងយន្តការកិច្ចសហប្រតិបត្តិការជាមួយអនុក្រុមការងារបច្ចេកទេសសុខាភិបាល និងក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត ដើម្បីសំរបសំរួលឱ្យបានជោគជ័យ នៃគោលបំណងសុខដុមនីយកម្ម និងការតំរង់ទិសនៅថ្នាក់ប្រតិបត្តិ។

បន្ថែមលើការងារប្រចាំថ្ងៃនៃការពិនិត្យរបាយការណ៍វឌ្ឍនៈភាព និងសិក្សាវិភាគ និងផ្តល់ពត៌មានផ្សេងៗ ទៅដល់ការរៀបចំផែនការវិស័យ។ ក្រុមការងារបច្ចេកទេសសុខាភិបាល មានមុខងារកិរិតខ្ពស់បន្ថែមថែមទៀត ដូចជា :

- កំណត់ យុទ្ធសាស្ត្រនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិទាំងអស់ អាទិភាព និង សូចនករណ៍ ។
- កំណត់ប្រភពទិន្នន័យទាំងឡាយសំរាប់ការត្រួតពិនិត្យ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ពិនិត្យយល់ព្រមលើការងារវិភាគបន្ថែម ដើម្បីបង្កើនការត្រួតពិនិត្យ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- បង្កើត និងត្រួតពិនិត្យ សូចនករណ៍ត្រួតពិនិត្យរួម សំរាប់វិស័យសុខាភិបាល ដែលមានការពាក់ព័ន្ធជាមួយគោលដៅកំណត់ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- រាយការណ៍ជូន គណកម្មការសំរបសំរួលជំនួយរវាងរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយ ស្តីពីសូចនករណ៍ត្រួតពិនិត្យរួម ផែនការសកម្មភាពដែលផ្តោតលើលទ្ធផល, ការតំរង់ទិស និងសុខដុមនីយកម្ម(H-A-R) និងការការប្រតិបត្តិផែនការសកម្មភាព នៃក្រុមការងារបច្ចេកទេសសុខាភិបាល
- តាមដានរាល់ការពិភាក្សាដែលពាក់ព័ន្ធទាំងឡាយ ដែលធ្វើឡើងនៅ គណកម្មការសំរបសំរួលជំនួយរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ នៅក្នុងការប្រជុំកិច្ចសហការអភិវឌ្ឍន៍កម្ពុជា ។ កំណត់បញ្ហាទាំងឡាយដែលត្រូវដាក់ជូនពិភាក្សានៅថ្នាក់លើ (Higher-level fora) ។

**ឧបសម្ព័ន្ធ ៣: តួនាទី និងភារៈកិច្ចរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត**

តួនាទី និងភារៈកិច្ចចំបងរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្តរួមមាន :

- ពង្រឹងកិច្ចសហប្រតិបត្តការរវាងមន្ទីរសុខាភិបាលខេត្ត និងដៃគូអភិវឌ្ឍន៍ទាំងអស់របស់ខ្លួនដោយរួមបញ្ចូលទាំង វិស័យដទៃទៀតរបស់រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ដោយសង្កត់ធ្ងន់ទៅលើសុខដុមនីយកម្មសកម្មភាពជាដៃគូ ប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានដែលមាន និងធ្វើការត្រួតពិនិត្យ និងវាយតំលៃការអនុវត្តន៍ផែនការសុខាភិបាលខេត្ត ។
- ធានាឱ្យមានការទំនាក់ទំនងសហប្រតិបត្តការរវាង ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត និងក្រុមការងារបច្ចេកទេសសុខាភិបាល តាមរយៈការធ្វើរបាយការណ៍ និងយន្តការផ្តល់ពតិមានត្រឡប់ ។

**ដើម្បីអនុវត្តតួនាទី និងភារកិច្ចទាំងនេះ ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្តត្រូវមានមុខងារដូចខាងក្រោម :**

១. ធានាឱ្យបាននូវផែនការប្រតិបត្តការប្រចាំឆ្នាំថ្នាក់ខេត្ត (Pro AoP) ដែលរួមបញ្ចូលទាំងសកម្មភាពធនធានដែលមានទាំងអស់ពីអង្គការក្រៅរដ្ឋាភិបាល តាមរយៈការចូលរួមពីសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលទាំងអស់ ក្នុងដំណើរការធ្វើផែនការប្រចាំឆ្នាំរបស់ខេត្ត ។

២. គៀងគរធនធានបន្ថែមទៀតពីគ្រប់ប្រភពធនធានទាំងអស់ ដើម្បីជួយជ្រោមជ្រែងដល់ការអនុវត្តន៍ផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំរបស់ខេត្ត រួមជាមួយសកម្មភាពភាពបន្ទាន់នៅពេលណាដែលចាំបាច់ ដូចជាការគ្រប់គ្រងការកើតជំងឺរាតត្បាត ឬការធ្វើអន្តរគមន៍លើគ្រោះមហន្តរាយផ្នែកសុខភាពនានា ។

៣. ធានាថាធនធានដែលមានទាំងអស់ត្រូវបានប្រើប្រាស់ឱ្យមានប្រសិទ្ធិភាព និងសន្សំសំចៃខ្ពស់តាមដែលអាចធ្វើទៅបាន ។

៤. តាមដានត្រួតពិនិត្យការរីកចំរើន និងសមិទ្ធិផល នៃការអនុវត្តសកម្មភាពសុខាភិបាលទាំងអស់នៅទូទាំងខេត្ត តាមរយៈការ ពិនិត្យ និងពិភាក្សាជាទៀងទាត់រៀងរាល់ត្រីមាស និងប្រចាំឆ្នាំ ពីផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ខេត្ត និងផែនការអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូរ ដោយរួមបញ្ចូលទាំងអនុសាសន៍សំរាប់ការអនុវត្តនៅពេលខាងមុខ ។

៥. ជំរុញឱ្យមានតម្លាភាពកាន់តែប្រសើរឡើង ក្នុងការចែករំលែកពតិមាន ការធ្វើផែនការ ការចាត់ចែងថវិកា និង របាយការណ៍ហិរញ្ញវត្ថុ នៃមន្ទីរសុខាភិបាលខេត្ត និងដៃគូអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ។

៦. ផ្តល់យោបល់លើការរៀបចំគំរោងថ្មីៗ ដើម្បីធានាឱ្យមានការពាក់ព័ន្ធគ្នា ជាមួយផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល និងការងារជាអាទិភាពទាំងអស់របស់ខេត្ត ។

៧. ពិនិត្យមើលលទ្ធផលនៃការអនុវត្តទាំងអស់ ដែលបានផ្តួចផ្តើមសាកល្បងទាំងឡាយនៅក្នុងខេត្ត (ដូចជា មូលនិធិសមធម៌ ប្រព័ន្ធបញ្ជូនជំងឺ ការពង្រឹងគុណភាព ជាដើម) ។ ពិភាក្សាពីបទពិសោធន៍ និងផ្តល់អនុសាសន៍ល្អៗ ជូនដល់អ្នកធ្វើគោលនយោបាយ តាមរយៈក្រុមការងារបច្ចេកទេសសុខាភិបាល ។

៨. ធានាឱ្យមានប្រសិទ្ធភាពនូវទំនាក់ទំនងរវាងក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត និងក្រុមការងារបច្ចេកទេសសុខាភិបាលក្រសួង តាមរយៈការផ្តល់របាយការណ៍ និងពត៌មានត្រឡប់ ។

## ឧបសម្ព័ន្ធ ៤: សេចក្តីថ្លែងពីបំណងផ្តួចផ្តើមសកម្មភាពថ្មីក្នុងវិស័យសុខាភិបាលកម្ពុជា

### ១. ឈ្មោះស្ថាប័ន

### ២. ប្រភេទស្ថាប័ន

*(អ្នកផ្តល់ជំនួយពហុភាគី ទ្វេភាគី ទីភ្នាក់ងារផ្តល់ជំនួយបច្ចេកទេស អង្គការក្រៅរដ្ឋាភិបាលជាតិ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ។ល។)*

### ៣. ឈ្មោះ និងពត៌មាន សំរាប់ទំនាក់ទំនង

### ៤. ចំណុចផ្តោតចំបងដែលស្នើរសុំ

*ផ្តល់នូវគំនូសបង្ហាញជាទូទៅ នៃការចាប់ផ្តើមគំនិតសំរាប់សុខភាព (សរសេរ ២-៣ ប្រយោគ)*

**ទីតាំងចំបងនៃសកម្មភាពគំរោង/កម្មវិធី: *(សូមគូសយកទាំងអស់បើមានទាំងអស់)***

| | អនុវិស័យចំបងៗ | អនុវិស័យបន្ទាប់បន្សំ |
|---|---|---|
| គាំពារសុខភាពមាតា និងទារក | | |
| ប្រយុទ្ធនឹងជំងឺឆ្លង | | |
| ជំងឺមិនឆ្លង/បញ្ហាសុខភាពដទៃទៀត | | |
| ការអភិវឌ្ឍន៍ស្ថាប័ន/ការពង្រឹងវិស័យសុខាភិបាល | | |

**បញ្ជាក់ពីគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា : *(សូមគូសយកទាំងអស់បើមានទាំងអស់)***

| | | តំបន់ធ្វើការចំបង | តំបន់ធ្វើការបន្ទាប់ |
|---|---|---|---|
| CMDG 4 | កាត់បន្ថយអាត្រាស្លាប់កុមារ | | |
| CMDG 5 | បង្កើនការគាំពារសុខភាពមាតា | | |
| CMDG 6 | ប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ របេង និងជំងឺដទៃទៀត | | |
| CMDG 7 | បង្កើនលទ្ធភាពប្រើប្រាស់ទឹកស្អាត និង អនាម័យជាមូលដ្ឋាន | | |

### ៥. ទីតាំងភូមិសាស្ត្រ

### ៦. រយះពេលគំរោង

### ៧. ថវិកា

## ឧបសម្ព័ន្ធ ៥: ទិន្នន័យដែលទទួលបានពីការលើកឡើងក្នុងកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត

**រយៈពេលគ្របដណ្តប់នៃរបាយការណ៍**

| ឈ្មោះខេត្ត | ចំនួនកិច្ចប្រជុំ | លទ្ធផលសំខាន់ៗ | បញ្ហាប្រឈម និងបញ្ហាដែលត្រូវតាមដាន | អនុសាសន៍ពី ក្រុមការងារបច្ចេកទេសសុខាភិបាល |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
១៥១-១៥៣ វិថីកម្ពុជាក្រោម
ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: ០២៣ ៧២២ ៤៦៥

# របាយការណ៍វឌ្ឍនៈភាពប្រចាំឆមាសរបស់ទីភ្នាក់ងារអនុវត្តន៍គំរោង

**(ឈ្មោះរបស់អង្គការ)**
**(ឈ្មោះរបស់គំរោងឬកម្មវិធី)**
**(លេខគំរោង)**

**(លេខរបាយការណ៍)**
**(រយៈពេលគ្របដណ្តប់នៃរបាយការណ៍)**

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
កែសំរួលលើកចុងក្រោយ ខែសីហា ឆ្នាំ២០០៧

## ១. ឈ្មោះរបស់គំរោងឬកម្មវិធី

សូមប្រគល់របាយការណ៍ដាច់ដោយឡែកពីគ្នាសំរាប់គំរោងឬកម្មវិធីដែលមានកិច្ចព្រម ព្រៀងផ្សេង១គ្នា ។ ប្រសិនបើគំរោងដែលអនុវត្តស្ថិតនៅច្រើនទីកន្លែង សូមប្រគល់ ពតិមានហិរញ្ញវត្ថុរបស់គំរោងនោះ ពីគ្រប់ទីកន្លែងនីមួយ១ (សូមមេត្តាមើលទៅលើ ផ្នែកទី ១១)

## ២. រយៈពេលគ្របដណ្តប់នៃរបាយការណ៍របស់គំរោងឬកម្មវិធី

របាយការណ៍របស់គំរោងគួតែប្រគល់រៀងរាល់ប្រាំមួយខែម្តងនិងមានចុះលេខរបាយការណ៍ត្រឹមត្រូវ ។

## ៣. ទីកន្លែងរបស់គំរោងឬកម្មវិធី

បង្ហាញគ្រប់ឈ្មោះរបស់ឃុំ ស្រុក ខេត្ត មន្ទីរពេទ្យ វិទ្យាស្ថាន ។ល។ ដែលនិងត្រូវលើក មកបង្ហាញនៅក្នុងរបាយការណ៍នេះ ។ ទីកន្លែងនេះគួមានលក្ខណៈដូចគ្នាទៅនិងទីកន្លែង ដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀង (កិច្ចព្រមព្រៀងដំបូង កិច្ចព្រមព្រៀងបន្ត ឬ កិច្ចព្រមព្រៀងដែលត្រូវបន្ត) ។ នៅក្នុងករណីដែលមានការផ្លាស់ប្តូរទីកន្លែង គួតែមានការពន្យល់មួយច្បាស់លាស់ ។

## ៤. សកម្មភាពរបស់គំរោងឬកម្មវិធី

លទ្ធផលនៅក្នុងរបាយការណ៍កំឡុងពេលបច្ចុប្បន្ន និងគោលបំណងចំបងបន្ថែម នៃកម្មវិធីឬគំរោង

សូមបង្ហាញអំពីកម្មវត្ថុសំខាន់១របស់កម្មវិធីឬគំរោង ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ។ សំរាប់កម្មវត្ថុនីមួយ១សូមបង្ហាញសូចនករគន្លឹះនិងបង្ហាញអំពីលទ្ធផលសំរាប់ របាយការណ៍ក្នុងកំឡុងពេលនេះ និងបន្ថែមអ្វីដែលជាស្នាដៃទទួលបានទៅលើការងារ នេះ ។ លើកយកចំណុចសំខាន់១សំរាប់ផ្លាស់ប្តូរណាមួយ (អាចបន្ថែមបន្ទាត់សំរាប់សរសេរក្នុងករណីដែលចាំបាច់)

| លរ | សូចនករគន្លឹះ | ដើមគ្រា(ឆ្នាំ) | គោលដៅសំរាប់ របាយការណ៍ នៅក្នុងគ្រាបច្ចុប្បន្ន | លទ្ធផលសំរាប់ របាយការណ៍ នៅក្នុងគ្រាបច្ចុប្បន្ន | គោលដៅបន្ថែម | លទ្ធផលបន្ថែម | ហេតុផលសំរាប់ការ ផ្លាស់ប្តូរណាមួយ |
|---|---|---|---|---|---|---|---|
| គោលបំណងទី១ | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |

| គោលបំណងទី២ | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| គោលបំណងទី៣ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |

## ៥. ការបណ្តុះបណ្តាលបន្តរឬសិក្ខាសាលានៅក្នុងប្រទេសឬក្រៅប្រទេស

សង្ខេបអំពីការអប់រំឬអាហារូបករណ៍ដែលផ្តល់បុគ្គលិកសុខាភិបាលកម្ពុជា៖ សូមសរសេរពតិមានអំពីឈ្មោះនិងប្រភេទបុគ្គលិក ទីកន្លែង មុខវិជ្ជាដែលត្រូវសិក្សា និងពេលវេលាដែលត្រូវសិក្សា ។

| ឈ្មោះបុគ្គលិក | ប្រភេទរបស់បុគ្គលិក | ទីកន្លែង | មុខវិជ្ជាដែលសិក្សា | ពេលវេលា |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

## ៦. ស្នាដៃដែលនិងបទពិសោធន៍ដែលទទួលបាននៅក្នុងកំឡុងពេលគ្របដណ្តប់នៃរបាយការណ៍

សូមលើកយកស្នាដៃនិងបទពិសោធន៍សំខាន់ៗដែលទទួលបាននៅក្នុងកំឡុងពេលរបស់របាយការណ៍នេះសំរាប់កម្មវត្ថុរបស់កម្មវិធីនីមួយៗ

| កម្មវត្ថុរបស់កម្មវិធី | ស្នាដៃដែលទទួលបាន | បទពិសោធន៍ដែលបានរៀនសូត្រ |
|---|---|---|
| | | |
| | | |
| | | |

## ៧. ឧបសគ្គនិងអនុសាសន៍សំរាប់ដំណោះស្រាយ

សូមបង្ហាញអំពីឧបសគ្គនៅក្នុងការអនុវត្តន៍និងអនុសាសន៍សំរាប់កំណត់ឧបសគ្គ៖

| ឧបសគ្គ | អនុសាសន៍ |
| --- | --- |
| | |
| | |
| | |

សូមផ្តល់យោបល់ទៅលើវឌ្ឍនភាពឬអនុសាសន៍ទៅលើរបាយការណ៍ពេលមុន

| ឧបសគ្គ | អនុសាសន៍ | វឌ្ឍនភាព |
| --- | --- | --- |
| | | |
| | | |
| | | |

## ៨. លទ្ធកម្មនៃសំភារៈសុខាភិបាល

សូមរំលងផ្នែកនេះក្នុងករណីដែលមិនជាប់ទាក់ទងទៅនិងគំរោងឬកម្មវិធីរបស់អ្នក ។ ក្នុងករណីដែលជាប់ទាក់ទង សូមបំពេញ សំភារៈឬផលិតផលដែលបានផ្តល់ឱ្យឬធ្វើលទ្ធកម្ម នៅក្នុងអំឡុងពេលរបស់របាយការណ៍ រួមទាំងពតិមានអំពីទីកន្លែង ថ្លៃចំណាយ និងរយៈពេលដែលអាចប្រើប្រាស់បានរបស់សំភារៈនីមួយៗ ។

| សំភារៈឬឧបករណ៍ | ទីកន្លែង | ថ្លៃសំភារៈ(គិតជាដុល្លាអាមេរិក) | រយៈពេលដែលអាចប្រើប្រាស់បាន |
| --- | --- | --- | --- |
| | | | |
| | | | |
| | | | |

## ៩. ជុសជុលនិងការសាងសង់

សូមរំលងផ្នែកនេះប្រសិនបើមិនមានជាប់ទាក់ទងទៅនិងគំរោងឬកម្មវិធីរបស់លោកអ្នក ។ ប្រសិនបើជាប់ទាក់ទង សូមបំពេញពតិមានខាងក្រោម:

ប្រភេទនៃអគា: (គ្លីនិច ប្រភេទនៃមន្ទីរពេទ្យ សាលារៀន រដ្ឋបាល ។ល។)

ទោះបីជាអគារកំពុងសាងសង់ថ្មីឬជុសជុលកែលំអរ

ទីកន្លែង: (ឃុំ ស្រុក ខេត្ត ។ល។)

ប្រភេទនៃសំណង់: (ឈើ បេតុង ចំនួនបន្ទប់ ដំបូលរាបស្មើឬដូចដំបូលទូក)

សំភារៈបំពាក់បន្ថែម: (អាងដាក់ទឹក បង្គន់)

បរិមាណនៃការចំណាយសំរាប់ការសាងសង់ឬផ្លាស់ប្តូនៅក្នុងកំឡុងពេលរបស់របាយការណ៍

ប៉ាន់ប្រមាណអំពីលទ្ធភាពដែលអាចបញ្ចប់ការងារនេះ នៅក្នុងចុងគ្រារបស់របាយការណ៍

ប៉ាន់ប្រមាណអំពីពេលវេលាសំរាប់បញ្ចប់ការងារនេះ ។

| ប្រភេទនៃអគា | កំពុងសាងសង់ ឬផ្លាស់ប្តូរទីកន្លែង | ទីកន្លែង | ប្រភេទនៃសំណង់ | សំភារៈបំពាក់បន្ថែម | ទឹកប្រាក់ | លទ្ធភាពដែល អាចបញ្ចប់ការងារ នេះ | ពេលវេលា សំរាប់បញ្ចប់ ការងារនេះ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## ១០. ចំណុចសំខាន់ៗរបស់សកម្មភាព ការវិនិយោគ ឬផែនការដែលត្រូវផ្លាស់ប្តូរចំពោះ របាយការណ៍ក្នុងគ្រាបន្ទាប់

| ផែនការសកម្មភាពសំខាន់ៗ | សំណើវិនិយោគលើសំភារៈ | សំណើជុសជុលឬសាងសង់ថ្មី | ការផ្លាស់ប្តូរសំខាន់ៗរបស់កម្មវត្ថុឬ គោលដៅរបស់គំរោងឬកម្មវិធី (ផ្តល់ហេតុផលនៃការផ្លាស់ ប្តូ) |
|---|---|---|---|
| | | | |
| | | | |
| | | | |

## ១១. របាយការណ៍ហិរញ្ញវត្ថុ

នៅក្នុងករណីដែលគំរោងត្រូវបានអនុវត្តលើសពីមួយទីកន្លែង (ឧទាហរណ៍: ស្រុកប្រតិបត្តិ) សូមផ្តល់កម្មវិធី ចំណាយសំរាប់ទីកន្លែងនីមួយៗ ។

| ការចំណាយ(គិតជារូបិយប័ណ្ណជាតិ) | | |
|---|---|---|
| | ការចំណាយនៅក្នុងកំឡុងពេលរបស់របាយការណ៍នេះ | ការចំណាយបន្ថែមរហូតមកដល់ពេល(កាលបរិច្ឆេទ) |
| ១. ប្រាក់បៀវត្ស<br>ថ្លៃចំណាយនៅការិយាល័យ | | |

| | | |
|---|---|---|
| កណ្តាល | | |
| ២. ឧបករណ៍ឬយានជំនិះ | | |
| ៣. ចំណាយទៅលើសកម្មភាពកម្មវិធី (សូមបែងចែករវាងការចំណាយរបស់គំរោងដែលស្ថិតនៅក្នុងទីកន្លែងផ្សេងគ្នា) | | |
| ទីកន្លែងទី ១ | | |
| ទីកន្លែងទី ២ | | |
| ទីកន្លែងទី ៣ | | |
| សរុបការចំណាយរបស់កម្មវិធី | | |
| សរុបថវិកាដែលត្រូវចំណាយ | | |

## តារាងនៃការបែងចែកថវិការគួតែមានទំរង់ដូចគ្នាទៅនិងតារាងនៅក្នុងកិច្ចសន្យា

| ការបែងចែកថវិការ (គិតជារូបិយប័ណ្ណជាតិ) | | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប |
| ឆ្នាំ | | | | | | |
| ១. ប្រាក់បៀវត្ស ការចំណាយនៅការិយាល័យកណ្តាល | | | | | | |
| ២. ឧបករណ៍ឬយានជំនិះ | | | | | | |
| សូមផ្តល់កម្មវិធីថវិកាផ្សេងៗគ្នាសំរាប់គំរោងដែលមានកន្លែងផ្សេងគ្នា | | | | | | |
| ៣. ចំណាយសកម្មភាពរបស់កម្មវិធី | | | | | | |
| ទីកន្លែងទី ១ | | | | | | |
| ទីកន្លែងទី ២ | | | | | | |
| ទីកន្លែងទី ៣ | | | | | | |
| សរុបការចំណាយរបស់កម្មវិធី | | | | | | |
| សរុបថវិកាដែលត្រូវចំណាយ | | | | | | |

## ២. ការរៀបចំនិងគ្រប់គ្រងទៅលើរបាយការណ៍

រៀបចំរបាយការណ៍ដោយ កាលបរិច្ឆេទ

ចុះហត្ថលេខា ជ.ទីភ្នាក់ងារអនុវត្តផ្ទាល់ កាលបរិច្ឆេទ

ឈ្មោះ

តួនាទី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
១៥១-១៥៣ វុក្ខវិថីកម្ពុជាក្រោម
ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: ០២៣ ៧២២ ៤៦៥

# អង្គការក្រៅរដ្ឋាភិបាលជាតិ_អន្តរជាតិ និងទីភ្នាក់ងារអនុវត្តដោយផ្ទាល់

## កិច្ចព្រមព្រៀងរវាង

**(ឈ្មោះរបស់អង្គការ)**

**(ឈ្មោះរបស់គំរោងឬកម្មវិធី)**

**(កាលបរិច្ឆេទ)**

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**

កែសំរួលលើកចុងក្រោយ ខែសីហា ឆ្នាំ២០០៧

## ១. ពត៌មានលំអិតរបស់ទីភ្នាក់ងារអនុវត្តគំរោង

ឈ្មោះអង្គការ:

ប្រភេទរបស់អង្គការ ( អង្គការជាតិឬអន្តរជាតិ ឬទីភ្នាក់ងារអនុវត្តដោយផ្ទាល់ផ្សេងៗទៀត)

អាស័យដ្ឋាន:

លេខទូរសារ:

លេខទូរស័ព្ទ:

អ៊ីម៉េល:

ឈ្មោះសំរាប់ទំនាក់ទំនង:

ឈ្មោះរបស់គំរោង:

លេខកូដកិច្ចសន្យា:

លេខកូដគំរោងរបស់អង្គការ:

ទីកន្លែងរបស់គំរោង: (ឧទាហរណ៍ ខេត្ត ស្រុក ស្រុកប្រតិបត្តិ ឃុំ ភូមិ មណ្ឌលសុខភាព មន្ទីរពេទ្យ)

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តគំរោង:

កាលបរិច្ឆេទបញ្ចប់គំរោង:

កាលបរិច្ឆេទសំរាប់ពន្យារពេល ( ប្រសិនបើមាន)

ចំនួនបុគ្គលិកជាតិ:

ចំនួនបុគ្គលិកបរទេស:

តួលេខប៉ាន់ប្រមាណរបស់ទីប្រឹក្សារយៈពេលខ្លី

ជាតិ

អន្តរជាតិ

## ២. ពត៌មានសង្ខេបរបស់គំរោងឬកម្មវិធី

ផ្នែកសំខាន់ៗដែលគំរោងឬកម្មវិធីធ្វើសកម្មភាព: (ជ្រើសរើសគ្រប់ចំណុចដែលពាក់ព័ន្ធ)

| | គោលដៅសំខាន់ៗរបស់ការងារ | គោលដៅបន្ទាប់បន្សំរបស់ការងារ |
|---|---|---|

| | | |
|---|---|---|
| គាំពារសុខភាពមាតានិងទារក | | |
| ផ្នែកប្រយុទ្ធនឹងជំងឺឆ្លង | | |
| ផ្នែកមិនមែនជំងឺឆ្លង ឬបញ្ហាផ្សេងៗដែលទាក់ទងនិងសុខភាព | | |
| អភិវឌ្ឍស្ថាប័ន ឬការពង្រឹងវិស័យសុខាភិបាល | | |

កំណត់គោលដៅអភិវឌ្ឍសហសវត្សរបស់ប្រទេសកម្ពុជា (ជ្រើសរើសគ្រប់ចំណុចដែលពាក់ព័ន្ធ)

| | គោលដៅសំខាន់ៗរបស់ការងារ | គោលដៅបន្ទាប់បន្សំរបស់ការងារ |
|---|---|---|
| គោលដៅទី៤ កាត់បន្ថយអត្រាមរណៈរបស់កុមារ | | |
| គោលដៅទី៥ លើកកំពស់សុខភាពមាតា | | |
| គោលដៅទី៦ ប្រយុទ្ធនឹងជំងឺអេដស៍ គ្រុនចាញ់និងជំងឺផ្សេងៗទៀត | | |
| គោលដៅទី៧<br>លើកកំពស់លទ្ធភាពការប្រើប្រាស់ទឹកស្អាតនិងអនាម័យមូលដ្ឋាន | | |

## ៣. កម្មវត្ថុរបស់គំរោងឬកម្មវិធី

សូមលើកយកគោលបំណងសំខាន់ៗរបស់គំរោងឬកម្មវិធី ។ សំរាប់កម្មវត្ថុនីមួយៗ សូមបង្ហាញសូចនករគន្លឹះ ដើមគ្រា និងគោលដៅប្រចាំឆ្នាំ (ប្រសិនបើអាចធ្វើបាន) (អាចបន្ថែមបន្ទាត់សំរាប់សរសេរ ក្នុងករណីដែលចាំបាច់)

| លរ | សូចនករគន្លឹះ | ដើមគ្រា<br>(ប្រសិនបើអាចធ្វើបាន) (គិតជាឆ្នាំ) | គោលដៅ<br>ឆ្នាំទី១ | គោលដៅ<br>ឆ្នាំទី២ | គោលដៅ<br>ឆ្នាំទី៣ | គោលដៅ<br>ឆ្នាំទី៤ | គោលដៅ<br>ឆ្នាំទី៥ |
|---|---|---|---|---|---|---|---|
| គោលបំណងទី១ | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| គោលបំណងទី២ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| គោលបំណងទី៣ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |

## ៤. អធិប្បាយអំពីគំរោង

ពិពណ៌នាយ៉ាងសង្ខេបចំនួនមួយទំព័រជាអតិបរមាអំពីបំណងប្រាថ្នានិងគោលដៅរបស់គំរោងឬកម្មវិធី

## ៥. ទិន្នន័យហិរញ្ញវត្ថុ

អ្នកផ្តល់ជំនួយ (សូមសរសេរឈ្មោះពេញរបស់អ្នកផ្តល់ជំនួយ មិនសរសេរអក្សរកាត់ ក្នុងករណីដែលមានអ្នកផ្តល់ជំនួយច្រើនលើសពីមួយដល់គំរោង សូមធ្វើការបែងចែកពត៌មានលំអិតរបស់ថវិកាសំរាប់អ្នកផ្តល់ជំនួយនីមួយៗ)

រាល់បរិមាណហិរញ្ញវត្ថុត្រូវគិតជាដុល្លាសហរដ្ឋអាមេរិក ដោយគ្មានលេខទសភាគ ។

(អាចបន្ថែមបន្ទាត់សំរាប់សរសេរ ក្នុងករណីដែលចាំបាច់)

| ប្រភពថវិកា(គិតជារូបិយប័ណ្ណជាតិ) | | | | | | |
|---|---|---|---|---|---|---|
| អ្នកផ្តល់ជំនួយ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប |
| អ្នកផ្តល់ជំនួយទី១ | | | | | | |
| អ្នកផ្តល់ជំនួយទី២ | | | | | | |
| អ្នកផ្តល់ជំនួយទី៣ | | | | | | |
| អង្គការដែលទទួលថវិកាដោយផ្ទាល់ | | | | | | |
| សរុប | | | | | | |

| ប្រភពថវិកា(គិតជារូបិយប័ណ្ណជាតិ) | | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប |
| ឆ្នាំ | | | | | | |
| ១. ប្រាក់បៀវត្ស និងសកម្មភាពចំណាយរបស់ការិយាល័យ | | | | | | |
| ២. ឧបករណ៍ឬយានជំនិះ | | | | | | |
| (សូមផ្តល់ពត៌មានចំណាយរបស់កម្មវិធីនីមួយៗទៅតាមទីកន្លែងផ្សេងៗគ្នារបស់គំរោង) | | | | | | |
| ៣. ចំណាយទៅលើសកម្មភាពកម្មវិធី | | | | | | |
| ទីតាំងទី១ | | | | | | |
| ទីតាំងទី២ | | | | | | |
| ទីតាំងទី៣ | | | | | | |
| សរុបចំណាយរបស់កម្មវិធី | | | | | | |
| សរុបថវិកា | | | | | | |

## ៦. លក្ខន្តិកៈនៃកិច្ចព្រមព្រៀង

ក្រសួងសុខាភិបាលនិង..........................................................................បានព្រមព្រៀងដូចខាងក្រោមៈ

### មាត្រា ១

### លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ វិសាលភាពទូទៅរបស់កិច្ចសន្យានេះ សំរាប់ក្រសួងសុខាភិបាលនិង.......................... ដើម្បីសហការក្នុងការអភិវឌ្ឍ អនុវត្ត និងវាយតម្លៃនៃគំរោងឬកម្មវិធីនៅក្នុងប្រព័ន្ធថែទាំសុខាភិបាល និងផ្អែកទៅលើក្រសួងសុខាភិបាលបានកំណត់ទៅលើគោលនយោបាយណែនាំ ។

១.២ រាល់សកម្មភាពគំរោង ឬកម្មវិធីលំអិត និងត្រូវលើកយកមកពិភាក្សានិងយកមកសហប្រតិបត្តិការ ជាមួយមន្ទីរសុខាភិបាលខេត្តដែលពាក់ព័ន្ធឬកម្មវិធីជាតិ ។

១.៣ ទីតាំងសាងសង់ថ្មី ឬ ការជុសជុលសំណង់អគារណាមួយចាំបាច់ត្រូវអនុលោមទៅតាមផែនការគ្របដណ្តប់សុខាភិបាលសំរាប់ស្រុកនោះ ឬខេត្តនោះ នឹងត្រូវពិភាក្សាជាចាំបាច់និងត្រូវបានយល់ព្រមដោយ ក្រសួងសុខាភិបាលមុននឹងចាប់ផ្តើមការងារណាមួយ ។ ប្លង់ស្ថាបត្យកម្មនានា នឹងត្រូវអនុលោមទៅតាមកំរិតស្តង់ដាររបស់ជាតិ ។

១.៤ ទីភ្នាក់ងារអនុវត្តការងារដោយផ្ទាល់ ដោយធ្វើការជាដៃគូរបស់ក្រសួងសុខាភិបាល នឹងធ្វើការពិនិត្យមើលគំរោងនេះយ៉ាងតិចបំផុតរយៈពេលបីខែមុនពេលដែលគំរោងបញ្ចប់ ។ ក្រោយពេលពិនិត្យមើលគំរោងនេះ និងមានការសំរេចចិត្តរួមគ្នាមួយថាតើត្រូវបញ្ឈប់គំរោងនេះនៅពេលវេលាកំណត់ណាមួយឬបន្តរយៈពេលសំរាប់អនុវត្តគំរោងនេះ ។

១.៥ ច្បាប់ចំលងទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានរក្សាដោយក្រសួងសុខាភិបាល ហើយចែកជូនដល់មន្ទីរសុខាភិបាលខេត្ត និង កម្មវិធីជាតិ ដែលពាក់ព័ន្ធ ដើម្បីបង្កើតជាបទដ្ឋាន ណែនាំជាមូលដ្ឋានសំរាប់កិច្ចសហប្រតិបត្តិការ និងបំពេញការងារនៅកម្មវិធីជាតិ មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ ។

### មាត្រា ២

### ...........................................(ទីភ្នាក់ងារអនុវត្តដោយផ្ទាល់) យល់ព្រមៈ

២.១ ផ្តល់ការគាំទ្រចំពោះគោលនយោបាយរបស់សុខាភិបាលនិងកម្មវិធីជាតិ ដូចដែលបានជាប់ទាក់ទងទៅនិងកម្មវត្ថុខាងលើ ។ រាល់គ្លីនិកដែលធ្វើការព្យាបាលនឹងប្រតិបត្តិតាមពិធីសារនៃការថែទាំ និងឱសថដែលបានផ្តល់ជូនទាំងឡាយណាដែលយល់ព្រមប្រតិបត្តិតាមបញ្ជីឱសថសារវន្តរបស់ជាតិ ។ (មជ្ឈមណ្ឌលជំនាញមួយចំនួនអាចនិងត្រូវពិភាក្សាជាមួយក្រសួងសុខាភិបាលអំពីឱសថដែលមានតំរូវការ)

២.២ ធ្វើការសហការគ្រប់ពេលវេលាជាមួយភាគីកម្ពុជា ដើម្បីធ្វើការពង្រឹងសមត្ថភាពជាអតិបរមាមកដល់អ្នក

ឯកទេសកម្ពុជា ។

២.៣ ក្នុងករណីដែលអាចធ្វើបាន គូតែប្រើប្រាស់ឯកសារបណ្តុះបណ្តាល និង សំភារៈសិក្សាដែលមានស្រាប់របស់ក្រសួងសុខាភិបាល និងដាក់ជូនមកកាន់ក្រសួងសុខាភិបាលនូវកម្មវិធីនិងសំភារៈសិក្សាដែលធ្វើការពិនិត្យកែប្រែឬកម្មវិធីថ្មី មកកាន់ក្រសួងសុខាភិបាលតាមរយៈនាយកដ្ឋានអភិវឌ្ឍធនធានមនុស្សសំរាប់ធ្វើការអនុម័តឬកែប្រែមុនចាប់ផ្តើមការបណ្តុះបណ្តាល។

២.៤ ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពដើម្បីធានាថា រាល់សារអប់រំសុខភាព ស្របជាមួយគោលនយោបាយរបស់ក្រសួងសុខាភិបាល ។

២.៥ រាល់តួនាទីទាំងឡាយដែលទាក់ទងទៅនិងការបំពេញការងារនៅគ្លីនិកដោយផ្ទាល់ ត្រូវធ្វើការជ្រើសរើសតែបុគ្គលណាដែលបានចុះឈ្មោះជាមួយក្រសួងសុខាភិបាល ឬបុគ្គលណាដែលមានសមត្ថភាពនិងទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបញ្ជូនឈ្មោះមកកាន់ក្រសួងសុខាភិបាលដើម្បធ្វើការពិនិត្យទៅលើផ្នែកបច្ចេកទេស ប្រវត្តិរូបសង្ខេប ការគាំទ្រផ្សេង១ដោយថតចំលងនូវសញ្ញាប័ត្រឬវិញ្ញាបនប័ត្រ ផ្សេង១ ។

២.៦ ចូលរួមប្រជុំប្រចាំខែឱ្យបានទៀងទាត់ជាមួយក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត ដើម្បីចូលរួមចំណែក ក្នុងការរៀបចំផែនការ ការគ្រប់គ្រង ការចែករំលែកពតិមាននិងដោះស្រាយបញ្ហាផ្សេង១ ។

២.៧ ប្រើប្រាស់ថវិកាដែលបានអនុម័តឱ្យមានប្រសិទ្ធភាពដើម្បីឆ្លើយតបចំពោះគោលបំណងដែលបានកំណត់ ។

២.៨ ផ្តល់របាយការណ៍សកម្មភាពប្រចាំឆមាសដល់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិតាមទំរង់របាយការណ៍ដែលបានអនុម័តរួចហើយ ។

២.៩ ក្នុងករណីដែលបន្តឬកាត់បន្ថយរយៈពេលនៃការធ្វើគំរោង និងត្រូវពិភាក្សាជាមួយក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្ត ឬ កម្មវិធីជាតិ និងក្រោយពេលដែលមានថវិកាគ្រប់គ្រាន់កិច្ចព្រមព្រៀងថ្មីជាមួយ និង ពតិមានសមស្របនឹងត្រូវបានចុះហត្ថលេខា ។

២.១០ គ្រប់របាយការណ៍ ឬអត្ថបទដែលត្រូវបោះពុម្ព ដែលបានមកពីកិច្ចសហប្រតិបត្តិការរបស់គំរោង គូតែដាក់ជូនមកក្រសួងសុខាភិបាលដើម្បីមានមតិយោបល់ និងចាត់ទុកជាកម្មសិទ្ធិរួមគ្នារវាងអង្គការ និងក្រសួងសុខាភិបាលជាមួយនិងការទទួលស្គាល់ទាំងសងខាង ។

## មាត្រាទី ៣

## ក្រសួងសុខាភិបាលយល់ព្រមៈ

៣.១ អនុញ្ញាតឱ្យមានដៃគូសមរម្យ (នៅក្រសួងសុខាភិបាល កម្មវិធីជាតិ វិទ្យាស្ថានជាតិ ខេត្តនិងឬស្រុក) ដើម្បីបំពេញការងារជាមួយបុគ្គលិករបស់ទីភ្នាក់ងារអនុវត្តដោយផ្ទាល់ ដើម្បីបំពេញសកម្មភាពគំរោងឱ្យបានត្រឹមត្រូវ និងទាន់តាមពេលវេលា ។

៣.២ ទីភ្នាក់ងារអនុវត្តគំរោងដោយផ្ទាល់អាចធ្វើការជួលបុគ្គលិកជាជនជាតិខ្មែរដោយសមស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

៣.៣ លើកកំពស់ប្រសិទ្ធភាពនិងតម្លាភាព ក្នុងការចាត់ចែងសេវាសុខាភិបាល ដោយធានាថា អង្គការទទួលពតិមានតាមពេលកំណត់ ស្តីអំពីការរកបុគ្គលិកធ្វើការនៅវិជ្ជាស្ថានជាតិ ស្រុក ខេត្តនានា អំពីហិរញ្ញវត្ថុ និងការចំណាយ ដែលជាសកម្មភាពចាំបាច់ដើម្បីចាត់ចែងអោយមានប្រសិទ្ធភាពនូវគំរោងកម្មវិធី ហើយនិងធានាប្រាកដថា គំរោងកម្មវិធីនេះ គឺបន្ថែមទៅលើថវិការបស់ខេត្ត ឬស្រុកនានា របស់វិជ្ជាស្ថានជាតិ និងសកម្មភាពការងារនានា ។

៣.៤ ធានាប្រាកដថាខេត្ត ស្រុក កម្មវិធីជាតិ ឬវិទ្យាស្ថាន លើកកំពស់ការប្រាស្រ័យទាក់ទងយ៉ាងទូលាយ ជាមួយនិងអង្គការដើម្បីធ្វើជួយធ្វើផែនការ ការគ្រប់គ្រង និងដោះស្រាយបញ្ហា ។

៣.៥ ធ្វើអោយមានឯកសារជាភាសាអង់គ្លេសឬបារាំងសំរាប់អោយអង្គការជាវិន្នូវអត្ថបទស្តីពីគោលនយោបាយជាតិ ផែនការជាតិ ពិធីសារជាតិនៃការព្យាបាលជំងឺសំខាន់ៗ បញ្ជីឱសថសារវ័ន្ត សៀវភៅ ក្បួនណែនាំ គ្រួតពិនិត្យជំងឺឆ្លង និងសំភារៈដែលគេបានយល់ព្រមផ្សេងៗ ដើម្បីណែនាំលើការងារព្យាបាល និងសកម្មភាព ។

## មាត្រា ៤

## ខ_សន្យានូទៅ

៤.១ នាយកនៃគំរោង.............................................................................
ឬតំណាងដែលគេជ្រើសរើសជាផ្លូវការ ឬអនុញ្ញាតដោយអង្គការធ្វើការងារក្នុងនាមអង្គការរបស់ខ្លួនជាមួយក្រសួងសុខាភិបាល ។

៤.២ វិសោធនកម្មជាលាយល័ក្ខអក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវចុះហត្ថលេខាដោយភាគីទាំងពីរបន្ទាប់ពីការគិតគូរពិចារណាត្រឹមត្រូវ ។

៤.៣ កិច្ចព្រមព្រៀងនេះអាចនិងត្រូវបញ្ចប់នៅក្នុងស្ថានភាពបន្ទាន់ណាមួយដោយការសំរេចចិត្តរួមគ្នារវាង មន្ត្រីផ្លូវការរបស់ក្រសួងសុខាភិបាលនិងទីភ្នាក់ងារអនុវត្តគំរោងក្រោយពេលដែលមានពិគ្រោះ និងសំរេចរួមគ្នា ។

៤.៤ ................................... នឹងត្រូវបានផ្តល់សិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះក្រោយ ពីការពិភាក្សាជាមួយក្រសួងសុខាភិបាល ប្រសិនបើគេឃើញថា កិច្ចសហប្រតិបត្តិការនោះមានលក្ខណៈមិនគ្រប់គ្រាន់ សំរាប់ការអនុវត្តន៍ដោយមានប្រសិទ្ធភាពនៃគំរោងកម្មវិធី ឬឃើញថាសន្តិសុខនៃបុគ្គលិករបស់ខ្លួន ឬទ្រព្យសម្បត្តិ ត្រូវមានគ្រោះថ្នាក់ដោយសង្គ្រាម ឬអំពើប្រទូស្តរាយទាំងឡាយ ឬការចលាចលដ៏ធ្ងន់ធ្ងរផ្សេងៗ ។

៤.៥ ក្រសួងសុខាភិបាលក្រោយពេលដែលធ្វើការពិភាក្សាជាមួយអង្គការ និងផ្អែកលើដំបូន្មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គួមានសិទ្ធិធ្វើការស្នើសុំ................................ ដើម្បីធ្វើការបញ្ឈប់បុគ្គលដែលកំពុងបំពេញការងារ ហើយដែលត្រូវវិនិច្ឆ័យទៅឃើញថាធ្វើអោយខូចកិត្តិយសក្រសួង ឬកំពុងប្រកាន់ចរិយាក្នុងលក្ខណៈមិនវិជ្ជាជីវៈ ។ ប្រសិនបើមានសំណើសុំបែបនេះត្រូវបានធ្វើឡើងនោះ អង្គការគួរតែធ្វើទៅតាមបែបបទដែលកំណត់នោះ ។

៤.៦ ក្រសួងសុខាភិបាលក្រោយពេលធ្វើការពិភាក្សាជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានផ្តល់សិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះប្រសិនបើអ្នកតំណាងអង្គការ... ត្រូវបានរកឃើញថាមិនបានបំពេញទៅតាមមាត្រាទីពីរនៃកិច្ចសន្យានេះ ។

៤.៧ ក្នុងករណីដែលច្បាប់ជាធរមាននៅកម្ពុជាមិនត្រូវបានគោរពដោយអង្គការ................ក្រសួងសុខាភិបាល បន្ទាប់ពីបានជូនពតិមានត្រឹមត្រូវទៅអង្គការនេះរួចមកក្រសួងសុខាភិបាលអាចបញ្ចប់កិច្ចព្រមព្រៀងនេះ ។

៤.៨ កិច្ចព្រមព្រៀងនេះនឹងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខាហើយ និងនៅតែមានប្រសិទ្ធភាពរហូតដល់ គំរោងកម្មវិធីធ្វើការបញ្ចប់តាមកាលបរិច្ឆេទ ។

កិច្ចព្រមព្រៀងនេះ ត្រូវបានរៀបចំឡើងដោយឥតកែប្រែជាអត្ថបទដើម២ច្បាប់ខ្មែរ និងអង់គ្លេសហើយ អត្ថបទទាំងអស់ត្រូវបានទទួលស្គាល់ថាពិតជាត្រឹមត្រូវដូចគ្នា និងមានតំលៃស្មើគ្នា ។

កាលបរិច្ឆេទចុះហត្ថលេខា...................................... ២០០....

នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ះត្ថលេខា

| | |
|---|---|
| ក្រសួងសុខាភិបាល | ទីភ្នាក់ងារអនុវត្តគំរោង |
| ឈ្មោះ | ឈ្មោះ |
| ុខងារ | មុខងារ |

ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៧

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**

# Working Paper

ភ្នំពេញ

ខែសីហាឆ្នាំ២០០៧

មាតិកា

១. ប្រវត្តិនិងសេចក្ដីផ្ដើម ១
២ គំរូការធនធានរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២.១. គំរូការធនធានមនុស្ស ២
២.២. គំរូការជំនួយបច្ចេកទេស ៦
២.៣. គំរូការហេដ្ឋារចនាសម្ព័ន្ធ ៩
ឧបសម្ព័ន្ធទី១ ម្ចាស់ជំនួយលើវិស័យសុខាភិបាលនៅប្រទេសកម្ពុជា ឆ្នាំ ២០០៦ ១១

## ១. ប្រវត្តិនិងសេចក្តីផ្តើម

ផ្អែកទៅលើការសិក្សាដែលចងក្រងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង្ហាញថា បរិដ្ឋានទទួលជំនួយរបស់ប្រទេសកម្ពុជាគឺស្ថិតក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួលជំនួយច្រើន ហើយដែលជំនួយត្រូវបានចែកជាបំណែកច្រើនបំផុតក្នុងសាកលលោក។ ម៉្យាងទៀតវិស័យសុខាភិបាលស្ថិតលំដាប់ដំបូងដែលទទួលជំនួយច្រើនជាងគេបើពិនិត្យលើតារាងបែងចែកជំនួយ ហើយចំនួនអ្នកផ្តល់ជំនួយដល់វិស័យសុខាភិបាលមានលើសពី២០[7] ក្នុងនោះភាគច្រើនគាំទ្រវិស័យឬគំរោងដ៏ដទៃទៀតដែរ ។ នៅក្នុងរបាយការណ៍ការប្រសិទ្ធភាពជំនួយឆ្នាំ ២០០៧[8] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសន្និដ្ឋានថា ប្រសិនបើគ្មានការប្រសើរឡើងក្នុងការប្រើប្រាស់ជំនួយល្អទេ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍ និងមិនអាចសម្រេច បាននូវការប្រើប្រាស់ជំនួយឱ្យមានប្រសិទ្ធភាពបានទេ។

ថ្មីៗនេះក្រសួងសុខាភិបាលបានចេញប្រកាសកំណត់ការរៀបចំ និងភារកិច្ចនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិទទួលខុសត្រូវទៅលើកិច្ចការសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាននៅក្នុងវិស័យសុខាភិបាល។ កិច្ចការនេះអាចសំរេចទៅបានតាមរយៈការសំរបសំរួល និងសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមជាមួយការរៀបចំគោលនយោបាយសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យសុខាភិបាលដើម្បីធានាបាននូវសុខដុមនីយកម្ម ភាពជាម្ចាស់ និងបំរើផលប្រយោជន៍ជាតិ។

ដើម្បីបំពេញការងារនេះឱ្យមានប្រសិទ្ធភាព ការប្រឹក្សាពិគ្រោះយោបល់ត្រូវបានប្រើប្រាស់ដើម្បីធ្វើការពិនិត្យនិងវិភាគទៅលើប្រព័ន្ធដែលមានស្រាប់ និងសកម្មភាពរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងផ្តល់អនុសាសន៍ដើម្បីធ្វើការកែលំអទៅលើការបំពេញមុខងាររបស់នាយកដ្ឋានឱ្យប្រសើរឡើង។

តាមរយៈលទ្ធផលនៃការប្រឹក្សាពិគ្រោះយោបល់ គោលនយោបាយ និងការណែនាំប្រតិបត្តិត្រូវបានអភិវឌ្ឍឡើង ដើម្បីពង្រឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ[9] ។ ឯកសារសិក្សាពីតំរូវការដែលភ្ជាប់ជាមួយនឹងគោលនយោបាយ និងការណែនាំប្រតិបត្តិនេះ បង្ហាញអំពី តំរូវការជាគន្លឹះ ផ្អែកហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងធនធានមនុស្សរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងចង្អុលបង្ហាញតំរូវការប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលត្រូវបង្កើតឡើង។ ប្រព័ន្ធទិន្នន័យនឹងផ្តល់ពត៌មានដែលអាច តាមដានការចូលរួម

---

[7] សម្ព័ន្ធភាពអ្នកផ្តល់ជំនួយទៅកាន់វិស័យសុខភិបាលនៅក្នុងឆ្នាំ ២០០៦ មានបង្ហាញជូនក្នុងតារាងឧបសម្ព័ន្ធទី១

[8] រាជរដ្ឋាភិបាលកម្ពុជា /ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
សេចក្តីព្រៀងរបាយការណ៍ការប្រើប្រាស់ជំនួយឱ្យមានប្រសិទ្ធភាពនៅកម្ពុជាឆ្នាំ ២០០៧

[9] នាកដ្ឋានសហប្រតិបត្តិការអន្តរជាតិៈ សេចក្តីព្រៀងគោលនយោបាយនិងការណែនាំអនុវត្ត ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០០៧

ចំណែករបស់ដៃគូអភិវឌ្ឍន៍(អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ) ហើយនឹងអាចជួយភ្ជាប់ទំនាក់ទំនង និង ចែករំលែកទិន្នន័យ។

## ២. ធនធានសំរាប់គាំទ្រការរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

ការពង្រីកកម្មវិធីនៃកិច្ចការរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលបានបកស្រាយនៅក្នុង គោលនយោបាយនិងគោលការណ៍ប្រតិបត្តិ នឹងមានតំរូវការជាប់ជាមួយ លើផ្នែកលើកកំពស់សមត្ថភាព បុគ្គលិក ជំនួយការបច្ចេកទេស និងតំរូវការហេដ្ឋារចនាសម្ព័ន្ធ។ ពតិមានលំអិតអំពីតំរូវការធនធានរបស់នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និងលើកយកមកបង្ហាញជូនដូចខាងក្រោមៈ

### ២.១. តំរូវការធនធានមនុស្ស

ចំណេះដឹង និងជំនាញមួយចំនួនសំរាប់មន្ត្រីក្នុងនាយកដ្ឋាននឹងតំរូវអោយមានការអភិវឌ្ឍ ដើម្បីឆ្លើយតប ទៅនឹងការទទួលខុសត្រូវដែលកើនឡើងក្នុងការសំរបសំរួលជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ដៃគូ។

បច្ចុប្បន្ននេះនាយកដ្ឋានបែងចែកចេញជាប្រាំការិយាល័យ ថ្វីបើការងារបានឆ្លងហួសពី ភារកិច្ចរបស់ ការិយាល័យទាំងអស់ក៏ដោយ។ ឧទាហរណ៍ ការគ្រប់គ្រងទៅលើដៃគូអភិវឌ្ឍផ្លូវការ ស្ថិតនៅក្រោមការគ្រប់គ្រង របស់ការិយាល័យ ទំនាក់ទំនងទ្វេភាគី ទំនាក់ទំនងពហុភាគីនិងសំរបសំរួលជាមួយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែ បុគ្គលិកនៃការិយាល័យទាំងនេះក៏ទទួលខុសត្រូវការងារដែលពាក់ព័ន្ធនឹងការសំរបសំរួលក្រុមការងារបច្ចេកទេស សុខាភិបាលថ្នាក់ក្រសួងនិងខេត្តដែរ។ដោយការខ្វះខាតបុគ្គលិក មន្ត្រីរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញភារកិច្ចដោយធ្វើការជាក្រុម របៀបផ្តោតលើភារកិច្ចដែលប្រគល់ជូនបុគ្គលិក ជាជាងបែងចែកតាម ការិយាល័យ ទោះជាមិនទាំងស្រុងក្តី។ នាយកដ្ឋានគួតែបន្តការអនុវត្តការងារមានលក្ខណៈជាក្រុម ផ្អែកទៅលើ មុខងារស្នូលរបស់នាយកដ្ឋាននៅក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រសួងសុខាភិបាល។

មុខងារស្នូលរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិរួមមានៈ

១ សំរបសំរួលរវាងដៃគូអភិវឌ្ឍសុខាភិបាល (អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី និងវិស័យ ឯកជន)

២ សហប្រតិបត្តិការជាមួយការងារអាស៊ានផ្នែកសុខាភិបាល

៣ សំរបសំរួលការងារសុខាភិបាលរវាងសហប្រតិបត្តិការអន្តរជាតិនិងទំនាក់ទំនងសាធារណៈ

៤ ពិនិត្យមើលទៅលើប្រសិទ្ធភាពនៃមុខងាររបស់ក្រុមការងារបច្ចេកទេសវិស័យសុខាភិបាល

៥ គ្រប់គ្រងពត៌មានជាយុទ្ធសាស្ត្រដែលទាក់ទងទៅនិងកម្មវិធីផ្តល់ជំនួយនៅក្នុងវិស័យសុខាភិបាល រួមទាំងកម្មវិធីគ្រប់គ្រងទិន្នន័យអំពីដៃគូអភិវឌ្ឍ ការសំរបសំរួលលើក្របខ័ណ្ឌផែនការចំណាយសំរាប់លក្ខណៈមធ្យម នៅក្នុងវិស័យសុខាភិបាល និងការអភិវឌ្ឍន៍និងគ្រប់គ្រងគេហទំព័ររបស់ក្រសួងសុខាភិបាល ។

ពត៌មានខាងក្រោមនិងបង្ហាញអំពីជំនាញចាំបាច់ដែលជួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ។ ជំនាញដែលចាំបាច់ផ្អែកទៅ លើការងារគន្លឹះនិងសកម្មភាពនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ សំរាប់មុខងារស្នូលនីមួយៗ:

**១. សំរបសំរួលរវាងដៃគូអភិវឌ្ឍសុខាភិបាល ( អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី និងវិស័យ ឯកជន)**

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| • កំណត់និងតាមដានទៅលើដៃគូអភិវឌ្ឍ ( ដៃគូពហុភាគី ទ្វេភាគី និងទីភ្នាក់ងារអនុវត្តដោយផ្ទាល់) អំពីផ្តល់មូលនិធិដល់វិស័យសុខាភិបាល រួមទាំងការសន្យាផ្តល់មូលនិធិ មូលនិធិរំពឹងទុក និងការចំណាយជាក់ស្តែង<br>• ផ្តល់យោបល់ និង តាមដានទីភ្នាក់ងារអនុវត្តគំរោងអំពីសកម្មភាពគ្របដណ្តប់ និងលទ្ធផលដែលសំរេចបាន<br>• សហប្រតិបត្តិការជាមួយនាយកដ្ឋាននិងកម្មវិធីនៃក្រសួសុខាភិបាល សំរបសំរួលការពិនិត្យមើលទៅលើសំណើសុំរបស់ដៃគូអភិវឌ្ឍ ដើម្បីធានាបាននូវភាពសុខដុមនីយកម្មជាមួយផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានស្រាប់ ជាមួយការផ្តួចផ្តើមរបស់ដៃគូអភិវឌ្ឍសុខាភិបាលដែលស្របជាមួយគោលនយោបាយសុខាភិបាលជាតិ ប្រព័ន្ធ និងអាទិភាពទាំងឡាយ ។<br>• កំណត់ឱកាសសំរាប់ការរៀបចំវិធីសាស្ត្រអោយកាន់តែប្រសើរក្នុងការទទួលជំនួយសំរាបវិស័យសុខាភិបាល ដើម្បីជួយពង្រឹងការសំរបសំរួលម្ចាស់ជំនួយ ដើម្បីឈានទៅការគ្រប់គ្រងវិស័យដែលមានលក្ខណៈទូលំទូលាយ<br>• តាមដានជំនួយបច្ចេកទេសដែលផ្តល់ដោយដៃគូអភិវឌ្ឍទៅក្នុងវិស័យសុខាភិបាល<br>• តាមដាន និង ចូលរួមប្រសិនបើអាចនៅក្នុងការពិនិត្យឡើងវិញលើគំរោងកម្មវិធី<br>• បំពេញតួនាទីជាច្រកទំនាក់ទំនងផ្លូវការដំបូងនៅក្នុងវិស័យសុខាភិបាល និងជាមជ្ឈមណ្ឌលផ្តល់ពត៌មានសំរាប់គ្រប់ដៃគូអភិវឌ្ឍទាំងអស់ ដែលបំពេញការងារនៅក្នុងវិស័យសុខាភិបាល ។<br>• ដើរតួនាទីជាបុគ្គលកណ្តាលនៅក្នុងក្រសួងសុខាភិបាលសំរាប់ជួយសំរបសំរួលការពិភាក្សាទៅលើគោលនយោបាយរវាងក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍសុខាភិបាលសំរាប់ជាជំនួយក្នុងការអភិវឌ្ឍកម្មវិធីក្នុងវិស័យសុខាភិបាល<br>• សំរបសំរួលការចែករំលែកពត៌មានទៅលើការសំរេចចិត្តរវាងដៃគូអភិវឌ្ឍសុខាភិបាលនិងក្រសួងសុខាភិបាល និងធ្វើបច្ចុប្បន្នភាពសកម្មភាពដែលបាន | • ការវិភាគទៅលើស្ថានភាពវិស័យសុខាភិបាល<br>• ការវិភាគទៅលើគោលនយោបាយសុខាភិបាល កម្មវិធី និងហិរញ្ញវត្ថុ<br>• ការពិនិត្យសំណើនិងការវាយតំលៃ<br>• ពិនិត្យ តាមដាន និងវាយតំលៃទៅលើការអនុវត្តន៍ របស់កម្មវិធីឬគំរោង<br>• ការគ្រប់គ្រងធនធាន<br>• សហប្រតិបត្តិការនិងសំរបសំរួលជាអន្តរជាតិលើវិស័យ សុខាភិបាល<br>• ជំនាញកុំព្យូទ័រ (Ms Word, Excel, PowerPoint and Access)<br>• ជំនាញគ្រប់គ្រងទិន្នន័យ (បញ្ចូល និង បង្ហាញទិន្នន័យពី ក្នុងកម្មវិធី MS Access)<br>• ភាពជាអ្នកដឹកនាំ<br>• ការប្រាស្រ័យទាក់ទង<br>• ជំនាញធ្វើបទបង្ហាញ<br>• ភាសាអង់គ្លេស<br>• រៀបចំរបាយការណ៍<br>• ការគ្រប់គ្រងទៅលើធនធានមនុស្ស និង ការធ្វើការងារជាក្រុម |

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| បំពេញរបស់ក្រុមបច្ចេកទេសសុខាភិបាលក្នុងពេលវេលាមួយទៀតទាត់ ។<br>• សំរបសំរួលការប្រាស្រ័យទាក់ទងរវាងក្រសួងសុខាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល ស្ថាប័នដ៏ទៃទៀតដែលពាក់ព័ន្ធនឹងការសំរបសំរួលនៃជំនួយអភិវឌ្ឍជាផ្លូវការទៅ កាន់វិស័យសុខាភិបាល ។<br>• ធ្វើការវិភាគពត៌មានហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍ និង ផែនការប៉ាន់ប្រមាណរយៈពេលពាឆ្នាំចំពោះការផ្តល់មូលនិធិ និង សន្យាមូលនិធិសំរាប់ក្រសួងសុខាភិបាល ។ | |

## ២. សហប្រតិបត្តិការជាមួយការងារអាស៊ានទៅលើការងារសុខាភិបាល

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| • ទំនាក់ទំនងជាមួយស្ថាបន័ នាយកដ្ឋាន និងកម្មវិធីនានាក្រោមឱវាទក្រសួងសុខាភិបាលដើម្បីប្រមូលពត៌មានសំខាន់ៗ និងផ្តល់អនុសាសន៍កិច្ចការដែលទាក់ទងនឹងអាស៊ាន ។<br>• ពិនិត្យផែនការសកម្មភាពរបស់ដៃគូសន្ទនាដែលផ្តល់ការគាំទ្រហិរញ្ញវត្ថុ និង បច្ចេកទេសដល់ប្រទេសសមាជិកអាស៊ាន ។<br>• ពិនិត្យច្បាប់ និងបទដ្ឋានរបស់ប្រទេស តំបន់ និង អន្តរជាតិ ដែលទាក់ទងទៅនឹងតំណើការសេរីភាវូបនីយកម្ម ផែទាំសុខភាព រួមជាមួយការកាត់បន្ថយអត្រាពន្ធ និង សុខដុនីយកម្មសំរាប់ផលិតផលថែទាំសុខភាព ។<br>• ចងក្រង និង គ្រប់គ្រងទិន្នន័យសហប្រតិបត្តិការសុខាភិបាលអាស៊ាន និងបំពេញភារកិច្ចជាមណ្ឌលរក្សាឯកសារ និងពត៌មានពាក់ពន្ធ័សុខាភិបាលអាស៊ានរបស់ក្រសួងសុខាភិបាល ។<br>• ផ្សព្វផ្សាយពត៌មានអាស៊ានឱ្យបានសមស្របដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹង និងធ្វើការសំរេចចិត្តលើសកម្មភាពអាស៊ានដោយមន្ត្រី និងស្ថាបន័សុខាភិបាល ។<br>• រៀបចំសេចក្តីព្រាងច្បាប់ និងគោលនយោបាយសុខាភិបាលសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដោយសហការយ៉ាងជិតស្និតជាមួយនាយកដ្ឋាន កម្មវិធី និងស្ថាប័នពាក់ពន្ធ័<br>• ចូលរួមក្នុងយន្តការសំរបសំរួលស្តីពីបញ្ហាសុខាភិបាលដោយរួមបញ្ចូលក្រុមឯកទេស និងក្រុមការងារដើម្បីធានាឱ្យមានតំណើការសហប្រតិបត្តិការនៃដៃគូសុខាភិបាលក្នុងតំបន់អាស៊ាន<br>• ចូលរួមក្នុងកិច្ចប្រជុំសិក្ខាសាលាផ្សេងៗដែលពាក់ពន្ធ័សុខាភិបាលអាស៊ានក្នុងកំរិតជាតិនិងក្នុងកំរិតតំបន់<br>• បំពេញភារកិច្ចជាលេខាធិការដ្ឋានក្នុងការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកិច្ចប្រជុំជាន់ខ្ពស់ផ្សេងៗដែលពាក់ពន្ធ័និងកិច្ចការសុខាភិបាលអាស៊ាន ដោយសហការជាមួយអគ្គលេខាធិការដ្ឋានអាស៊ាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>• តាមដាន វាយតំលៃ និងផ្តល់របាយការណ៍សរសេរអំពីសហប្រតិបត្តិការអាស៊ានរបស់ស្ថាប័ន | • កិច្ចសហប្រតិបត្តិការនិងសំរបសំរួលអន្តរជាតិ វិស័យសុខាភិបាល<br>• ជំនាញក្នុងការចចារ<br>• ធ្វើផែនការយុទ្ធសាស្ត្រ<br>• ជំនាញកុំព្យូទ័ (Ms Word Excel PowerPoint)<br>• ភាពជាអ្នកដឹកនាំ<br>• ការប្រាស្រ័យទាក់ទងអន្តរបុគ្គល<br>• ភាសាអង់គ្លេស<br>• សរសេររបាយការណ៍<br>• គ្រប់គ្រងឯកសារ និង ប្រើប្រាស់ពត៌មាន<br>• មានចំណេះដឹងទៅលើបញ្ហាសុខភាពអន្តរជាតិ នីតិកម្ម និងការអនុវត្តន៍ផ្នែកពាណិជ្ជកម្ម<br>• គោលនយោបាយពាណិជ្ជកម្ម |

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| សុខាភិបាលក្នុងកំរិតជាតិ និង តំបន់<br>• រៀបចំផែនការយុទ្ធសាស្ត្រពីរយៈពេលមួយទៅរយៈពេលមួយ សំរាប់កិច្ចសហប្រតិបត្តិការសុខាភិបាលអាស៊ាន និង ធានាថាយុទ្ធសាស្ត្រទាំងនោះត្រូវបានបញ្ចូលទៅក្នុងការកសាងផែនការប្រចាំឆ្នាំ និងបីឆ្នាំរំកិលដែលមានលក្ខណៈទូលំទូលាយ<br>• ទំនាក់ទំនង និង សំរបសំរួលជាមួយនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង នាយកដ្ឋានអាស៊ាន និង អង្គការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ដើម្បីរក្សាទុកឯកសារ និងអនុវត្តន៍កិច្ចព្រមព្រាងដែលទាក់ទងនិងជាមួយសេវា និងផលិតផល រវាងប្រទេសសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ប្រទេសដៃគូអាស៊ាន និងរដ្ឋ សមាជិកអាស៊ាន<br>• ពិនិត្យច្បាប់បទដ្ឋានសំរាប់សេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និង ជួយក្នុងការបង្កើតយន្តការសំរបសំរួល និង និយ័តកម្មសំរាប់សមាហរណកម្មសេដ្ឋកិច្ចនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន | |

## ៣. សំរបសំរួលកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យសុខាភិបាល

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| • សំរបសំរួលកម្មវិធី និងការវិភាគទស្សនកិច្ចជូនគណប្រតិភូបរទេស ទទួលគណប្រតិភូ និង អមដំណើរគណប្រតិភូដែលចុះទស្សនកិច្ចមូលដ្ឋានប្រសិនបើចាំបាច់<br>• សំរបសំរួលការរៀបចំនៃដំណើរទស្សនកិច្ចជាន់ខ្ពស់ទៅកាន់គំរោងដែលគាំទ្រដោយមូលនិធិពីខាងក្រៅ<br>• ភ្ជាប់ទំនាក់ទំនងជាមួយក្រសួងការបរទេស និងស្ថានទូតលើកិច្ចសហប្រតិបត្តិការសុខាភិបាល<br>• តាមដានពត៌មានទេសចរណ៍ និង រៀបចំរបាយការណ៍អំពីការវិវឌ្ឍន៍នៃកិច្ចការទេសចរណ៍ជូនការិយាល័យផ្សេងៗរបស់នាយកដ្ឋាន<br>• រៀបចំបែបបទឯកសារនិងជួយសំរបសំរួលទស្សនកិច្ចក្រៅប្រទេសរបស់មន្ត្រីក្រសួងសុខាភិ-បាលដែលអញ្ជើញចូលរួមក្នុងសិក្ខាសាលា សន្និសិត ទស្សនកិច្ចសិក្សា ។ល។ ដោយរួមទាំងរៀបចំឯកសារធ្វើដំណើរ លិខិតឆ្លងដែន ទិដ្ឋការ និង ការអនុញ្ញាតដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>• ទទួល និង បែងចែកលិខិត ឬ ឯកសារអន្តរជាតិ និង ផ្តល់ដំបូលមានជូននាយកដ្ឋាន និង កម្មវិធីផ្សេងទៀតតាមដែលចាំបាច់<br>• ធានាទំនាក់ទំនងសាធារណជាមួយស្ថាប័ន និងក្រសួងផ្សេងៗដើម្បីធានាកិច្ចសហប្រតិបត្តិការអន្តរនាយកដ្ឋាន និង អន្តរក្រសួងឱ្យមានប្រសិទ្ធភាព<br>• រៀបចំសំរបសំរួលការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយក្រៅប្រទេសរវាងក្រសួងសុខាភិបាល និង ដៃគូអភិវឌ្ឍន៍<br>• រៀបចំសំរបសំរួលកិច្ចប្រជុំរវាងមន្ត្រីជាន់ខ្ពស់ជាមួយគណប្រតិភូជាន់ខ្ពស់នានា<br>• ផ្តល់ការគាំទ្រដែលចាំបាច់ជូនទីភ្នាក់ងារអន្តរជាតិក្នុងការនាំចូលមុខទំនិញជាអំណោយ និង | • រដ្ឋបាលការរៀបចំឯកសារ និង ដកឯកសារមក ប្រើប្រាស់<br>• រៀបចំកាលវិភាគនិងសំរបសំរួលការធ្វើដំណើរ<br>• ទំនាក់ទំនងសាធារណៈ<br>• ការគ្រប់គ្រងពិធីកា<br>• ទំនាក់ទំនងអន្តរជាតិ<br>• ធ្វើសេចក្តីព្រៀងនិងរៀបចំសន្ទរកថា<br>• ជំរះបញ្ជីទំនិញនាំចូល<br>• ជំនាញចចារ<br>• ជំនាញកុំព្យូទ័រ (Ms Word Excel PowerPoint)<br>• ភាពជាអ្នកដឹកនាំ<br>• ទំនាក់ទំនងអន្តរបុគ្គល<br>• ភាសាអង់គ្លេស<br>• ការគ្រប់គ្រងធនធានមនុស្ស<br>• ចំណេះដឹងសំរាប់បំពេញការងារទៅលើវិស័យទេសចរ |

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| សំភារៈគំរោង | |

## ៤.សំរបសំរួលលើការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល

### ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
|---|---|
| • រៀបចំរបៀបវារអង្គប្រជុំ និង រក្សាទុកដាក់ជាឯកសាររៀបចំកំណត់ហេតុអង្គប្រជុំ និង ផ្សព្វផ្សាយ ឬ បែងចែក ។<br>• ធានាតាមដានការសំរេចចិត្តដែលធ្វើឡើងដោយអង្គប្រជុំ<br>• សំរបសំរួលការរៀបចំផែនការការងាររបស់ក្រុមការងារបច្ចេកទេសសុខាភិបាលប្រចាំឆ្នាំ<br>• គាំទ្រការអនុវត្តន៍ផែនការការងារប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសសុខាភិបាល<br>• ទំនាក់ទំនងជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីធានាឱ្យការរៀបចំរបាយការណ៍វឌ្ឍនភាពដែលមានប្រសិទ្ធភាពស្តីពីការបំពេញមុខងាររបស់ក្រុមការងារបច្ចេកទេសសុខាភិបាល ដើម្បីបែងចែក និង ផ្ញើរជូនគណកម្មការសំរបសំរួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ ។<br>• ពិនិត្យរបាយការប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត និង ដាក់ជូនលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តក្រសួង និងតាមដានបញ្ហាដែលបានរាយការណ៍ក្នុងរបាយការណ៍ ត្រីមាសមុនៗ ។<br>• ចងក្រងពតិមានដែលបានផ្តល់ដោយ នៃត្រីមាសនីមួយៗ និង តាមដានបញ្ហាគន្លឹះនានាជាមួយខេត្ត ។<br>• ក្នុងនាមក្រុមការងារបច្ចេកទេសសុខាភិបាលក្រសួង ចងក្រង និងផ្តល់ពតិមានត្រលប់ជូនក្រុមការងារ បច្ចេកទេសសុខាភិបាលខេត្ត ដោយសហការជាមួយនាយកដ្ឋាននានា និង កម្មវិធីជាតិនានា ។<br>• ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត ផ្អែកតាមតំរូវការជាក់ស្តែងក្នុងករណីដែល មានប្រធានបទសំខាន់ ឬ ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តបំពេញមុខងារមិនទាន់បានពេញលេញ ។ តាមដែលអាចធ្វើបាន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិគួរចូលរួមយ៉ាងហោចអោយបានម្តងក្នុងមួយឆ្នាំក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តនីមួយៗ ។ | • ការគ្រប់គ្រងទៅលើការប្រជុំ រួមទាំងការរៀបចំរបៀបវារៈ កំណត់ត្រាក្នុងអង្គប្រជុំ និងការរៀបចំកំណត់ហេតុ<br>• ទំនាក់ទំនងនិងសំរបសំរួល<br>• ភាពជាអ្នកដឹកនាំ<br>• ជំនាញក្នុងការចចារ<br>• រៀបចំនិងពិនិត្យមើលរបាយការណ៍<br>• ជំនាញកុំព្យូទ័រ (Ms Word Excel PowerPoint)<br>• ជំនាញអន្តរបុគ្គល<br>• ភាសាអង់គ្លេស |

## ៥. រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងពតិមានដែលទាក់ទងទៅនឹងកម្មវិធីផ្តល់ជំនួយនៅក្នុងវិស័យសុខាភិបាល រួមទាំងកម្មវិធីគ្រប់គ្រងទិន្នន័យទៅលើជំនួយអភិវឌ្ឍជាផ្លូវការ សំរបសំរួល

## ក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈមធ្យមនៅក្នុងវិស័យសុខាភិបាល និងការអភិវឌ្ឍន៍ និង គ្រប់គ្រងគេហទំព័ររបស់ ក្រសួងសុខាភិបាល

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
| --- | --- |
| • ទំនាក់ទំនងជាមួយនាយកដ្ឋានផែនការ និង ពត៌មានសុខាភិបាល ដើម្បីទទួលបានផែនការ ៣ឆ្នាំរំកិល ផែនការប្រតិបត្តិប្រចាំឆ្នាំចុងក្រោយបំផុត<br>• ទំនាក់ទំនងជាមួយនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីទទួលបានការផ្តល់មូលថវិកាប៉ាន់ប្រមាណសំរាប់រយៈពេល៣ឆ្នាំសំរាប់ក្រសួងសុខាភិបាល<br>• វិភាគទិន្នន័យនៃកំរងសំនួរ MTEF របស់ម្ចាស់ជំនួយ និង ដកស្រង់ទិន្នន័យ សំខាន់ៗ<br>• ទំនាក់ទំនងជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធានាថាទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស៊ីសង្វាក់ជាមួយទិន្នន័យដែលម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលបានផ្តល់ក្នុងកំរងសំនួរ MTEF ។<br>• ធានាថាទីភ្នាក់ងារអនុវត្តគម្រោងក្នុងវិស័យសុខាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងគំរោងជាមួយក្រសួងសុខាភិបាល<br>• ធានាថាទីភ្នាក់ងារអនុវត្តគម្រោងក្នុងវិស័យសុខាភិបាល មានទំរង់របាយការណ៍ជាច្បាប់បោះពុម្ព និង អេឡិចត្រូនិចដែលបានកែសំរួលចុងក្រោយហើយនឹងដឹងអំពីតំរូវការដែលត្រូវផ្ញើរបាយការណ៍មកក្រសួងរៀងរាល់៦ខែម្តង ។<br>• ប្រមូលនិងរក្សាទុកដាក់របាយការណ៍ដែលទទួលបានពីទីភ្នាក់ងារអនុវត្តគំរោង និង តាមដានរំលឹកទីភ្នាក់ងារអនុវត្តគំរោងណាដែលមិនបានផ្ញើរបាយការណ៍ទាន់ពេលវេលា (ប្រើប្រាស់យន្តការក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តប្រសិនសមស្រប)<br>• បញ្ចូលពត៌មានសំខាន់ៗរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងប្រពន្ធ័ទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>• វិភាគទិន្នន័យហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ហើយ និងរៀបចំជាឯកសារប៉ាន់ប្រមាណនៃការផ្តល់ និងសន្យាផ្តល់មូលនិធិសំរាប់រយៈពេល១ឆ្នាំ និង ៣ឆ្នាំខាងមុខ<br>• ចងក្រងរបាយការណ៍សរុបដែលម្ចាស់ជំនួយ និង ទីភ្នាក់ងារអនុវត្តន៍គម្របដណ្តប់បានចំណាយលើវិស័យសុខាភិបាល ហើយនិងដាក់របាយការណ៍ជូនក្រុមការងារបច្ចេកទេសសុខាភិបាល<br>• ប្រមូល ចងក្រង និងរក្សាជាឯកសារនូវពត៌មានអេឡិចត្រូនិកពីនាយកដ្ឋាន កម្មវិធីជាតិ រួមទាំងការរៀបរាប់អំពីនាយកដ្ឋាន កម្មវិធីជាតិ គោលនយោបាយ ផែនការអាទិភាព និង សកម្មភាពរបស់ក្រសួងសុខាភិបាល ហើយនិងបញ្ចូលពត៌មានទាំងអស់នេះទៅក្នុងWebsite ក្រសួងជាបន្តបន្ទាប់<br>• បង្កើត និង គ្រប់គ្រង Website ក្រសួងព្រមទាំងមានលទ្ធភាពភ្ជាប់ទៅកាន់ Website នាយកដ្ឋាន កម្មវិធីជាតិ ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និង បណ្ណាល័យអេឡិចត្រូនិកដែលមានស្រាប់<br>• បញ្ចូលផែនទីរួមទាំងផែនទី GIS នៃទីតាំងសេវាសុខាភិបាល អង្គការក្រៅរដ្ឋាភិបាល ។ល។ ដោយសហការជាមួយអង្គការ មេឌីខាំ<br>• ចងក្រង និង បញ្ចូលប្រតិទិនពត៌មាននៃព្រឹត្តិការណ៍នានា ។ល។ ទៅក្នុង Website ក្រសួង | • ជំនាញកុំព្យូទ័រ (Ms Word Excel PowerPoint)<br>• បញ្ចូលនិងផ្ទៀងផ្ទាត់ពត៌មាន<br>• គ្រប់គ្រងទៅលើប្រព័ន្ធទិន្នន័យ វិភាគនិងរៀបចំរបាយការណ៍<br>• អភិវឌ្ឍ គ្រប់គ្រង និងថែរក្សាគេហទំព័ររបស់ក្រសួងសុខាភិបាល<br>• រៀបចំសរសេររបាយការណ៍<br>• ភាសាអង់គ្លេស<br>• វិភាគអំពីហិរញ្ញវត្ថុរបស់កម្មវិធីសុខាភិបាល<br>• សំរបសំរួល |

| ការងារនិងសកម្មភាព | ជំនាញដែលត្រូវការ |
| --- | --- |
| • លើកកំពស់ការប្រើប្រាស់វេបសាយ និង បញ្ចូលពត៌មានទៅក្នុងវេបសាយ<br>• ធានាថានឹងទទួលបាននូវ Website ដែលមានអាស័យដ្ឋាន www.moh.gov.kh អាចដំណើរការបាននៅលើ ប្រពន្ធ័ ។ | |

## ២.២. ជំនួយបច្ចេកទេសដែលត្រូវការ

នៅពេលដែលនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិកំពុងតែពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីទទួលយកនូវការងារ និងតួនាទីរបស់ខ្លួននោះ គឺចាំបាច់ត្រូវតែមានជំនួយការបច្ចេកទេសពីខាងក្រៅដើម្បីជួយបង្កើតនូវ ប្រព័ន្ធចាំបាច់ផ្សេងៗ និងបង្ហាត់បង្រៀនបុគ្គលិករបសឱ្យនាយកដ្ឋានបំពេញការងារតាមគោលការណ៏ថ្មីៗទាំងនោះ ។ ជំនួយការបច្ចេកទេសពីខាងក្រៅត្រូវបានស្នើសុំរួមមានដូចខាងក្រោម :

### ២.២.១ ទីប្រឹក្សារយៈពេលខ្លី ដើម្បីជួយសំរបសំរួលការគ្រប់គ្រងពត៏មានជាយុទ្ធសាស្ត្រនៅក្នុងនាយកដ្ឋាន សហប្រតិបត្តការអន្តជាតិ ៖

នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ បានបង្ហាញពីតំរូវការសំរាប់ប្រព័ន្ធទិន្នន័យមួយ (Database) ដែលអាចឱ្យនាយកដ្ឋានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងកិច្ចសហប្រតិបត្តិការនៃជំនួយដៃគូអភិវឌ្ឍន៏សុខាភិបាលជូនដល់ផ្នែកនេះ ។ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ក៏ត្រូវការជំនួយលើផ្នែកបច្ចេកទេសផងដែរ ដើម្បីពិនិត្យឡើងវិញ ធ្វើបច្ចុប្បភាព (update) ថែរក្សាវេបសាយរបស់ក្រសួងសុខាភិបាល (MoH Website) ។ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិចង់អោយមានដំណើរការនោះធ្វើឡើងដោយប្រើប្រាស់លទ្ធកម្មក្នុងការផ្តល់សេវាពីម្នាក់ ទៅច្រើននាក់ ។

**ការងារ និងតួនាទីសំរាប់ការងារប្រឹក្សាពិគ្រោះយោបល់នេះមានផ្តល់ជូនដូចខាងក្រោម :**

គោលបំណងនៃប្រឹក្សាពិគ្រោះយោបល់

នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ កំពុងស្វែងរកទីប្រឹក្សាដែលមានបទពិសោធន៏ផ្នែកពត៌មានវិទ្យា ដើម្បីបង្កើតប្រព័ន្ធទិន្នន័យមួយសំរាប់ការប្រើប្រាស់ទូលំទូលាយ ដែលងាយឱ្យនាយកដ្ឋានអាចបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធជាមួយនឹងកិច្ចសហប្រតិបត្តិការ នៃជំនួយដៃគូអភិវឌ្ឍន៏សុខាភិបាលជូនដល់ផ្នែកទាំងអស់ ។ ដូចដែលមានបញ្ជាក់នៅក្នុងគោលនាយោបាយ និងគោលការណ៏ប្រតិបត្តរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រព័ន្ធទិន្នន័យរបស់នាយកដ្ឋានត្រូវតែភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា

ដែលមានលទ្ធភាពសំរបសំរួលការងារនេះឱ្យស៊ីសង្វាក់គ្នាជាមួយតំរូវការពតិមានរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ដោយរួមបញ្ចូលទាំងសមត្ថភាពដែលអាចៈ

- បញ្ជាក់ និងតាមដានដៃគូអភិវឌ្ឍន៏ (ជំនួយទ្វាភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) ដែលផ្តល់ថវិកាដល់ផ្នែកសុខាភិបាលដោយរួមបញ្ចូលទាំងមូលនិធិដែលបានសន្យា ប៉ាន់ស្មាននិងដែល បានផ្តល់ជូនកន្លងមក) ។
- ផ្តល់ជាផែនការ និងតាមដានសកម្មភាពដៃគូអនុវត្តការងារ តំបន់គ្របដណ្តប់ និងសមិទ្ធិផលដែលសំរេចបានកន្លងមក ។
- តាមដានជំនួយការបច្ចេកទេសដៃគូអភិវឌ្ឍន៏ដែលបានផ្តល់ជូនផ្នែកសុខាភិបាល
- រៀបចំក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមជាទៀងទាត់

ទីប្រឹក្សាក៏ត្រូវផ្តល់ផងដែរនូវជំនួយការបច្ចេកទេស ដើម្បីជួយនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ រៀបចំ និងថែរក្សា វេបសាយរបស់ក្រសួងសុខាភិបាល(MoH Website: www.moh.gov.kh ) ។ វេបសាយគឺដើរជាប្រព័ន្ធទិន្នន័យហើយអាចមានសត្ថភាព ក្នុងនាមជាប្រព័ន្ធទិន្នន័យរបស់នយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ។

**ក្រុមការងារជាពិសេស (Specific tasks)**

### ១. បង្កើតប្រព័ន្ធទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

- ត្រួតពិនិត្យឡើងវិញ ក្របខ័ណ្ឌគោលនាយោបាយ និងគោលការណ៍ប្រតិបត្តការរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ និងសហការជាមួយបុគ្គលិកនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ដើម្បីឱ្យយល់អំពីសេចក្តីត្រូវការនៃប្រព័ន្ធគ្រប់គ្រងពតិមានរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ
- ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធពតិមានដែលពាក់ព័ន្ធវិស័យសុខាភិបាលដែលមានស្រាប់ (រួមបញ្ចូលទាំងជំនួយការអភិវឌ្ឍន៏ផ្លូវការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ប្រព័ន្ធទិន្នន័យនៃអង្គការក្រៅរដ្ឋាភិបាល ប្រព័ន្ធទិន្នន័យរបស់អង្គការ MEDiCAM និង វេបសាយក្រសួងសុខាភិបាល ។
- ផ្តល់ជាអនុសាសន៏ពីអ្វីដែលល្អក្នុងការភ្ជាក់ជាមួយនឹង ប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជាដែលមានស្រាប់ជាមួយនឹងប្រព័ន្ធទិន្នន័យនៃ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិដែលកំពុងរៀបចំ ។

- ត្រួតពិនិត្យឡើងវិញ និងផ្តល់យោបល់លើក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈពេលមធ្យមបច្ចុប្បន្ន សំរាប់ការប្រើប្រាស់ទូលំទូលាយ ។

- បង្កើតផែនការ (តារាង និងរចនាសម្ព័ន្ធនៃការភ្ជាប់) ហើយនិងបង្កើតរចនាសម្ព័ន្ធ ទិន្នន័យ ។

## ២. បង្កើតប្រព័ន្ធ និងដំណើរការសំរាប់បញ្ចូលទិន្នន័យ ប្រមូលទិន្នន័យមកប្រើប្រាស់ និងវិភាគទិន្នន័យ

- បង្កើត និងប្រើឧបករណ៍បញ្ចូលទិន្នន័យសមស្របសំរាប់ប្រព័ន្ធទិន្នន័យ

- ត្រួតពិនិត្យទិន្នន័យឱ្យបានត្រឹមត្រូវដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

- សហការជាមួយដៃគូពាក់ព័ន្ធខាងក្រៅផ្សេងៗក្នុងការជួយឧបត្ថម្ភដល់ដំណើរការប្រមូលទិន្នន័យ

- បញ្ចាញ ការត្រួតពិនិត្យទិន្នន័យ ការបញ្ចូលទិន្នន័យ និងការថែរក្សាទិន្នន័យ

- បង្កើតរបាយការណ៍ និងសំភារៈដែលចាំបាច់នៅក្នុងប្រព័ន្ធទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

- បង្កើតរបាយការណ៍លំអិតសំរាប់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

## ៣. ជួយជ្រោមជ្រែងដំណើរការនៃប្រព័ន្ធទិន្នន័យនៅក្នុងនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

- ប្រើប្រាស់កម្មវិធីទិន្នន័យជាស្តង់ដារមួយ (ដូចជា MS. Access, SQL) ដើម្បីថែរក្សាទិន័យនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

- រៀបចំធ្វើសវនៈកម្ម និងវិសោធនកម្ម នូវរបាយការណ៍ទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យ

- រៀបចំធ្វើការសាកល្បងលើប្រព័ន្ធទិន្នន័យជាមួយបុគ្គលិកដែលទទួលខុសត្រូវលើទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

- បង្រៀនអ្នកប្រើប្រាស់ឱ្យចេះពីការប្រើប្រាស់ ប្រព័ន្ធទិន្នន័យនេះ

- បង្កើត និងអនុវត្តនូវសៀវភៅណែនាំសំរាប់ការប្រើប្រាស់ ប្រព័ន្ធទិន្នន័យទូលំទូលាយដោយរួមបញ្ចូលទាំងបទដ្ឋាននិងគោលការណ៍រដ្ឋបាលផង ការណែនាំសំរាប់អ្នកប្រើប្រាស់ផង និងការគ្រប់គ្រងទិន្នន័យ និងបទដ្ឋាននៃការបញ្ចូលពតិមានផង ។

## លទ្ធផលដែលបានមកពីសេវាផ្តល់ប្រឹក្សា

- កម្មវិធីទិន្នន័យទូលំទូលាយ ដែលត្រូវជាមួយនឹងតំរូវការក្នុងការគ្រប់គ្រងពតិមាននៃនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ដោយភ្ជាប់ជាមួយនឹងប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ដែលបានបង្កើតឡើង និងប្រើប្រាស់ដោយ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ

- បុគ្គលិកសុខាភិបាលដែលមានសិទ្ធិគឺមានលទ្ធភាពអាចប្រើប្រាស់ និងថែរក្សាប្រព័ន្ធទិន្នន័យដោយរួមទាំងការបញ្ចូលទិន្នន័យ ការគ្រប់គ្រង ការវិភាគ និងការបង្កើតជារបាយការណ៍ ។

- សៀវភៅណែនាំសំរាប់ការប្រើប្រាស់ប្រព័ន្ធទិន្នន័យទូលំទូលាយ រួមមានគោលការណ៍សំរាប់អ្នកប្រើប្រាស់ ការគ្រប់គ្រងទិន្នន័យ និងបទដ្ឋាននៃការបញ្ចូលពតិមាន ។

## លក្ខណះពិសេសសំរាប់សេវាកម្មទីប្រឹក្សា

### ការសិក្សា

- ត្រូវមានបរិញ្ញបត្រផ្នែកពតិមានវិទ្យា ដែលមានជំនាញខាង ប្រព័ន្ធទិន្នន័យ និង Web-based ឬយ៉ាងហោចណាស់ត្រូវមានបទពិសោធន៍ក្នុងការបង្កើត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ ដែលប្រើប្រាស់បច្ចេកវិទ្យាទិន្នន័យ

### បទពិសោធន៍

- ដូចមានកំណត់នៅក្នុង "ការសិក្សា" ខាងលើ

- បង្ហាញពីបទពិសោធន៏ក្នុងការបង្កើត Database និង Web-based

- បង្ហាញពីបទពិសោធន៏ក្នុងការសហប្រតិបត្តការ និងគ្រប់គ្រងដំណើរការប្រមូលទិន្នន័យ និងជួយផ្នែកពតិមានវិទ្យា

ចំណេះដឹង និងជំនាញ

ជំនាញការងារជាក់លាក់

- សមត្ថភាពក្នុងការបង្វែរពត៌មានផែនការស្ថាបត្យកម្ម ទៅជាការងារ Database ទៅតាមតំរូវការចាំបាច់
- ពង្រឹងចំណេះដឹងកម្មវិធី SQL Database និងកម្មវិធី Database ពាណិជ្ជកម្ម ដូចជាកម្មវីធី Ms. Access
- ចំណេះដឹងកម្មវិធី Web-based database គឺល្អ
- ចំណេះដឹង និងជំនាញ ប្រព័ន្ធ GIS គឺមានអាទិភាព
- ចំណេះដឹង និងបទពិសោធន៍ក្នុងការត្រួតពិនិត្យ និងតាមដាន គឺមានអាទិភាព
- ចំណេះដឹងផ្នែកសុខាភិបាល គឺមានអាទិភាព

ជំនាញគ្រប់គ្រង

- សមត្ថភាពក្នុងការសហការ បណ្តុះបណ្តាល និងធ្វើការជាមួយអ្នកមិនជំនាញខាងពត៌មានវិទ្យា
- បង្ហាញពីសមត្ថភាពក្នុងការធ្វើការងារជាក្រុមឯករាជ និងអាចធ្វើការបានដោយមានអភិបាលតិច
- ជំនាញផ្នែកទំនាក់ទំនង និងសមត្ថភាពធ្វើការជាមួយនឹងបុគ្គលិករដ្ឋ

ជំនាញខាងអក្សរ និងលេខ

- មានសត្ថភាពខ្ពស់ក្នុងការសរសេរ និងទំនាក់ទំនងជាភាសារអង់គ្លេស
- ចំណេះដឹងភាសាខ្មែរសំរាប់ទំនាក់ទំនងការងារជារគឺជាទ្រព្យសម្បត្តិ

**គុណភាពផ្ទាល់ខ្លួន**

- សមត្ថភាពក្នុងការដោះស្រាយបញ្ហា និងធ្វើការសំរេចចិត្ត
- សមត្ថភាពក្នុងកាធ្វើការជាឯករាជ្យ និងជំរុញដោយខ្លួនឯង
- ជំនាញក្នុងការទំនាក់ទំនងក្នុងកន្លែងធ្វើការ និងសមត្ថភាពសហការជាសមាជិកក្រុម

- ជំនាញក្នុងការគ្រប់គ្រងផែនការ និងពេលវេលា

- សមត្ថភាពបទបែន ក្នុងការគ្រប់គ្រង និងទំនាក់ទំនងក្នុងក្រុម នៅក្នុងនាយកដ្ឋាននានារបស់រដ្ឋាភិបាល

- សមត្ថភាពធ្វើការសុខដុមរមនីកម្មជាមួយសហសេវិកនៅក្នុងបរិបទស្មុគ្រស្មាញ និងចាំបាច់

**២.២.២ ជំនួយការបច្ចេកទេសរយៈពេលខ្លី ដើម្បីជួយបង្កើតប្រព័ន្ធត្រួតពិនិត្យក្រុមខ្លួន (Peer Review System) សំរាប់សំណើសុំថ្មីៗ ពី ដៃគូអភិវឌ្ឍន៍ សុខាភិបាលទាំងអស់**

ប្រព័ន្ធត្រួតពិនិត្យក្រុមខ្លួន សំរាប់ផ្តួចផ្តើម និងស្រាវជ្រាវប្រព័ន្ធសុខាភិបាលថ្មីគឺមានកំណត់នៅក្នុងផែនការសកម្មភាពរបស់ រាជរដ្ឋាភិបាលកម្ពុជា សំរាប់សុខដុមនីកម្ម លទ្ធផល និងការតំរង់ទិស។ ទោះជាយ៉ាងណាប្រព័ន្ធត្រួតពិនិត្យក្រុមខ្លួន សំរាប់សំណើថ្មីៗ គឺជាមហិច្ឆិតាមួយ ហើយដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំជាយូរមក ហើយជាមួយនឹងដៃគូអភិវឌ្ឍន៍សុខាភិបាល និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាល។ ការប្រជុំទាំងនោះមិនបានសំរេចបានជាអ្វីនោះទេ ។

ទោះនេះជាបញ្ហាដែលត្រូវព្រួយបារម្ភ ការកំណត់របស់ប្រព័ន្ធត្រួតពិនិត្យក្រុមខ្លួនត្រូវបានកំណត់នៅក្នុងសំណើដែលបានផ្ញើជូនទៅមូលនិធិសកល ដោយគណកម្មការសំរបសំរួលថ្នាក់ជាតិ (ដែលហៅកាត់ថា CCC) ។ សមាសភាពនៃសំណើទាំងនេះត្រូវបានត្រួតពិនិត្យឡើងវិញដោយក្រុមត្រួតពិនិត្យមួយ ដែលចូលរួមពីសមាជិករាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សហគមន៍អ្នកផ្តល់ជំនួយ និងទីប្រឹក្សាឯករាជទាំងឡាយ។ អនុសាសន៍យោបល់របស់ក្រុមត្រួតពិនិត្យ ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តី សំរេចចុងក្រោយមួយរបស់សំណើថ្នាក់ប្រទេសដែលមានការសំរបសំរួលពី CCC ហើយប្រហែលជាអាចឆ្លងទៅដល់សមាសភាពតូចៗខាងក្រោម ដែលត្រូវពិនិត្យសើរើឡើងវិញ ឬក៏អាចដកចេញពីសំណើចុងក្រោយ។ ដំណើរការនេះទំនងជាមានការចូលរួម ដើម្បីបង្កើតគុណភាពសំណើដែលបានបញ្ជូនទៅមូលនិធិសកល ។

ដំណើរការត្រួតពិនិត្យរបស់គណកម្មការសំរបសំរួលថ្នាក់ជាតិកំពុងតែវិវត្ត និងកំណត់សំរាប់សំណើរបស់មូលនិធិសកលទាំងអស់។ គេបានផ្តល់យោបល់ថា បេសកកម្មក្នុងការជ្រើសរើសទីប្រឹក្សារបស់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិដើម្បី មានលទ្ធភាពចូលទៅដល់ដំណើរក្រុមវាយតំលៃរបស់មូលនិធិសល/គណកម្មការសំរបសំរួលថ្នាក់ជាតិ ដូចដែលបានរៀបរាប់ខាងលើ នឹងបានស្វែងរកពីលទ្ធភាពនៃការពង្រីកដំណើរការនេះ ដើម្បីឈានឱ្យដល់ផ្នែកសុខាភិបាលទូទៅ ។ សេវាប្រឹក្សានឹង ត្រូវបង្ហាញពីចំណុចដូចខាងក្រោម :

- កិច្ចព្រមព្រៀងទៅលើដំណើរ និងលក្ខណៈដើម្បីត្រួតពិនិត្យ

- សមត្ថភាព និងការជ្រើសរើសអ្នកត្រួតពិនិត្យក្នុងក្រុម

- កំណត់ពេលវេលា និងសិទ្ធិ សំរាប់ធ្វើការបញ្ចាក់ ឬបញ្ឈប់សំណើ

- សក្តានុពលសំរាប់ជំលោះផលប្រយោជន៏. ផ្តល់ការកំណត់ក្នុងការជ្រើសរើសអ្នកត្រួតពិនិត្យ និងការទំនាក់ទំនងគ្នា ទៅវិញទៅមករបស់ដៃគូទាំងអស់នៅក្នុងវិស័យសុខាភិបាល

## ២.២.៣ *ជំនួយការបច្ចេកទេសរយៈពេលខ្លី សំរាប់ជួយបណ្តុះបណ្តាល បុគ្គលិកនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ក្នុងការ គ្រប់គ្រងពតិមានយុទ្ធសាស្ត្រ*

ភារកិច្ចចំបងរបស់ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ គឺការគ្រប់គ្រងពតិមានទាំងឡាយដែលពាក់ព័ន្ធទៅនឹង :

- កិច្ចសំរបសំរួលអ្នកផ្តល់ជំនួយ រួមមានមូលនិធិដែលបានសន្យា មូលនិធិដែលបានគ្រោងទុក និងមូលនិធិដែលបានផ្តល់រួចហើយដោយអ្នកផ្តល់ជំនួយ និងភ្នាក់ងារប្រតិបត្តការដទៃទៀត។ ពតិមានទាំងនេះ នឹងត្រូវបំពេញទៅក្នុងក្របខ័ណ្ឌផែនការចំណាយសំរាប់រយៈសំរាប់មធ្យមដំណើរការផែនការប្រចាំឆ្នាំ និងដំណើរការធ្វើផែនការរំកិល ៣ឆ្នាំបន្តបន្ទាប់ទៅទៀត។

- ការចុះបញ្ជី ការធ្វើរបាយការណ៍ សកម្មភាព ការគ្របតណ្តប់ ថវិកាដែលបានទទួល និងសមិទ្ធិផលនៃការអនុវត្ត សកម្មភាពរបស់ភ្នាក់ងារ/អង្គការក្រៅរដ្ឋាភិបាល ។ ពតិមាននេះនឹងសំរួលដល់ការអនុវត្តក្នុងការ សំរបសំរួល និង ត្រួតពិនិត្យ សកម្មភាពការងាររបស់ភ្នាក់ងារ/ អង្គការក្រៅរដ្ឋាភិបាលនានា ។

- គ្រប់គ្រង និងថែរក្សាវេបសាយរបស់ក្រសួងសុខាភិបាល។ គ្រប់គ្រង និងថែរក្សានេះគឺជាប្រភពឯកសារវិស័យ សុខាភិបាល ដ៏សំខាន់មួយ ។

បុគ្គលិក នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិនឹងត្រូវការជំនាញក្នុងការបញ្ចូលទិន្នន័យ និងធ្វើសុខពលភាពទិន្នន័យ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យ ការធ្វើវិភាគ និងបង្កើតរបាយការណ៍ ការបង្កើតវេបសាយ ការគ្រប់គ្រងនិងថែរក្សា។ ទាំងនេះតំរូវឱ្យទីប្រឹក្សារយៈពេលខ្លីត្រូវផ្តល់ជាគំនិតផ្តួចផ្តើម និងផ្តល់ជាការសិក្សានៅនឹងកន្លែងដល់បុគ្គលិកនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងពតិមានទាំងអស់។ វាប្រហែលជាអាចធានាបាននូវសេវាកម្មនៃ អ្នកជំនាញDatabase របស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ឱ្យធ្វើការជាមួយបុគ្គលិកនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ក្នុងការផ្តល់ការបណ្តុះបណ្តាលនៅនឹងកន្លែង និងធ្វើការត្រួតពិនិត្យក្នុង

ការវិភាគទិន្នន័យ។ URC បានបញ្ជាក់ថានឹងគាំទ្រ ទៅដល់ទស្សនៈនៃជំនួយការបច្ចេកទេសទៅដល់ក្រសួងសុខាភិបាល ដើម្បីសំរបសំរួលការគ្រប់គ្រង និងថែរក្សាវេបសាយ ។

## ២.២.៤. ជំនួយការបច្ចេកទេសសំរាប់ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ ក្នុងការពង្រឹងតួនាទីក្នុងការសំរបសំរួល នៃជំនួនការអភិវឌ្ឍន៍ផ្លូវការចំពោះវិស័យ

សកម្មភាពចំបងរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិដែលរួមបញ្ចូលទៅក្នុងការសំរបសំរួលដៃគូអភិវឌ្ឍន៍គឺបានគូសបញ្ជាក់នៅក្នុង គំរោងគោលនយោបាយ និងគោលការណ៍ណែនាំ ដូចបានសង្ខេបជូនខាងក្រោមៈ

- ផ្តល់ជាផែនការ និងតាមដានដៃគូអភិវឌ្ឍន៍ដែលផ្តល់ថវិកាទៅវិស័យសុខាភិបាល វិភាគពត៌មានហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ និងបង្កើតគំរោងផែនការប្រចាំ និងផែនការរំកិលពាឆ្នាំទៅមុខទៀត សំរាប់អ្នកផ្តល់ជំនួយ និងអ្នកសន្យាផ្តល់ជំនួយដល់ក្រសួងសុខាភិបាល ។

- ផ្តល់ជាផែនការ និងតាមដានដៃគូអនុវត្ត/សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល ទំហំនិងសមិទ្ធិផលដែលទទួលបាន ទាំងអស់ ។

- សំរួលដល់ការពិនិត្យមើលសំណើរបស់ដៃគូអភិវឌ្ឍន៍ផ្នែកសុខាភិបាលទាំងឡាយ

- កំណត់ពីឱកាសសំរាប់វិធីដ៏មានប្រសិទ្ធភាពមនានា ក្នុងការផ្តុំជំនួយការអភិវឌ្ឍន៍ផ្លូវការ ជូនដល់វិស័យសុខាភិបាល

- តាមដាន និងពិនិត្យមើលជំនួយការបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ ដែលបានផ្តល់ជូនវិស័យសុខាភិបាល

- ត្រួតពិនិត្យ ហើយប្រសិនបើសមស្របចូលរួមនៅក្នុងគំរោង កម្មវិធី និងបេសសកម្មត្រួតពិនិត្យទាំងឡាយ

- ដើរតួជាអ្នកច្រកទំនាក់ទំនងផ្លូវការដំបូងរបស់កសួងសុខាភិបាលហើយដើរតួជា មជ្ឈមណ្ឌលផ្តល់ ពត៌មានសំរាប់គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលធ្វើការនៅក្នុងវិស័យសុខាភិបាល ។

- ដើរតួជាចំណុចប្រសព្វក្នុងការទំនាក់ទំនងជាមួយក្រសួងសុខាភិបាល ដើម្បីសំរបសំរួលគោលនយោបាយរវាងក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ សំរាប់កម្មវិធីជំនួយការអភិវឌ្ឍន៍ ជូនដល់វិស័យសុខាភិបាល ។

- សំរបសំរួលក្នុងការចែករំលែកពត៌មានស្តីពីការសំរេចចិត្តដែលព្រមព្រៀងរវាងក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ និងរាយការទ៍ពីការរីកចំរើន ដែលទទួលបានពីក្រុមការងារបច្ចេកទេសសុខាភិបាល ផ្អែកលើរបាយការណ៍តាមដំណាក់កាល ។

- សំរបសំរួលក្នុងការទំនាក់ទំនងរវាងក្រសួងសុខាភិបាល, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តការអន្តរជា ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ និងស្ថាប័នសំខាន់ៗ ដទៃទៀតដែលពាក់ព័ន្ធទៅនឹងការសំរបសំរួលរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការជូនដល់វិស័យសុខាភិបាល ។

មានតំរូវការចាំបាច់ចំពោះជំនួយការបច្ចេកទេសដែលកំពុងដំណើរការ ដើម្បីជួយដល់ការវិវត្តតួនាទីរបស់នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ និងការទទួលខុសត្រូវទាំងអស់ក្នុងការសំរាប់ដៃគូអភិវឌ្ឍន៍ ។

## ២.៣ តំរូវការរចនាសម្ព័ន្ធ

ដើម្បីឱ្យនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិមានតួនាទីជាមជ្ឈមណ្ឌលផ្តល់សេវា One-stop Service សំរាប់ការសំរបសំរួលដៃគូអភិវឌ្ឍន៍ នាយកដ្ឋាននេះនឹងត្រូវការបន្ថែមនូវសំភារៈការិយាល័យ ទីកន្លែងធំទូលាយ និងបុគ្គលិក និងធនធានបន្ថែមទៀត ។

សេចក្តីត្រូវការរចនាសម្ព័ន្ធចំបងសំរាប់ នាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ គឺទាក់ទិនទៅនឹងការបង្កើនសមត្ថភាពសំរាប់ការគ្រប់គ្រងពត៌មាននៅក្នុងនាយកដ្ឋាន ។ ត្រូវមានប្រព័ន្ធកុំព្យូទ័រដែលមានសមត្ថភាពអាចគ្រប់គ្រងកម្មវិធី SQL បន្ថែម ទៀត (ដូចជា Microsoft Access) និងមានល្បឿនលឿនសំរាប់ការភ្ជាប់ Internet ដែលអាចឱ្យនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ អាចដកស្រង់យកឯកសារស្រួល និងធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួរបែបសាយ (Website) ។

## ឧបសម្ព័ន្ធ១ ម្ចាស់ជំនួយក្នុងវិស័យសុខាភិបាល ឆ្នាំ២០០៦

| | (US$ Millions) |
|---|---|
| **ពហុភាគី(Multilateral)** | **29.1** |
| អង្គសហប្រជាជាតិ (United Nations) | 13.1 |
| WHO | 4.1 |
| WFP | 2.9 |
| UNFPA | 2.7 |
| UNICEF | 1.3 |
| FAO | 1.1 |
| UNAIDS | 0.4 |
| UNDP | 0.4 |
| UNESCO | 0.1 |
| UNODC | 0.1 |
| EC | 8.6 |
| IBRD/WB | 4.0 |
| ADB | 3.4 |
| **ទ្វេភាគី(Bilateral)** | **61.1** |
| US | 25.7 |
| Japan | 11.4 |
| UK | 10.5 |
| Germany | 3.5 |
| France | 3.4 |
| Belgium | 2.3 |
| Switzerland | 2.2 |
| Korea | 1.6 |
| Canada | 0.2 |
| Australia | 0.1 |
| China | 0.1 |
| Denmark | 0.1 |
| **ភាពជាដៃគូសុខភាពសាកល (Global Health Partnerships)** | **22.2** |
| GFATM | 11.9* |
| **NGO Own Funds** | **28.3** |
| **TOTAL** | **140.7** |